# បញ្ញាវឌ្ឍកៈ

## និង

# សាមណេរវិន័យ

គណៈកម្មការធម្មវិន័យ

ការផ្សាយរបស់វិជ្ជាស្ថាន ពុទ្ធសាសនបណ្ឌិត្យ

ព.ស. ២៥៣៣ គ.ស. ១៩៨៩

www.elibraryofcambodia.org

# បព្វជ្ជាខន្ធក

## និង

# សាមណេរវិន័យ

គណៈកម្មការធម្មវិន័យ

អំណោយរបស់
លោក ខៅ ប៊ុនសំអឿង
ដល់ការិយាល័យខ្មែរ ដើម្បី
ទុកដាក់ក្នុង
elibrary of Cambodia
ឧសភា ២០១៤



ការផ្សាយរបស់វិទ្យាស្ថាន ពុទ្ធសាសនបណ្ឌិត្យ

បោះពុម្ពលើកទី ១ ចំនួន ៥.០០០ ក្បាល

បោះពុម្ពនៅរោងពុម្ពកងទ័ព

ក្រោសិដ្ឋ

ព.ស. ២៥៣៣ គ.ស. ១៩៨៩

www.elibraryofcambodia.org

# អារម្ភកថា

មូលហេតុនាំឲ្យបោះពុម្ពសៀវភៅ បព្វជ្ជាខន្ធកៈ និងសាមណេរវិន័យ ទាំងពីរមុខនេះ ឡើងវិញដោយ ៖

- ព្រះពុទ្ធសាសនាដែលប្រជាពលរដ្ឋកម្ពុជាភាគច្រើន គោរពប្រតិបត្តិ ចាប់តាំងពីពុទ្ធសតវត្សទី៧មកនោះ ក្នុងកាលខ្លះរុងរឿង កាលខ្លះ អន់ថយចុះទៅតាមសភាពការណ៍របស់ប្រទេសជាតិ ។ ប៉ុន្តែទោះជាយ៉ាងណា ក៏ព្រះពុទ្ធសាសនាពុំដែលធ្លាក់ដល់កម្រិតសូន្យដែរ ។

- របបប្រល័យពូជសាសន៍ គ្រប់គ្រងប្រទេសជាតិ ពីខែមេសា ឆ្នាំ ១៩៧៥ ដល់ខែ មករា ឆ្នាំ ១៩៧៩ ព្រះពុទ្ធសាសនា នៅកម្ពុជា ត្រូវបានពួកគេលុបបំបាត់ចោលទាំងស្រុង ។ ព្រះសង្ឃត្រូវពួកគេ បំបាត់សូន្យជាស្ថាពរឈប់អោយមាន, វត្តអារាម និងគម្ពីរ ក្បួន ច្បាប់ ទាំងអស់ត្រូវគេកម្ទេចចោលស្ទើរសូន្យ ។

- ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ថ្ងៃជ័យជម្នះជាប្រវត្តិសាស្ត្រ របស់ប្រជាជនកម្ពុជា លើរបបប្រល័យពូជសាសន៍ អ៊ុ ៗ ទាំងអស់ត្រូវ បានរស់ឡើងវិញ ។

- យល់ឃើញថា វិន័យ ជាឫសគល់ព្រះពុទ្ធសាសនា បើវិន័យ ស្ថិតនៅដរាបណា ព្រះពុទ្ធសាសនា ស្ថិតនៅដរាបនោះ ។

www.elibraryofcambodia.org

- ព្រះសង្ឃទូទាំងប្រទេសកម្ពុជា មានចំនួនកើនច្រើនឡើងរៀងរាល់ឆ្នាំ ។

- ជួយសម្រួលពួកកុលបុត្រ អ្នកប្រាថ្នាសាងផ្នួសជាសាមណេរ ឬ ភិក្ខុបានរៀនសូត្រយល់ដឹង នូវរបៀបសុំបព្វជ្ជា និងឧបសម្បទា ត្រៀមខ្លួនទុកជាមុន ។

- ផ្អែកតាមរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា បានកំណត់ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ។

- ផ្អែកតាមលិខិត របស់គណៈលេខាមជ្ឈិមបក្សប្រជាជនកម្ពុជា លេខ៦៦.ដ.ទ.ម.ប ចុះថ្ងៃទី ២២ មិនា ១៩៨០ ឲ្យបោះពុម្ពសៀវភៅធម្មវិន័យដែលមានស្រាប់ពីមុនឡើងវិញ ក្នុងនោះមានបព្វជ្ជាខន្ធកៈ និង សាមណេរវិន័យផងដែរ ដើម្បីបម្រើសំណូមពរពុទ្ធសាសនិកទូទៅ ។

គណៈកម្មការរៀបចំបោះពុម្ពសៀវភៅ ធម្មវិន័យ របស់ក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា បានបោះពុម្ពសៀវភៅ ២មុខនេះគឺ បព្វជ្ជាខន្ធកៈ និង សាមណេរវិន័យជាមុនដោយហេតុកុលបុត្រអ្នកបួសថ្មី ឬ រៀនសូត្រត្រៀមចាំបួស គេត្រូវការជាបន្ទាន់ ។

សូមបញ្ជាក់ថា សម័យមុនគេចែកបព្វជ្ជាខន្ធកៈជាស្នាព្រះហស្តសម្តេចឧត្តមប្រឹក្សា ល្វី ឯម ជាសៀវភៅមួយ, សាមណេរវិន័យជាស្នាព្រះហស្តរបស់ព្រះឧត្តមមុនី អ៊ុម ស៊ូ និង សម្តេចព្រះសង្ឃរាជ


www.elibraryofcambodia.org

ជោតញ្ញាណោ ជួន ណាត កាលនៅជាព្រះគ្រូសង្ឃសត្ថា ជាសៀវភៅមួយ ដាច់ពីគ្នា, ប៉ុន្តែឥឡូវនេះ គណៈកម្មការយល់ឃើញថា បព្វជ្ជា និង ឧបសម្បទា ជាប់នៅជាមួយគ្នា គឺបួសជាសាមណេរត្រឹមត្រូវរួចហើយ លុះគ្រប់អាយុ ទើបសូត្រញត្តិបំពេញឧបសម្បទាជាភិក្ខុខាងក្រោយ ។ ហេតុដូច្នេះ កុលបុត្រអ្នកប្រាថ្នាបួសត្រូវតែចេះច្បាប់បួស ក្នុងសៀវភៅទាំងពីរមុខនេះដាច់ខាត ។ ទើបគណៈកម្មការសម្រេចថា បោះពុម្ពសៀវភៅទាំងពីរមុខនេះ រួបរួមបញ្ចូលគ្នាជាសៀវភៅមួយទៅវិញ ដើម្បីងាយស្រួលទុកដាក់ផង ងាយស្រួលរៀនសូត្រផង រីឯខ្លឹមសាររបស់សៀវភៅទាំងពីរមុខ, គណៈកម្មការរក្សាទុកទាំងស្រុងដូចច្បាប់ដើមមុនឥតមានបញ្ចូល - បញ្ចេញត្រង់ណាឡើយ ។

គណៈកម្មការរៀបចំបោះពុម្ពសៀវភៅ

ធម៌វិន័យ ព្រះពុទ្ធសាសនា

ក្រុមប្រឹក្សាទូទាំងប្រទេសរណសិរ្ស
សាមគ្គីកសាងការពារមាតុភូមិកម្ពុជា

លេខ ៣៥-៨៥ ក.រ.ស.

សាធារណរដ្ឋប្រជាមានិតកម្ពុជា
ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ភ្នំពេញ, ថ្ងៃទី ៦ សីហា ១៩៨៥

# សេចក្តីសម្រេច

## ស្តីពីការបង្កើតគណៈកម្មការរៀបចំបោះពុម្ពសៀវភៅ
## ធម៌វិន័យព្រះពុទ្ធសាសនា

- បានឃើញសេចក្តីសម្រេចលេខ ៣៧៧ ស.រ.ម ឈ. ចុះថ្ងៃទី ២៣ វិច្ឆិកា ១៩៨២ ស្តីពីការបង្កើតក្បាលម៉ាស៊ីន នៃទីស្តីការក្រុមប្រឹក្សាទូទាំងប្រទេសរណសិរ្ស,

- បានឃើញកំណត់ហេតុលេខ ៥៨ -- ៨៥ នស. ចុះថ្ងៃទី ៣១ ឧសភា ១៩៨៥ ស្តីពីការប្រជុំរៀបចំសមាសភាព គណៈកម្មការបោះពុម្ពសៀវភៅធម៌វិន័យព្រះពុទ្ធសាសនា,

- បានឃើញសំណើឡើងរបស់គណៈកម្មការ ដោយមានការឯកភាពរបស់ព្រះវិន័យធរ ទេព វង្ស ផង,

- បានឃើញកំណត់ហេតុ អង្គប្រជុំគណៈអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាទូទាំងប្រទេសរណសិរ្ស ចុះថ្ងៃទី ៦ សីហា ១៩៨៥ ។

គណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សាទូទាំងប្រទេសរណសិរ្ស

## សម្រេច

ប្រការ ១- បង្កើតគណៈកម្មការរៀបចំពិនិត្យ បោះពុម្ពសៀវភៅធម៌វិន័យព្រះពុទ្ធសាសនាមួយក្រុម ។

www.elibraryofcambodia.org

ប្រការ ២. គណៈកម្មការនេះ មានសមត្ថភាពបំពេញការកិច្ចពិនិត្យស្រាវជ្រាវត្រិះរិះពិចារណា រៀបចំកែលម្អគ្រប់ឯកសារ ជៀសវាងការខុសឆ្គងដល់ទំនៀមទម្លាប់សង្គមយើង ។

ប្រការ ៣. យោងតាមសំណើរបស់អង្គប្រជុំ តាមកំណត់ហេតុលេខ ៥៨-៨៥ នស. ចុះថ្ងៃទី ៣១ ឧសភា ១៩៨៥ ស្នើបោះពុម្ពជាដំបូងនូវសៀវភៅ គោលគតិបរិបដិបត្តិ ។

ប្រការ ៤- គ្រប់ឯកសារទាំងអស់ ដែលត្រូវបោះពុម្ពលុះតែមានការអនុញ្ញាតយល់ព្រមពីថ្នាក់លើជាមុនសិន ទើបអាចបោះពុម្ពបាន ។

ប្រការ ៥. សេចក្តីសម្រេចនេះ មានប្រសិទ្ធភាព ចាប់ពីចុះហត្ថលេខានេះតទៅ ៖

ជ.គណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សាទូទាំងប្រទេស
រណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា
អនុប្រធានអចិន្ត្រៃយ៍
ហត្ថលេខា និងត្រា
**ម៉ែន ឆន**

www.elibraryofcambodia.org

# មាតិកា


| ឈ្មោះ | ទំព័រ |
| --- | --- |
| - បព្វជ្ជាខន្ធកៈ | ១ |
| - ឧបជ្ឈាយវិធី | ៧ |
| - កម្មវាចាចារិយវិធី | ៩ |
| - បព្វជ្ជាវិធី | ១០ |
| - ឧបជ្ឈាយគ្គហណវិធី | ១៧ |
| - ឧបសម្បទាវិធី | ១៩ |
| - អនុសាសនវិធី | ២៧ |
| - សព្ទវិត្យាធិប្បាយ | ៣៤ |
| - អធិប្បាយក្នុងឧបជ្ឈាយវិធី | ៣៥ |
| - អធិប្បាយក្នុងកម្មវាចាចារិយវិធី | ៣៦ |
| - អធិប្បាយក្នុងបព្វជ្ជាវិធី | ៤៨ |
| - អធិប្បាយក្នុងអនុសាសនវិធី | ៥៨ |
| - បទានុក្រម | ៥៩ |
| - បណាមគាថា | ៦៩ |
| - សាមណេរវិន័យ | ៧០ |
| - សិក្ខាបទ ១០ | ៧៣ |
| - ទណ្ឌកម្ម ១០ | ៧៤ |
| - នាសនង្គៈ ១០ | ៧៦ |
| - អង្គនៃសិក្ខាបទ ១០ | ៧៧ |
| - បយោគ | ៨១ |
| - កិច្ចនៃទណ្ឌកម្ម | ៨២ |
| - កិច្ចនៃនាសនង្គៈ | ៨៥ |
| - សេខិយវគ្គ | ៩២ |
| - បច្ចវេក្ខណៈ | ១០៤ |

# នមត្ថុ រតនត្តយស្ស

បព្ជាខន្ធកសង្ខេប

## ទី១ អក្ខរវិធិ

វិធិអក្សរដែលប្រើក្នុងបាលីភាសា មាន ៤១ តួ គឺ អ អា ឥ ឦ ឧ ឩ, ឯ ឱ ក ខ គ ឃ ង ច ឆ ជ ឈ ញ ដ ឋ ឌ ឍ ណ ត ថ ទ ធ ន ប ផ ព ភ ម យ រ ល វ ស ហ ឡ អំ ។

អក្ខរៈ ៨ តួ តាំងពី អ ដល់ ឱ ឈ្មោះថាស្រៈ ព្រោះចេញសំឡេងបានតាមទំនើងខ្លួនឯង ហើយអាចទឹងញុំាងព្យញ្ជនៈឱ្យចេញសំឡេងផងបាន ។

ឯស្រៈទាំង៨តួនេះ ចាត់ជាគូបាន៣គូ គឺ អ អា ហៅថា អវណ្ណៈជាគូ ១ ឥ ឦ ហៅថាឥវណ្ណៈជាគូ១ ឧ ឩ ហៅថាឧវណ្ណៈជាគូ១ ។ ស្រៈឯនិងស្រៈឱទាំង២តួនេះ ហៅថា សំយុត្តសរៈ ព្រោះប្រកបសំឡេងស្រៈ២តួ ផ្សំចូលគ្នាជាសំឡេង ១ គឺ អ និង ឥ ផ្សំចូលគ្នាជា ឯ, អ និង ឧ ផ្សំចូលគ្នាជា ឱ ព្រោះហេតុនោះ ស្រៈទាំង២តួនេះ ទើបកើតក្នុង ២ ឋាន តាមន័យដែលនឹងមានពោលក្នុងខាងមុខ ។

ក៏ស្រៈទាំង៨តួនេះ ចែកចេញជា ២ ពួក គឺ ជារស្សៈ ពួក ១ ជាទីឃៈពួក១ ស្រៈដែលមានមាត្រារបស់សៀសរាន់ ៣តួ គឺ អ ឥ ឧ ឈ្មោះថារស្សៈ ព្រោះជាស្រៈមានសំឡេងខ្លី ដូចពាក្យថា ឥតិបិ អបិនុ ដូច្នេះជាដើម ។

ស្រៈដែលមានមាត្រាវែង ៥ តួ គឺ **អាឦឩឯឱ** ឈ្មោះថា ទីឃៈ ព្រោះជាស្រៈមានសំឡេងវែង ដូចពាក្យថា **ភាគី ថូបោ នេខោ** ដូច្នេះជាដើម ។ ស្រៈទីឃៈ ២ តួ គឺ ឯ និង ឱ បើមានព្យញ្ជនៈសំយោគតម្រួតគ្នា ២ តួ នោះលោកពោលថា មានសំឡេងខ្លីបន្តិច ប្រហែលដូចជារស្សៈដូចពាក្យថា **ឯត្ត មេត្តា សេយ្យោ សេដ្ឋី ឱដ្ឋោ សោត្ថិ** ដូច្នេះជាដើម។

អក្ខរៈ ៣៣ តួ មាន ក ជាដើម មាន អំ ជាទីបំផុត ឈ្មោះថា ព្យញ្ជនៈ ព្រោះជាអក្ខរៈធ្វើនូវសេចក្ដីឲ្យច្បាស់ប្រាកដ តែថាលុះតែទៅអាស្រ័យនឹងស្រៈផង ទើបនឹងអាចធ្វើនូវសេចក្ដី ឲ្យច្បាស់ប្រាកដឡើងបាន ។ ដូចពាក្យថា **ថូបា បិតា ភេសា** ដូច្នេះជាដើម បើព្យញ្ជនៈ មិនចូលអាស្រ័យនឹងស្រៈ ផងទេ ក៏ឮសូរតែសំឡេងស្រៈម្យ៉ាង ត្រឡប់ទៅជាឮថា ◌ូ, ◌ា, ◌ិ, ◌ា, េ◌, េ◌ា ដូច្នេះទៅវិញអស់ លុះតែព្យញ្ជនៈ ចូលអាស្រ័យផងនោះ ទើបមានសេចក្ដីច្បាស់ប្រាកដឡើងបាន ។

ព្យញ្ជនៈទាំង ៣៣ តួនោះ ចែកចេញជា ២ ពួក គឺជាវគ្គៈពួក១ ជាអវគ្គៈពួក ១ ។ វគ្គៈនោះចែកចេញទៅទៀត ជា ៥ ពួកគឺ

**កខគឃង** ៥ តួនេះ ហៅថា **កវគ្គៈ**

**ចឆជឈញ** ៥ តួនេះ ហៅថា **ចវគ្គៈ**

**ដឋឌឍណ** ៥ តួនេះ ហៅថា **ដវគ្គៈ**

**តថទធន** ៥ តួនេះ ហៅថា **តវគ្គៈ**

**បផពភម** ៥ តួនេះ ហៅថា **បវគ្គៈ**

ព្យញ្ជនៈទាំង ២៥ តួនេះ ជាពួក ៗ ផងគ្នា តាមឋានករណៈ ទីកើតដែលនឹងមានសេចក្ដីពោលក្នុងខាងមុខ ហេតុនោះទើបឈ្មោះថា វគ្គៈ ព្រោះជាពួកៗ ។

ព្យញ្ជនៈ ៨ តួ គឺ យរលវសហឡអំ នេះហៅថា អវគ្គៈព្រោះមិនមាន ពួកតាមឋានករណៈទីកើត ។ ព្យញ្ជនៈ គឺ អំ នេះ ហៅថានិគ្គហិត ។ នោះលុះតែមានស្រៈ ៣ តួ គឺ អឥឧ នៅខាងក្រោមនោះ ទើបអាស្រ័យនៅបាន ដូចពាក្យថា អហំ សេតុំ អភាសី ដូច្នេះជាដើម ។

ម្យ៉ាងទៀត ព្យញ្ជនៈទាំងអស់នោះ លោកចែកចេញជា ២ ចំណែក គឺ ជាឃោសៈ ១ ចំណែក ជាអឃោសៈ ១ ចំណែក និងពោលខាងអឃោសៈមុន តាមលំដាប់អក្ខរៈដូច្នេះគឺ

កខ ចឆ ដឋ តថ បផ ស ១១ តួនេះ ហៅថា អឃោសៈ ជាព្យញ្ជនៈ មានសំឡេងមិនលាន់ឮគឹកកង ។ ព្យញ្ជនៈ គឺ គឃង ជឈញ ឌឍណ ទធន ពភម យរលវហឡ ២១ តួនេះ ហៅថា ឃោសៈ ជាព្យញ្ជនៈមានសំឡេងលាន់ឮគឹកកង ។ ព្យញ្ជនៈ គឺ អំ នេះ ជាឃោសាឃោសវិមុត្ត រួចចាកឃោសៈនិងអឃោសៈ គឺមិនមែនជាឃោសៈ និងអឃោសៈឡើយ ។

# ឋានករណៈ នៃ អក្ខរៈ

ឋានទីតាំងដែលនឹងកើតនៃអក្ខរៈ មាន ៧ យ៉ាង គឺ **កណ្ឋោ** ក ១ **តាលុ** ពិតាន១ **មុទ្ធា** ក្បាល១ **ទន្តោ** ធ្មេញ១ **ឱដ្ឋោ** បបូរមាត់១ **នាសិកា** ច្រមុះ១ ឧរោ ទ្រូង១ ។ អក្ខរៈពួកខ្លះកើតក្នុងឋាន១ ពួកខ្លះកើតក្នុងឋាន២ ។ អ អា ក ខ គ ឃ ង ហ ៨ តួនេះ កើតក្នុង ក ហៅថា កណ្ឋជៈ ឥ ឦ ច ឆ ជ ឈ ញ យ ៨ តួនេះកើតក្នុងពិតាន ហៅថា តាលុជៈ ដ ឋ ឌ ឍ ណ រ ឡ ៧ តួនេះកើតក្នុងក្បាល ហៅថា មុទ្ធជៈ ត ថ ទ ធ ន ល ស ៧ តួនេះកើតត្រង់ប្រទល់ធ្មេញហៅថា ទន្តជៈ ឧ ឩ ប ផ ព ភ ម ៧ តួនេះកើតត្រង់រឹមបបូរមាត់ ហៅថា ឱដ្ឋជៈ និគ្គហិត កើតក្នុងច្រមុះ ហៅថា នាសិកជៈ ។

អក្ខរៈប៉ុណ្ណេះ លើកតែព្យញ្ជនៈទីបំផុតវគ្គ៥តួគឺ ង ញ ណ ន ម នេះចេញ នោះលោកពោលថាកើតក្នុងឋាន១ ។ តួ ឯ កើតក្នុង ២ ឋាន គឺ ក និង ពិតាន ហៅថា កណ្ឋតាលុជៈ ។ តួ ឱ កើតក្នុង២ឋានគឺ ក និងបបូរមាត់ ហៅថា កណ្ឋោដ្ឋជៈ ។ ព្យញ្ជនៈទីបំផុតវគ្គទាំង៥តួ គឺ ង ញ ណ ន ម កើតក្នុង ២ ឋាន គឺតាមឋានរបស់ខ្លួនៗ និងច្រមុះហៅថា សកដ្ឋាននាសិកជៈ ។

ភូវ កើតក្នុង ២ ឋាន គឺធ្មេញនិងរឹមបបូរមាត់ ហៅថា ទន្តោដ្ឋជៈ ។ ព្យញ្ជនៈ គឺ ហ នេះ បើប្រកបចូលនឹងព្យញ្ជនៈ៨តួ គឺ ញ ណ (ន) ម យ ល វ ឡ ដូចពាក្យថា តញ្ហិ កណ្ហា តម្ហា មយ្ហំ ទុល្ហំ ជិវ្ហា រុឡ្ហា ដូច្នេះជាដើម នោះលោកពោលថាកើតក្នុងទ្រូង ហៅថា ឱរជៈ បើមិនប្រកបចូលនឹងព្យញ្ជនៈទាំង៨តួនេះទេ ក៏កើតក្នុង ក តាមឋានរបស់ខ្លួនដដែល ។

ករណៈ គឺ អវយវៈ ជាទីធ្វើនូវសំឡេងនៃអក្ខរៈនោះ មាន ៤ យ៉ាង គឺ ជិវ្ហាមជ្ឈំ ពាក់កណ្ដាលអណ្ដាត ១ ជិវ្ហោបគ្គំ រលាស់ចុងអណ្ដាតចូលមក ១ ជិវ្ហគ្គំ ចុងអណ្ដាត ១ សកដ្ឋានំ ឋានរបស់ខ្លួន ១ ។ ពាក់កណ្ដាលអណ្ដាតជាករណៈរបស់អក្ខរៈដែលជាតាលុជៈ រលាស់ចុងអណ្ដាតចូលមក ជាករណៈរបស់អក្ខរៈដែលជាមុទ្ធជៈ ចុងអណ្ដាតជាករណៈរបស់អក្ខរៈដែលជាទន្តជៈ ឋានរបស់ខ្លួនជាករណៈរបស់អក្ខរៈ ដែលសល់ចាកអក្ខរៈជា តាលុជៈ មុទ្ធជៈ និង ទន្តជៈ ។

## អក្ខរប្បភេទ

ប្រភេទនៃអក្ខរៈមាន ១០ យ៉ាង គឺ សិថិល ១ ធនិត ១ ទីឃៈ ១ រស្សៈ ១ គរុ ១ លហុ ១ សម្ពន្ធៈ ១ វវត្ថិតៈ ១ និគ្គហិត ១ វិមុត្ត ១ ។

ព្យញ្ជនៈជាបឋមនិងព្យញ្ជនៈជាគម្រប់(១) ៣ ក្នុងវគ្គទាំង ៥ គឺ កគ ចជ ដឌ តទ បព ១០តួនេះ ហៅថាសិថិល មានសំឡេងធូរស្រាល ព្យញ្ជនៈជាគម្រប់ ២ និងព្យញ្ជនៈជាគម្រប់ ៤ ក្នុងវគ្គទាំង ៥ គឺ ខឃ ឆឈ ឋឍ ថធ ផភ ១០ តួនេះហៅថា ធនិត មានសំឡេងតឹងលាន់ឮខ្លាំង ។

ឯទីឃៈនិងរស្សៈនោះ មានសេចក្ដីដូចបានពោលក្នុងខាងដើមរួចហើយ ។

---

១ គួរប្រែថា មិ ងាយស្ដាប់ផាង

ស្រៈដែលជាទីឃៈសុទ្ធ និងស្រៈដែលជារស្សៈ ដែលមានព្យញ្ជនៈ សំយោគតម្រួតគ្នានៅខាងចុង ឬមាននិគ្គហិតនៅខាងលើ ដូចពាក្យថា ពុទ្ធំ ធម្មំ សង្ឃំ សម្មាសម្ពុទ្ធោ ដូច្នេះជាដើមហៅថា គរុ ត្រូវពោលបន្លឺឲ្យយូរ ឲ្យធ្ងន់ ។

ស្រៈដែលជារស្សៈសុទ្ធ មិនមានព្យញ្ជនៈសំយោគតម្រួតគ្នា នៅខាងចុង និងមិនមាននិគ្គហិតនៅខាងលើ ដូចពាក្យថា ឥតិបិ ខមតុ ដូច្នេះជាដើម ហៅថា លហុ ត្រូវពោលឲ្យមានសំឡេងស្រាល-រហ័ស ។

អក្ខរៈដែលលោកតបទសន្ធិ តាំងពីអក្ខរៈ២តួ ឬ២បទឡើងទៅ ឲ្យជាប់ចូលគ្នាជាបទ ១ ដូចពាក្យថា ស្មិន្និ ភិន្នុ ខរុត្តមំ ឧទិរធាត្តមំ ដូច្នេះជាដើមហៅថា សម្ពន្ធៈ ត្រូវពោលឲ្យជាប់ជាបទ១កុំញែកឲ្យដាច់ពីគ្នា ។

អក្ខរៈដែលលោកកាត់បទ ញែកចេញពីបទសន្ធិ ឲ្យដាច់ចេញពីគ្នា ក្នុងកាលដែលនឹងប្រែ ដូចពាក្យថា ស្មីនិ ភីនុ ខរំ ឧត្តមំ ឧទិធំ ឧត្តមំ ដូច្នេះជាដើម ហៅថា វវត្ថិតៈ ព្រោះជាអក្ខរៈសម្រាប់កាត់បទ និងប្រែឲ្យដឹងសេចក្តី ។

អក្ខរៈឯណា ក្នុងវេលាដែលនឹងពោល មានសំឡេងដូចតួ ង ឬតួ ម ប្រកបខាងចុង ដូចពាក្យថា ពុទ្ធំ ធម្មំ សង្ឃំ ពុទ្ធម៑ ធម្មម៑ សង្ឃម៑ ដូច្នេះជាដើម អក្ខរៈនោះឈ្មោះថា និគ្គហិត ។

អក្ខរៈឯណាក្នុងវេលាដែលនឹងពោល បើកមាត់ហាលើសជាងប្រក្រតី ដូចពាក្យថា ឱភារធា រថេរា ឆារគា ជារណា ដូច្នេះជាដើម អក្ខរៈនោះ ឈ្មោះថា វិមុត្ត ។

ប្រភេទនៃអក្ខរៈនេះជាគូៗនឹងគ្នាគឺសិថិល ជាគូនិងធនិត ទីឃៈជាគូនិងរស្សៈ គរុ ជាគូនិងលហុ សម្ពន្ធៈ ជាគូនិងវវត្ថិតៈ និគ្គហិត ជាគូនិងវិមុត្ត ។

ចប់អក្ខរវិធីដោយសង្ខេប



www.elibraryofcambodia.org

# ទី២ ឧបជ្ឈាយវិធី

## វិធីនៃភិក្ខុដែលគួរនឹងធ្វើជាឧបជ្ឈាយ៍បាន ។

### អត្ថាធិប្បាយថា

ភិក្ខុដែលគួរនឹងធ្វើជាឧបជ្ឈាយ៍ បំបួសកុលបុត្របាននោះ លុះតែប្រកបដោយអង្គ ៥ យ៉ាង ដូចមានបាលីពុទ្ធានុញ្ញាតទុកក្នុងគម្ពីរមហាវគ្គថា **បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតេន ភិក្ខុនា ឧបសម្បាទេតព្វំ** ជាដើម ប្រែថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៥ ទើបគួរឲ្យឧបសម្បទា និងឲ្យនិស្ស័យដល់កុលបុត្របាន ។

ឯអង្គ ៥ នោះ គឺ

**អាបត្តឹ ជានាតិ** ចេះដឹងថា មានអាបត្តិ ១

**អនាបត្តឹ ជានាតិ** ចេះដឹងថា មិនមានអាបត្តិ ១

**លហុកំ អាបត្តឹ ជានាតិ** ចេះដឹងថា អាបត្តិមានទោសស្រាល ១

**គរុកំ អាបត្តឹ ជានាតិ** ចេះដឹងថា អាបត្តិមានទោសធ្ងន់ ១

**ទស វស្សោ វា ហោតិ អតិរេកទសវស្សោ វា** ភិក្ខុមានវស្សា ១០ ឬមានវស្សាច្រើនជាង ១០ ឡើងទៅ ១ ។

ម្យ៉ាងទៀត ក្នុងគម្ពីរចុល្លគណ្ឋិមហាវគ្គថា ភិក្ខុប្រកបដោយអង្គ៣យ៉ាង គឺ

**មនុស្សភូតោ** ជាតិជាមនុស្សសុទ្ធ មិនមែនជាសត្វតិរច្ឆាន ១

**ភិក្ខុភាវោ** បួសកើតជាភិក្ខុពេញបរិបូណ៌ ១

**ឧបជ្ឈាយង្គសមន្នាគតោ** ប្រកបដោយអង្គជារបស់ឧបជ្ឈាយ៍ ១

បណ្ណាអង្គទាំង ៣ នេះត្រង់អង្គទិ ៣ ខាងចុងនោះ ចែកទៅជា ១៤ គឺ

មង្គលាមង្គលានិសំសំ ជានាតិ ចេះដឹងនូវអានិសង្សនៃសូត្រ ជាមង្គលមានរតនសូត្រជាដើម និង អានិសង្សនៃសូត្រមិនមែនជាមង្គល គឺតិរោកុឌ្ឌសូត្រ ១

កម្មាកម្មំ ជានាតិ ចេះដឹងសង្ឃកម្ម និង មិនមែនសង្ឃកម្ម ១

សិក្ខាបទំ ជានាតិ ចេះដឹងសិក្ខាបទក្នុងព្រះបាតិមោក្ខទាំង២២៧ មួយ

សិក្ខាបទង្គំ ជានាតិ ចេះដឹងអង្គនៃសិក្ខាបទនោះ ៗ ១

សរណគមនំ ជានាតិ ចេះពោលនូវព្រះត្រៃសរណគមន៍ ត្រឹមត្រូវតាមភាសាបាឡី ជាសម្ពន្ធ ថា ពុទ្ធំ សរណំ គច្ឆាមិ ជាដើម និង មការន្ត ជាមួយបទមុខៗ បានថា ពុទ្ធម សរណម គច្ឆាមិ ជាដើម ១

ឧបោសថំ ជានាតិ ចេះដឹងឧបោសថកម្ម ប្រកបដោយលក្ខណៈទាំងប្រាំបួន ១

ឧបោសថកម្មំ ជានាតិ ចេះដឹងឧបោសថកម្ម ៤ យ៉ាង ១

ញត្តិសម្បត្តិ ជានាតិ ចេះដឹងញត្តិសម្បត្តិ ១

ញត្តិវិបត្តិ ជានាតិ ចេះដឹងញត្តិវិបត្តិ ១

អក្ខរសម្បត្តិ ជានាតិ ចេះដឹងអក្ខរសម្បត្តិត្រឹមត្រូវតាមអក្ខរវិធីដែលបានពោលហើយខាងដើម ១

អក្ខរវិបត្តិ ជានាតិ ចេះដឹងអក្ខរវិបត្តិ ខុសចាកអក្ខរប្បភេទទាំង១០យ៉ាង ដែលបានពោលហើយខាងដើម ១

ឧភយានិ បាតិមោក្ខានិ ចេះសូធ្យបាតិមោក្ខទាំង២ គឺ ភិក្ខុបាតិមោក្ខ និងភិក្ខុនីបាតិមោក្ខ ចាំស្ទាត់រត់មាត់ ១

ទសវស្សោ វា ហោតិ អតិរេកទសវស្សោ វា មានវស្សា ១០ ឬមានវស្សាក្រែនផាង ១០ឡើងទៅ ១

នាមរូបំ ជានាតិ ចេះដឹងបរមត្ថព្រះអភិធម្ម គឺ ចិត្ត ចេតសិក រូប និព្វាន ១ ។

បើភិក្ខុប្រកបដោយអង្គ ដូចបានពោលមកហើយនេះ ទើបធ្វើជាឧបជ្ឈាយ៍ពេញបរិបូណ៌បាន ។

ចប់ឧបជ្ឈាយវិធី

## ទី ៣ កម្មវាចាចារិយវិធី

វិធីនៃភិក្ខុដែលគួរធ្វើជាគ្រូសូធ្យ សូធ្យកម្មវាចាបាន ។

អធិប្បាយថា

ភិក្ខុដែលនឹងធ្វើជាគ្រូសូធ្យបាននោះ មិនបានកំណត់ថាចាស់វស្សា ឬខ្ចីវស្សាទេ សូម្បីទើបនឹងបួសបាន១ថ្ងៃ តែជាភិក្ខុអង់អាចឆ្លៀវឆ្លាស ពោលភាសាបាលីត្រឹមត្រូវ ស្ទាត់រត់មាត់ ដូចមានបាលីក្នុងគម្ពីរមហាវគ្គថា

អនុជានាមិ ភិក្ខវេ ព្យត្តេន ភិក្ខុនា បដិពលេន អនុសាវេតុំ ប្រែថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលឆ្លៀវឆ្លាសប្រតិពល សូធ្យប្រៀនប្រដៅឧបសម្បទាបេក្ខបុគ្គលបាន ។



www.elibraryofcambodia.org

ឯពាក្យថា ឆៀវឈ្លាសនោះ គឺសំដៅយកភិក្ខុណាដែលចេះដឹងអន្តរាយិកធម៌ ១ ចេះដឹងទីឆ្ងាយគឺក្រៅហត្ថបាស និងទីជិតគឺក្នុងហត្ថបាស ១ គួរដល់កូនសិស្សប្រើបាន១ គួរដល់ទីតាំងជាគ្រូគេ១ ចេះដឹងឋានករណៈ សិថិល ធនិត ទីឃៈ និងរស្សៈ ជាដើម ១ គួរឱ្យគេស្តាប់បង្គាប់ ១ មានសំឡេងស្ទាវស្រួលបួល១ ភិក្ខុនោះ ឈ្មោះថាជាអ្នកឆៀវឈ្លាសវៀងវៃ ។

ឯពាក្យថា ប្រតិពលនោះ គឺអង់អាច សំដៅយកភិក្ខុដែលជាអ្នកសូត្រ មិនបានចាស់ជរាទុព្វលភាព ១ អាចសូត្រប្រដៅ នូវអន្តរាយិកធម៌ ១ អាចសូត្រប្រៀនប្រដៅ នូវវិធីនៃអក្ខរៈមានឋានករណៈ និងធនិតជាដើម ១ មានសំឡេងស្អាតប្រាសចាកស្អួស្អាជាដើម ១ មានពាក្យសម្តីពោលច្បាស់លាស់ ១ ជាភិក្ខុអង់អាចចេះដឹង នូវបទព្យញ្ជនៈនិងអក្ខរៈទាំងឡាយ ១ អាចពោលនូវបទព្យញ្ជនៈនិងអក្ខរៈទាំងឡាយដោយសំឡេងដ៏ពីរោះ ១ អាចពោលឱ្យត្រូវតាមឋានករណៈសិថិល និងធនិតជាដើម ១ ភិក្ខុនោះ ឈ្មោះថាជាអ្នកអង់អាច ។

ភិក្ខុដែលឆៀវឈ្លាសអង់អាច ចេះចាំស្ទាត់ដូចបានអធិប្បាយមកនេះ ទើបគួរនឹងសន្មតឱ្យធ្វើជាគ្រូសូត្រ សូត្រកម្មវាចាបាន ។

ចប់ កម្មវាចាចារិយវិធី

## ទី ៤ បព្វជ្ជាវិធី

វិធីដែលនឹងបំបួសកុលបុត្រ ជាសាមណេរ ។

វិធីដែលនឹងបំបួសកុលបុត្រជាសាមណេរនោះ គប្បីឱ្យកោរសក់និងពុកមាត់ពុកចង្កា កាត់ក្រចក ឱ្យត្រឹមត្រូវតាមវិនយបញ្ញត្តិ ហើយស្លៀកដណ្តប់តាម

អហំ ភន្តេ បព្វជ្ជំ យាចាមិ ។ល។ តតិយម្បិ អហំ ភន្តេ បព្វជ្ជំ យាចាមិ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាសូមនូវបព្វជ្ជា ។ល។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាសូមនូវបព្វជ្ជា ជាគម្រប់៣ដងផង ។ ហើយពោលផ្ទេះតទៅទៀតថា

សព្វទុក្ខ និស្សរណ និព្វាន សច្ឆិករណត្ថាយ ឥមំ កាសាវំ គហេត្វា, បព្វាជេថ មំ ភន្តេ; អនុកម្បំ ឧបាទាយ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មេត្តាប្រោស ទទួលយកនូវសំពត់កាសាវៈនេះ ហើយធ្វើនូវសេចក្តីអនុគ្រោះបំបួសខ្ញុំព្រះករុណា ដើម្បីប្រយោជន៍ នឹង ធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលជាធម៌រលាស់នូវខ្លួនចេញចាកទុក្ខទាំងពួង ។

លុះបព្វជ្ជាបេក្ខៈ ពោលផ្ទេះ៣ដងរួចហើយ ព្រះឧបជ្ឈាយ៍ត្រូវទទួលយកនូវសំពត់កាសាវៈនោះអំពីដៃបព្វជ្ជាបេក្ខៈ ហើយទើបបព្វជ្ជាបេក្ខៈពោលផ្ទេះ ៣ ដងតទៅទៀតថា

សព្វទុក្ខ និស្សរណ និព្វាន សច្ឆិករណត្ថាយ ឯតំ កាសាវំ ទត្វា បព្វាជេថ មំ ភន្តេ អនុកម្បំ ឧបាទាយ។ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មេត្តាប្រោស ឱ្យនូវសំពត់កាសាវៈនុះដល់ខ្ញុំព្រះករុណា ហើយធ្វើនូវសេចក្តីអនុគ្រោះ បំបួសខ្ញុំព្រះករុណា ដើម្បីប្រយោជន៍នឹងធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលជាធម៌រលាស់នូវខ្លួនចេញចាកទុក្ខទាំងពួង ។



www.elibraryofcambodia.org

លុះបព្វជ្ជាបេក្ខៈពោលឲ្យរួចហើយ ទើបព្រះឧបជ្ឈាយ៍ ប្រគល់ទូរសំពត់កាសាវៈនោះឲ្យមកវិញ ហើយប្រាប់ **តចបញ្ចកកម្មដ្ឋាន** ជាអនុលោមបដិលោម ( បណ្តោយៈច្រាស ) ដោយបាលីថា

**កេសា លោមា នខា ទន្តា តចោ ; តចោ ទន្តា នខា លោមា កេសា ។** ប្រែថា សក់ រោម ក្រចក ធ្មេញ ស្បែក; ស្បែក ធ្មេញ ក្រចក រោម សក់ ។

កិច្ចនេះត្រូវព្រះឧបជ្ឈាយ៍ ប្រាប់សេចក្តីអធិប្បាយ ក្នុង **កាយគតាសតិកម្មដ្ឋាន** ឲ្យឃើញថា ជារបស់បដិកូលដោយល្អិត ឲ្យបព្វជ្ជាបេក្ខៈស្តាប់បានចូលចិត្តតាមពុទ្ធានុញ្ញាត ។

កាលបើព្រះឧបជ្ឈាយ៍ប្រាប់ **តចបញ្ចកកម្មដ្ឋាន** រួចហើយ ត្រូវឲ្យបព្វជ្ជាបេក្ខៈក្រោកឡើង ដើរត្រឡប់ចេញមក ហើយឲ្យផ្លាស់គ្រឿងស្លៀកដណ្តប់ជាយរាវាសចេញក្នុងទីសមគួរមួយ ហើយឲ្យស្លៀកស្បង់គ្រងចីវរជាបរិមណ្ឌលតាមសេខិយវត្ត ។

ឯកិច្ចដែលស្លៀកស្បង់នោះ ត្រូវស្លៀកឲ្យមានបរិមណ្ឌល ៣ គឺ ខាងលើបិទបាំងមណ្ឌលផ្ចិត ១ ខាងក្រោមឲ្យស្រុងចុះក្រោមជង្គង់ ៨ ធ្នាប់ ១ ឲ្យស្មើមុខស្មើក្រោយហើយត្រូវវាត់វត្ថពន្ធចង្កេះឲ្យខ្ជាប់ ១ ។

គ្រងចីវរត្រូវរំកាញ់ឲ្យមានផ្នត់ គ្រងឲ្យស្រុងចុះក្រោម កុំឲ្យស្មើនឹងស្បង់ ទុកឲ្យសល់សម្រុងស្បង់ ៤ ធ្នាប់ សម្រុងចីវរខាងក្រោមនោះឲ្យត្រឹម ស្មើមុខស្មើក្រោយឲ្យមានជាយខាងមុខព័ទ្ធទៅ ឲ្យជួបនឹងផ្នត់ខាងក្រោយ រួចយកសង្ឃាដីមកពាក់លើស្មាខាងឆ្វេង ហើយត្រូវវាត់វត្ថពន្ធទ្រូង ឲ្យចុះខាងក្រោមដោះ ១ ធ្នាប់ ២ ធ្នាប់ ៣ ធ្នាប់ ៤ ធ្នាប់ ក៏បាន ដើម្បីនឹងរក្សាបរិមណ្ឌលចីវរ កុំឲ្យរយីករយាក លុះគ្រងចីវរស្រេចហើយ ត្រូវកាន់យកគ្រឿងសក្ការៈ មានទៀនធូប

ជាដើម ចូលទៅកាន់សំណាក់ព្រះឧបជ្ឈាយ៍ ឬបព្វជ្ជាចារ្យ ប្រគេនគ្រឿងសក្ការៈនោះទៅលោក ហើយថ្វាយបង្គំរួចក្រោកឈរឡើង ប្រណម្យអញ្ជលីពោលថា

**ឱកាស! វន្ទាមិ ភន្តេ ។ល។ សាធុ សាធុ អនុមោទាមិ ។** ( សេចក្ដីប្រែដូចមុន ) រួចហើយពោលដូច្នេះ តទៅទៀត ថា

**ឱកាស! ការុញ្ញំ កត្វា តិសរណេន សហ សីលានិ ទេថ មេ ភន្តេ ។** សូមទានគោរព បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មេត្តាប្រោស ធ្វើនូវសេចក្ដីករុណាឱ្យសីលទាំងឡាយ ព្រមទាំងព្រះត្រៃសរណគមន៍ ដល់ខ្ញុំព្រះករុណា ។ ហើយអង្គុយច្រហោងផ្គងអញ្ជលីឡើងពោលដូច្នេះតទៅទៀតថា **អហំ ភន្តេ សរណសីលំ យាចាមិ** បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាសូមនូវព្រះត្រៃសរណគមន៍និងសីល ។

ទុតិ / តតិ } **យម្បិ**

**អហំ ភន្តេ សរណសីលំ យាចាមិ** បពិត្រលោកម្ចាស់ដ៏ចម្រើន

ខ្ញុំព្រះករុណាសូមនូវព្រះត្រៃសរណគមន៍និងសីល ជាគម្រប់ ២ / ៣ } ដងផង ។

ហើយតាំងនមោ ៣ ដង ថា **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។** កិរិយានមស្ការថ្វាយបង្គំ នៃខ្ញុំព្រះករុណា សូមមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកសេចក្ដីសៅហ្មងហើយ ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយព្រះអង្គឯងដោយប្រពៃ ។

ទើបព្រះឧបជ្ឈាយ៍ ឬឧបជ្ឈាចារ្យ លោកតាំងនមោ ៣ ដងរួចហើយពោល

ថា **យមហំ វទាមិ, តំ វទេហិ** យើងពោលនូវពាក្យឯណា

អ្នកចូរពោលនូវពាក្យនោះ ។ បព្វជ្ជាបេក្ខៈ ត្រូវទទួលថា **អាម ភន្តេ** ករុណា

លោកម្ចាស់ ( ខ្ញុំព្រះករុណានឹងពោលតាម ) ។ ហើយលោកឲ្យព្រះត្រៃ-

សរណគមន៍ថា

**ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹក

**ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរលឹក

**សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរលឹក។

**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹង ទីរលឹក ជាគម្រប់ ២ ដងផង **ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹងទីរលឹក ជាគម្រប់ ២ ដងផង **ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹងទីរលឹក ជាគម្រប់ ២ ដងផង ។

**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរលឹក ជាគម្រប់៣ដងផង **តតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹងទីរលឹក ជាគម្រប់៣ដងផង។ **តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹងទីរលឹក ជាគម្រប់៣ដងផង ។



www.elibraryofcambodia.org

វិធីដែលនឹងឲ្យព្រះត្រៃសរណគមន៍នេះ ឲ្យជាអនុនាសិកន្តៈ ជាឯកសម្ពន្ធ ដូច្នេះក៏បាន និងឲ្យមការន្តៈក៏បាន ឬនិងឲ្យទាំងអនុនាសិកន្តៈ និងមការន្តៈ ទាំង២យ៉ាងក៏បាន ដើម្បីឲ្យមាំមួន ។

វិធីដែលនឹងឲ្យជាមការន្តៈនោះ ត្រូវឲ្យឬយបទម្តង ៗ ដូច្នេះថា

ពុទ្ធំ សរណំ គច្ឆាមិ ធម្មំ សរណំ គច្ឆាមិ សង្ឃំ សរណំ គច្ឆាមិ ។ ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ។ តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ តតិយម្បិ ធម្មំ សរណំ គច្ឆាមិ តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ។

( សេចក្តីប្រែដូចមុន ) ហើយលោកពោលថា តិសរណគមនំ នេះជាកិច្ចផល់នូវព្រះត្រៃសរណគមន៍ (ឬថា) តិសរណគ្គហណំ បរិបុណ្ណំ កិរិយាកាន់យកគឺ ទទួលនូវព្រះត្រៃ សរណគមន៍ បរិបូណ៌ហើយ ។ សាមណេរត្រូវទទួលថា អាម ភន្តេ ករុណាលោកម្ចាស់ ។ ( ហើយក្រាបចុះម្តង ) រួចហើយទទួលសិក្ខាបទ១០តទៅទៀតថា

បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ។ល។ ជាតរូប រជតប្បដិគ្គហណា វេរមណី សិក្ខាបទំ សមាទិយាមិ ។

( សេចក្តីប្រែនោះ ដូចមានក្នុងសាមណេរវិន័យ ដែលបានបោះពុម្ពផ្សាយទៅសព្វគ្រប់ហើយ ) ។ ហើយលោកពោលដូច្នេះថា

ឥមានិ ទស សិក្ខាបទានិ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទទាំង១០នេះ ។ សាមណេរត្រូវទទួលតាម៣ដង ( ហើយក្រាបចុះម្តង ) ក្រោកឈរឡើងប្រណម្យអញ្ជលី ពោលថា

វន្ទាមិ ភន្តេ ។ល។ សាធុ សាធុ អនុមោទាមិ ។

( សេចក្តីប្រែដូចមុន ) ហើយក្រាបថ្វាយបង្គំ៣ដង ។

ចប់បព្វជ្ជាវិធីតែប៉ុណ្ណេះ

## ទី ៥ ឧបជ្ឈាយគ្គហណវិធី

### វិធីនៃការកាន់យកនូវព្រះឧបជ្ឈាយ៍

វិធីនៃបព្វជ្ជាបេក្ខៈ ដែលបានទទួលនូវព្រះត្រៃសរណគមន៍ត្រឹមត្រូវតាមពុទ្ធានុញ្ញាត បានឡើងបព្វជ្ជាៈពេញបរិបូណ៌ ជាសាមណេររួចហើយ ត្រូវឲ្យកាន់យកនូវព្រះឧបជ្ឈាយ៍ ( គឺសូមនិស្ស័យ ) ។

ឯកិច្ចដែលនឹងកាន់យកនូវព្រះឧបជ្ឈាយ៍នោះ គឺត្រូវឲ្យសាមណេរកាន់យកនូវគ្រឿងសក្ការៈ មានធូបទៀនផ្កាជាដើម ចូលទៅកាន់សំណាក់ព្រះឧបជ្ឈាយ៍ ហើយប្រគេននូវគ្រឿងសក្ការៈនោះទៅលោក រួចធ្វើអភិវាទនកម្មថ្វាយបង្គំដោយគោរព ហើយក្រោកឈរឡើងប្រណម្យអញ្ជលី ពោលដូច្នេះថា

ឧកាស វន្ទាមិ ភន្តេ ។ល។ សាធុ សាធុ អនុមោទាមិ ។

( សេចក្តីប្រែដូចមុន ) ហើយពោលដូច្នេះថា

ឧកាស ការុញ្ញំ កត្វា និស្សយំ ទេថ មេ ភន្តេ

សូមទានគោរព បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មេត្តាប្រោសធ្វើនូវសេចក្តីករុណាឲ្យនូវនិស្ស័យ គឺទីនៅអាស្រ័យដល់ខ្ញុំព្រះករុណា ។ ហើយអង្គុយច្រហោងផ្គងអញ្ជលីឡើង ពោលដូច្នេះថា

www.elibraryofcambodia.org

អហំ ភន្តេ និស្សយំ យាចាមិ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវនិស្ស័យ ។

ទុតិយម្បិ / តតិយម្បិ អហំ ភន្តេ និស្សយំ យាចាមិ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវនិស្ស័យជាគម្រប់ ២ / ៣ ដងផង ។

ក្រោយចុះម្តង រួចអង្គុយច្រហោងឡើងវិញ ពោលពាក្យថ្វេះ៣ដងតទៅទៀតថា

ឧបជ្ឈាយោ មេ ភន្តេ ហោហិ បពិត្រលោកម្ចាស់ ដ៏ចម្រើន សូមលោកម្ចាស់ជាព្រះឧបជ្ឈាយ៍ នៃខ្ញុំព្រះករុណា ។

ហើយព្រះឧបជ្ឈាយ៍លោកពោលតប ពាក្យថ្វេះថា សាធុ អ្នកប្រព្រឹត្តនេះ ជាការសម្រេចប្រយោជន៍ល្អក្នុងព្រះពុទ្ធសាសនាហើយ (ឬលោកថា) លហុ អ្នកប្រព្រឹត្តនេះ ជាកិច្ចស្រាល គឺថាជាការចិញ្ចឹមជីវិតងាយក្នុងព្រះពុទ្ធសាសនាហើយ (ឬលោកថា) ឱបាយិកំ អ្នកប្រព្រឹត្តនេះ ប្រកបដោយឧបាយជាទីរលាស់ នូវខ្លួនចេញចាកសង្សារទុក្ខហើយ (ឬលោកថា) បដិរូបំ អ្នកសូមនូវព្រះឧបជ្ឈាយ៍នេះ ជាកិច្ចដ៏សមគួរ ដល់សេចក្តីកោតក្រែង តាមបវេណីធម៌ហើយ (ឬលោកថា) បាសាទិកេន សម្បាទេហិ អ្នកចូរញ៉ាំងវត្តជុំ ៣ នៃសិក្ខា មានអធិសីលសិក្ខាជាដើម ឱ្យសម្រេចល្អដោយសេចក្តីជ្រះថ្លាចុះ ។

ក្នុងបទទាំង៥នេះ ព្រះឧបជ្ឈាយ៍ នឹងពោលតប ដោយបទណាមួយក៏បាន តែត្រូវពោលឱ្យគ្រប់បីដង។ ត្រង់បទទី១ សាមណេរត្រូវទទួលថា ឧកាស សម្បដិច្ឆាមិ សូមទានគោរពខ្ញុំព្រះករុណាសូមទទួលព្រមតាម ដោយគោរព ។ ត្រង់បទពីរដងបន្ទាប់ ត្រូវថាតែត្រឹម សម្បដិច្ឆាមិ ។ ហើយសាមណេរត្រូវពោលពាក្យថ្វេះ ៣ ដង តទៅទៀតថា



www.elibraryofcambodia.org

អជ្ជតគ្គេ ទានិ, ថេរោ មយ្ហំ ភារោ, អហម្បិ ថេរស្ស ភារោ តាំងពីថ្ងៃនេះជាដើមទៅ ព្រះថេរៈជាភារៈនៃខ្ញុំព្រះករុណា គឺភារៈក្នុងកិច្ចដែលខ្ញុំព្រះករុណា គប្បីធ្វើវត្តប្រតិបត្តិគោរពក្រែងជានិច្ច ចំណែកខាងខ្ញុំព្រះករុណា ក៏ជាភារៈនៃព្រះថេរៈ គឺភារៈក្នុងកិច្ចដែលលោកម្ចាស់ គប្បីរំលឹកដាស់តឿនប្រៀនប្រដៅខ្ញុំព្រះករុណាជានិច្ច ។ ទទួលថ្វាយបង្គំចុះ ៣ ដង ។

ចប់ ឧបជ្ឈាយគ្គហណវិធី តែប៉ុណ្ណេះ

## ទី ៦ ឧបសម្បទាវិធី

### វិធីឲ្យឧបសម្បទា

សាមណេរដែលសុំឡើងយក ឧបសម្បទានោះ គឺ ត្រូវស្ពាយបាត្រ ក្រោកឈរឡើង ហើយចូលមកដល់កណ្តាលការកសង្ឃ ស្ថិតត្រង់ទីចំពោះមុខព្រះឧបជ្ឈាយ៍ ទើបព្រះឧបសម្បទាចារ្យ គឺ គ្រូសូត្រឲ្យផ្លាស់បកតិនាមដែលមិនសមគួរតាមភាសាបាលី ហើយសន្មតឲ្យឈ្មោះថា តំខណិកនាម វិញថា

ត្វំ នាគោ នាម អ្នកឈ្មោះនាគ ។ ឧបសម្បទាបេក្ខៈ ត្រូវទទួលថា ឧកាស អាម ភន្តេ ។ ហើយព្រះឧបសម្បទាចារ្យ សន្មតនាម ព្រះឧបជ្ឈាយ៍ជា តំខណិកនាម ថា

តុយ្ហំ ឧបជ្ឈាយោ អាយស្មា តិស្សត្ថេរោ នាម ព្រះឧបជ្ឈាយ៍របស់អ្នកឈ្មោះ តិស្សត្ថេរ ដ៏មានអាយុ ។ ឧបសម្បទា-បេក្ខៈ ត្រូវទទួលថា ឧកាស អាម ភន្តេ ។ ( ប្រែដូចមុន ) ។



www.elibraryofcambodia.org

កិច្ចដែលសន្មតឈ្មោះ នាគៈ តិស្សៈ ដែលហៅថា គំខណិតនាម នេះ ឧបសម្បទាចារ្យត្រូវបញ្ចេញវចីភេទឱ្យព្រះឧបជ្ឈាយ៍ និង ការកសង្ឃឮច្បាស់ប្រាកដ ហើយគប្បីអធិប្បាយអំពីឈ្មោះទាំង ២ គឺ នាគនាម និង តិស្សនាម ពន្យល់ឱ្យឧបសម្បទាបេក្ខៈចូលចិត្តដោយសេចក្តីល្អិតជ្រាលជ្រៅតាមបាលី និង អដ្ឋកថា ដីកា ហើយឧបសម្បទាចារ្យសូត្រនមស្ការ ៣ ដងថា

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

រួចហើយសូត្រដូច្នេះថា

បឋមំ ឧបជ្ឈំ គាហាបេតព្វោ ឧបជ្ឈំ គាហាបេត្វា បត្តចីវរំ អាចិក្ខិតព្វំ ( ប្រែថា ) អាចារ្យគប្បីឱ្យឧបសម្បទាបេក្ខៈ ពីសាមណេរអ្នកសំឡឹងយកនូវឧបសម្បទា ទទួលកាន់បេកនូវព្រះឧបជ្ឈាយ៍ជាមុន លុះឱ្យទទួលកាន់យកនូវព្រះឧបជ្ឈាយ៍ស្រេចហើយ គប្បីប្រាប់នូវបាត្រ និងចីវរថា អយន្តេ បត្តោ នេះបាត្ររបស់អ្នក ។ ឧបសម្បទាបេក្ខៈ ត្រូវទទួលថា អាម ភន្តេ ករុណាលោកម្ចាស់ ។ អយំ សង្ឃាដិ នេះ សង្ឃាដីរបស់អ្នក ។ ទទួលថា អាម ភន្តេ ករុណាលោកម្ចាស់ ។ អយំ ឧត្តរាសង្គោ នេះចីពររបស់អ្នក ។ ទទួលថា អាម ភន្តេ ករុណាលោកម្ចាស់ ។ អយំ អន្តរវាសកោ នេះស្បង់របស់អ្នក ។ ទទួលថា អាម ភន្តេ ករុណាលោកម្ចាស់ ។ គច្ឆ អមុម្ហិ ឱកាសេ តិដ្ឋាហិ អ្នកចូរចេញទៅឈរក្នុងទីឱកាសឯណោះទៅ ។ ឧបសម្បទាបេក្ខៈ ត្រូវថយចេញទៅឱ្យផុតហត្ថបាសការកសង្ឃ ហើយឈរប្រណម្យអញ្ជលី រួចឧបសម្បទា-ចារ្យសូត្រប្រកាសសង្ឃថា


www.elibraryofcambodia.org

សុណាតុ មេ ភន្តេ សង្ឃោ នាគោ អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខោ យទិ សង្ឃស្ស បត្តកល្លំ អហំ នាគំ អនុសាសេយ្យំ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ ដ្បិតសាមណេរឈ្មោះនាគ ( ជាសទ្ធិវិហារិក ) នៃព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុ ជាអ្នកប្រាថ្នាយកនូវឧបសម្បទា បើឧបសម្បទាកម្មនេះជាបត្តកល្លៈ គឺមានកាលដ៏សមគួរដល់ការកសង្ឃហើយ ខ្ញុំគប្បីប្រៀនប្រដៅនូវសាមណេរឈ្មោះនាគ ( ឲ្យដឹងជាមុន ) ។

លុះសូធ្យប្រកាសសង្ឃស្រេចហើយ ទើបលោកចេញទៅឈរចំពោះមុខជិតគ្នានឹងនាគហើយ លោកសូធ្យប្រៀនប្រដៅថា

សុណាសិ នាគ អយន្តេ សច្ចកាលោ ភូតកាលោ នែអ្នកនាគ អ្នកចូរស្តាប់ កាលនេះ ជាកាលពិត ជាកាលគួរដល់អ្នកហើយ យំ ជាតំ តំ សង្ឃមជ្ឈេ បុច្ឆន្តេ របស់ឯណាដែលកើតមានហើយ កាលបើយើងសួរចំពោះត្រង់របស់នោះ ក្នុងកណ្តាលការកសង្ឃ សន្តំ អត្ថីតិ វត្តព្វំ អសន្តំ នត្ថីតិ វត្តព្វំ របស់ដែលបាន អ្នកគប្បីប្រាប់ថាមានរបស់ដែលមិនមានអ្នកគប្បីប្រាប់ថា មិនមាន មា ខោ វិត្ថាសិ មា ខោ មង្កុ អហោសិ អ្នកកុំអឹមអៀមឡើយ កុំអៀនខ្មាសឡើយ ឯវន្តំ បុច្ឆិស្សន្តិ សន្តិ តេ ឯវរូបា អាពាធា យើងនឹងសួរអ្នកដូច្នេះថា អាពាធទាំងឡាយមានសភាពយ៉ាងនេះអ្នកមានដែរឬ ? កុដ្ឋំ រោគឃ្លង់ ។ ទទួលថា នត្ថិ ភន្តេ មិនមានទេលោកម្ចាស់ ។ គណ្ឌោ ពកឬពួស ។ ទទួលថា នត្ថិ ភន្តេ មិនមានទេលោកម្ចាស់ ។ កិលាសោ រោគស្រែង ។

ទទួលថា នត្ថិ ភន្តេ មិនមានទេលោកម្ចាស់ ។ សោសោ រោគ ហិត ។ ទទួលថា នត្ថិ ភន្តេ មិនមានទេលោកម្ចាស់ ។ អបមារោ រោគឆ្កួតជ្រូក ។ ទទួលថា នត្ថិ ភន្តេ មិនមានទេលោកម្ចាស់ ។ មនុស្សោសិ អ្នកជាមនុស្សឬ? ទទួលថា អាម ភន្តេ ករុណាលោកម្ចាស់ ។ បុរិសោសិ អ្នកជាប្រុសឬ? ទទួលថា អាម ភន្តេ ករុណាលោកម្ចាស់ ។ ភុជិស្សោសិ អ្នកជាអ្នកជាទេឬ? ទទួលថា អាម ភន្តេ ករុណាលោកម្ចាស់ ។ អននណោសិ អ្នកមិនជំពាក់បំណុលគេឬទេ? ទទួលថា អាម ភន្តេ ករុណាលោកម្ចាស់ ។ នសិ រាជភដោ អ្នកមិនមែនជាខ្ញុំរាជការទេឬ? ទទួលថា អាម ភន្តេ ករុណាលោកម្ចាស់ ។ អនុញ្ញាតោសិ មាតាបិតូហិ អ្នកគឺមាតាបិតាបានអនុញ្ញាតហើយឬ? ទទួលថា អាម ភន្តេ ករុណាលោកម្ចាស់ ។ បរិបុណ្ណវីសតិវស្សោសិ អ្នកមានអាយុគ្រប់២០ឆ្នាំហើយឬ? ទទួលថា អាម ភន្តេ ករុណាលោកម្ចាស់ ។ បរិបុណ្ណន្តេ បត្តចីវរំ បាត្រនិងចីវររបស់អ្នកគ្រប់គ្រាន់ហើយឬ? ទទួលថា អាម ភន្តេ ករុណាលោកម្ចាស់ ។ កិន្នាមោសិ អ្នកឈ្មោះអ្វី ? ទទួលថា អហំ ភន្តេ នាគោ នាម បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាឈ្មោះនាគ។ កោ នាមោ តេ ឧបជ្ឈាយោ ព្រះឧបជ្ឈាយ៍របស់អ្នកឈ្មោះអ្វី ? ទទួលថា ឧបជ្ឈាយោ មេ ភន្តេ អាយស្មា តិស្សត្ថេរោ នាម បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះឧបជ្ឈាយ៍របស់ខ្ញុំព្រះករុណា ឈ្មោះតិស្សត្ថេរដ៏មានអាយុ ។

លុះសូត្រប្រៀនប្រដៅនាគរួចហើយ ទើបព្រះឧបសម្បទាចារ្យត្រឡប់ចូលមកក្នុងកណ្ដាលការកសង្ឃវិញហើយសូត្រប្រកាសសង្ឃ និងហៅនាគឡើងចូល មកថា

សុណាតុ មេ ភន្តេ សង្ឃោ នាគោ អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខោ អនុសិដ្ឋោ សោ មយា យទិ សង្ឃស្ស បត្តកល្លំ នាគោ អាគច្ឆេយ្យ អាគច្ឆាហីតិ វត្តព្វោ,[១] អាគច្ឆាហិ ។ បពិត្រព្រះសង្ឃដ៏ចម្រើន ព្រះសង្ឃចូរស្តាប់ខ្ញុំ ផ្សិតសាមណេរឈ្មោះនាគ ( ជាសទ្ធិវិហារិក ) នៃព្រះថេរៈឈ្មោះតិស្សៈ ដ៏មានអាយុជាអ្នកសំឡឹងយកនូវឧបសម្បទា សាមណេរឈ្មោះនាគនោះ ខ្ញុំព្រះករុណាបានប្រៀនប្រដៅហើយ បើ (ឧបសម្បទាកម្មនេះ) ជាបត្តកល្លៈ មានកាលដ៏សមគួរដល់ការកសង្ឃហើយ សាមណេរឈ្មោះនាគគប្បីចូលមក សាមណេរឈ្មោះនាគនោះ ខ្ញុំព្រះករុណាគប្បីពោលថា ឱ្យចូលមក អ្នកចូរមកចុះ ។

សាមណេរឈ្មោះនាគ ត្រូវដើរចូលមកអង្គុយក្នុងកណ្តាលការកសង្ឃ ត្រង់ទីចំពោះព្រះឧបជ្ឈាយ៍ ធ្វើអភិវាទនកម្មថ្វាយបង្គំព្រះឧបជ្ឈាយ៍ ឧបសម្បទាចារ្យ និងការកសង្ឃ រួចហើយត្រូវអង្គុយច្រហោងប្រណម្យអញ្ជលី សូមឧបសម្បទាចំពោះនឹងការកសង្ឃ ដោយបញ្ចេញវចីភេទថា

សង្ឃម្ភន្តេ ឧបសម្បទំ យាចាមិ ឧល្លុម្បតុ មំ ភន្តេ សង្ឃោ អនុកម្បំ ឧបាទាយ បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាសូមនូវឧបសម្បទានឹងព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃអាស្រ័យនូវសេចក្តីអនុគ្រោះ លើកខ្ញុំព្រះករុណាឡើង ឱ្យផុតចាកភេទជាសាមណេរហើយតម្កល់នៅក្នុងភេទជាភិក្ខុភាវៈ ។

ទុតិយម្បិ ភន្តេ សង្ឃំ ឧបសម្បទំ យាចាមិ ឧល្លុម្បតុ មំ ភន្តេ សង្ឃោ អនុកម្បំ ឧបាទាយ បពិត្រព្រះសង្ឃដ៏ចម្រើនខ្ញុំព្រះករុណាសូមនូវឧបសម្បទា នឹងព្រះសង្ឃជាគម្រប់ពីរដងផង បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃ ។ល។ ជាភិក្ខុភាវៈ ។

---

១ - ដល់មកត្រង់នេះ គួរឈប់បង្អង់ឱ្យយូរបន្តិច ហើយសឹមថា អាគច្ឆាហិ ( តាមសំណើរសេចក្តីនេះ ) ។



www.elibraryofcambodia.org

តតិយម្បិ ភន្តេ សង្ឃំ ឧបសម្បទំ យាចាមិ, ឧល្លុម្បតុ មំ ភន្តេ,សង្ឃោ អនុកម្បំ ឧបាទាយ បពិត្រព្រះសង្ឃដ៏ចម្រើនខ្ញុំព្រះករុណាសូមនូវឧបសម្បទានឹងព្រះសង្ឃ ជាគម្រប់៣ដងផង បពិត្រព្រះសង្ឃដ៏ចម្រើន ។ល។ ជាតិក្ខុភាវៈ ។

កាលបើ ឧបសម្បទាបេក្ខៈ សូមឧបសម្បទា នឹង ព្រះសង្ឃស្រេចហើយ ការកសង្ឃត្រូវអង្គុយពិទូ ចូលខ្សែដាប់ហត្ថបាសគ្នា ហើយទើបឧបសម្បទាចារ្យលោកសូធ្យស្វូរអន្តរាយិកធម៌ ក្នុងកណ្ដាលការកសង្ឃដូច្នេះថា

សុណាតុ មេ ភន្តេ សង្ឃោ, អយំ នាគោ អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខោ, យទិ សង្ឃស្ស បត្តកល្លំ, អហំ នាគំ អន្តរាយិកេ ធម្មេ បុច្ឆេយ្យំ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្ដាប់ខ្ញុំ ដ្បិតសាមណេរឈ្មោះនាគនេះ (ជាសទ្ធិវិហារិក) នៃព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុ ជាអ្នកសុំឡើងយកនូវឧបសម្បទា បើ( ឧបសម្បទាកម្មនេះ ) ជាបត្តកល្លៈគឺមានកាលដ៏សមគួរដល់ព្រះសង្ឃហើយ ខ្ញុំព្រះករុណាគប្បីសួរនូវអន្តរាយិកធម៌ទាំងឡាយចំពោះសាមណេរឈ្មោះនាគនេះ ។

ហើយសូធ្យដូច្នេះតទៅទៀតថា

សុណាសិ នាគ, អយន្តេ សច្ចការលោ ភូតការលោ, (សេចក្ដីប្រែដូចមុន) យំ ជាតំ តំ បុច្ឆាមិ របស់ឯណាដែលកើតមានហើយ យើងសួរចំពោះរបស់នោះ សន្តំ អត្ថីតិ វត្តព្វំ, អសន្តំ នត្ថីតិ វត្តព្វំ ( សេចក្ដីប្រែដូចមុន ) សន្តិ តេ ឯវរូបា អាពាធា អាពាធទាំងឡាយមានសភាពយ៉ាងនេះ អ្នកមានដែរឬ ? កុដ្ឋំ រោគឃ្លង់។ នត្ថិ ភន្តេ មិនមានទេលោកម្ចាស់។ល។ ឧបជ្ឈាយោ មេ ភន្តេ អាយស្មា តិស្សត្ថេរោ នាម ( សេចក្ដីប្រែដូចមុន ) ។

លុះសូត្រសួរអន្តរាយិកធម៌ ក្នុងកណ្ដាលការកសង្ឃស្រេចហើយ ទើបលោកសូត្រ ញត្តិចតុត្ថកម្មវាចា តទៅទៀតថា

សុណាតុ មេ ភន្តេ សង្ឃោ, អយំ នាគោ អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខោ, បរិសុទ្ធោ អន្តរាយិកេហិ ធម្មេហិ បរិបុណ្ណស្ស បត្តចីវរំ, នាគោ សង្ឃំ ឧបសម្បទំ យាចតិ, អាយស្មតា តិស្សេន ឧបជ្ឈាយេន, យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ នាគំ ឧបសម្បាទេយ្យ, អាយស្មតា តិស្សេន ឧបជ្ឈាយេន ឯសា ញត្តិ ។ ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្ដាប់ខ្ញុំ ដ្បិតសាមណេរឈ្មោះនាគនេះ (ជាសទ្ធិវិហារិក) នៃព្រះថេរៈឈ្មោះតិស្សៈ ដ៏មានអាយុជាអ្នកសំឡឹងយកនូវឧបសម្បទា បរិសុទ្ធផុតចាក អន្តរាយិកធម៌ទាំងឡាយ ហើយបាត្រនិងចីវររបស់ (សាមណេរឈ្មោះនាគ) មានគ្រប់គ្រាន់ហើយ សាមណេរឈ្មោះនាគ មានព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុ ជាព្រះឧបជ្ឈាយ៍ មកសូមនូវឧបសម្បទាអំពីព្រះសង្ឃ បើ ( ឧបសម្បទាកម្មនេះ ) ជាបត្តកល្លៈ គឺមានកាលដ៏សមគួរដល់ព្រះសង្ឃ ហើយព្រះសង្ឃគប្បីញ៉ាំងសាមណេរឈ្មោះនាគមានព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុជាព្រះឧបជ្ឈាយ៍ ឲ្យបាននូវឧបសម្បទា វាចានេះជាវាចាសម្រាប់ញ៉ាំងសង្ឃឲ្យដឹង ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ នាគោ អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខោ, បរិសុទ្ធោ អន្តរាយិកេហិ ធម្មេហិ, បរិបុណ្ណស្ស បត្តចីវរំ, នាគោ សង្ឃំ ឧបសម្បទំ យាចតិ អាយស្មតា តិស្សេន ឧបជ្ឈាយេន សង្ឃោ នាគំ ឧបសម្បាទេតិ អាយស្មតា តិស្សេន ឧបជ្ឈាយេន យស្សាយស្មតោ ខមតិ នាគស្ស


www.elibraryofcambodia.org

ឧបសម្បទា អាយស្មតា តិស្សេន ឧបជ្ឈាយេន, សោ តុណ្ហស្ស. យស្ស នក្ខមតិ, សោ ភាសេយ្យ, ទុតិយម្បិ ឯតមត្ថំ វទាមិ ។ ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើន សូម ព្រះសង្ឃស្តាប់ខ្ញុំ ផ្សិតសាមណេរឈ្មោះនាគនេះ (ជាសទ្ធិវិហារិក) នៃព្រះថេរៈ ឈ្មោះតិស្សៈដ៏មានអាយុ ជាអ្នកសំឡឹងយកឧបសម្បទា បរិសុទ្ធចាកអន្តរាយិក-ធម៌ទាំងឡាយហើយ បាត្រនិងចីវររបស់ ( សាមណេរឈ្មោះនាគនេះ ) មាន គ្រប់គ្រាន់ហើយសាមណេរឈ្មោះនាគ មានព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុជា ព្រះឧបជ្ឈាយ៍មកសូមនូវឧបសម្បទានឹងព្រះសង្ឃ ព្រះសង្ឃក៏បានញុំាងសាមណេរ ឈ្មោះនាគ មានព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុ ឲ្យបាននូវឧបសម្បទា ការ ដែលឲ្យនូវឧបសម្បទា ដល់សាមណេរឈ្មោះនាគ មានព្រះថេរៈឈ្មោះ តិស្សៈ ដ៏មានអាយុជាព្រះឧបជ្ឈាយ៍ (នេះ) គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម បើមិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង ខ្ញុំព្រះករុណាពោលនូវសេចក្ដីនេះ ជាគម្រប់២ដងផង ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ នាគោ អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខោ បរិសុទ្ធោ អន្តរាយិកេហិ ធម្មេហិ បរិបុណ្ណស្ស បត្តចីវរំ នាគោ សង្ឃំ ឧបសម្បទំ យាចតិ អាយស្មតា តិស្សេន ឧបជ្ឈាយេន សង្ឃោ នាគំ ឧបសម្បាទេតិ អាយស្មតា តិស្សេន ឧបជ្ឈាយេន យស្សាយស្មតោ ខមតិ នាគស្ស ឧបសម្បទា អាយស្មតា តិស្សេន ឧបជ្ឈាយេន សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ, តតិយម្បិ ឯតមត្ថំ វទាមិ ។ ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើន ។ ល ។ ខ្ញុំព្រះករុណា ពោលនូវសេចក្ដីនេះ ជាគម្រប់ បី ដងផង ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ នាគោ អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខោ បរិសុទ្ធោ អន្តរាយិកេហិ ធម្មេហិ បរិបុណ្ណស្ស បត្តចីវរំ នាគោ សង្ឃំ ឧបសម្បទំ យាចតិ អាយស្មតា តិស្សេន ឧបជ្ឈាយេន សង្ឃោ នាគំ ឧបសម្បាទេតិ, អាយស្មតា តិស្សេន ឧបជ្ឈាយេន, យស្សាយស្មតោ ខមតិ, នាគស្ស ឧបសម្បទា អាយស្មតា តិស្សេន ឧបជ្ឈាយេន, សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើន ។ល។ លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។

ឧបសម្បន្នោ សង្ឃេន នាគោ អាយស្មតា តិស្សេន ឧបជ្ឈាយេន, ខមតិ សង្ឃស្ស, តស្មា តុណ្ហី, ឯវមេតំ ធារយាមិ ។ ប្រែថា សាមណេរឈ្មោះនាគ ( នេះ ) មានព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុជាព្រះឧបជ្ឈាយ៍ គឺការកសង្ឃឲ្យបានឧបសម្បទាហើយ ( ការដែលឲ្យនូវឧបសម្បទាដល់សាមណេរឈ្មោះនាគ ( នេះ ) ជាការគួរដល់សង្ឃ ព្រោះហេតុនោះបានជាព្រះសង្ឃស្ងៀម ខ្ញុំព្រះករុណាសូមចាំទុកនូវសេចក្ដីនេះ ដោយអាការស្ងៀមដូច្នេះឯង ។

លុះចប់ញត្តិចតុត្ថកម្មវាចា ស្រេចក្នុងខណៈណា ឧបសម្បទាបេក្ខៈនោះ ក៏បានស្ថិតនៅក្នុងភិក្ខុភាវៈ គឺកើតជាភិក្ខុពេញបរិបូណ៌ក្នុងខណៈនោះ តាមពុទ្ធានុញ្ញាត។

ចប់ ឧបសម្បទាវិធីតែប៉ុណ្ណេះ ។

## ទី ៧ អនុសាសនវិធី

វិធីប្រៀនប្រដៅភិក្ខុ ដែលទើបនឹងបួសថ្មី ថ្មីនាគ ។

កាលបើចប់ញត្តិចតុត្ថកម្មវាចាស្រេចហើយ វិន័យធរ គឺព្រះឧបជ្ឈាយ៍ ឬកម្មវាចាចារ្យគប្បីប្រាប់ព្រមទាំងប្រៀនប្រដៅនវកភិក្ខុគឺភិក្ខុថ្មី ក្នុងលំដាប់បន្ទាប់អំពីឧបសម្បទាកម្មនោះ ដោយវិធីភេទថា

តាវទេវ ឆាយា មេតព្វា, ឧតុប្បមាណំ អាចិក្ខិតព្វំ, ទិវសភាគោ អាចិក្ខិតព្វោ, សង្គីតិ អាចិក្ខិតព្វា, ចត្តារោ និស្សយា អាចិក្ខិតព្វា, ចត្តារិ ច អករណីយានិ អាចិក្ខិតព្វានិ កិរិយាវាស់នូវស្រមោល (នៃសរីរៈនៃសត្វដោយបាទជើងទាំងឡាយ) វិន័យធរគប្បីប្រាប់នូវប្រមាណនៃរដូវ វិន័យធរគប្បីប្រាប់ចំណែកនៃថ្ងៃ វិន័យធរគប្បីប្រាប់សេចក្តីប្រៀនប្រដៅប្រមូលរួមនូវកិច្ចទាំង ៣ យ៉ាង គឺស្រមោលនៃសរីរៈ ១ ប្រមាណនៃរដូវ ១ ចំណែកនៃថ្ងៃ ១ វិន័យធរគប្បីប្រាប់និស្ស័យ គឺបច្ច័យដែលជាទីអាស្រ័យរបស់សមណៈ៤យ៉ាង វិន័យធរគប្បីប្រាប់ថ្យែងទៀត អករណីយកិច្ច គឺកិច្ចដែលសមណៈមិនត្រូវធ្វើ ៤យ៉ាង វិន័យធរគប្បីប្រាប់ថា

១- បិណ្ឌិយាលោបភោជនំ និស្សាយ បព្វជ្ជា តត្ថ តេ យាវជីវំ ឧស្សាហោ ករណីយោ ។ អ្នកបួសត្រូវអាស្រ័យនូវភោជនជាពំនូត ។ គឺអាហារមានប្រមាណ ១ វែក ២ វែក ជាដើម ដែលទាយកគេដាក់ក្នុងបាត្រ ដែលបានមកដោយកម្លាំងស្មង គឺដែលបានមកដោយដើរទៅបិណ្ឌបាត្រ សេចក្តីព្យាយាមក្នុងការបរិភោគ នូវបិណ្ឌិយាលោបភោជននោះ អ្នកគប្បីធ្វើសព្វៗ ថ្ងៃ ដរាបដល់អស់ជីវិត ។

អតិរេកលាភោ សង្ឃភត្តំ ឧទ្ទេសភត្តំ និមន្តនំ សលាកភត្តំ បក្ខិកំ ឧបោសថិកំ បាដិបទិកំ ។ ភត្តជាអតិរេកលាភ ៧ យ៉ាង គឺសង្ឃភត្ត ១ ឧទ្ទេសភត្ត ១ និមន្តនភត្ត ១ សលាកភត្ត ១ បក្ខិកភត្ត ១ ឧពោសថិកភត្ត ១ បាដិបទិកភត្ត ១ (ភត្តជាអតិរេកលាភទាំង៧យ៉ាងនេះ បើអ្នកបានហើយ អ្នកគប្បីបរិភោគ ដោយធម៌ចុះ ) ។ នវភិក្ខុត្រូវទទួលថា អាម ភន្តេ ករុណាលោកម្ចាស់ ។

២ បំសុកូលចីវរំ និស្សាយ បព្វជ្ជា តត្ថ តេ យាវជីវំ ឧស្សាហោ ករណីយោ ។ អ្នកបួសត្រូវ



www.elibraryofcambodia.org

អាស្រ័យនូវបំសុកូលចីវរ គឺសំពត់ដែលសៅហ្មងដោយអាចម៍ដី ដោយធូលី សេចក្តីព្យាយាមក្នុងការប្រើប្រាស់នូវសំពត់បំសុកូលចីវរនោះអ្នកគប្បីធ្វើរាបដល់អស់ជីវិត

**អតិរេកលាភោ ខោមំ កប្បាសិកំ កោសេយ្យំ កម្ពលំ សាណំ ភង្គំ ។** សំពត់ជាអតិរេកលាភ ៦ យ៉ាង គឺ សំពត់ដែលគេត្បាញដោយសរសៃឈើ ១ សំពត់ដែលគេត្បាញដោយអំបោះ ១ សំពត់ដែលគេត្បាញដោយសូត្រ ១ សំពត់ដែលគេត្បាញដោយរោមសត្វ ១ សំពត់ដែលគេត្បាញដោយសំបកធ្មៃ ១ សំពត់ដែលគេយករបស់ទាំង ៥ គឺសរសៃឈើ អំបោះ សូត្រ រោមសត្វ សំបកធ្មៃ មកលាយច្រឡំគ្នា ហើយត្បាញ ១ ( សំពត់ជាអតិរេកលាភទាំង ៦ យ៉ាងនេះ បើអ្នកបានហើយ អ្នកគប្បីប្រើប្រាស់ដោយធម៌ចុះ) ។ នវភិក្ខុត្រូវទទួលថា **អាម ភន្តេ** ករុណាលោកម្ចាស់ ។

**៣ រុក្ខមូលសេនាសនំ និស្សាយ បព្វជ្ជា តត្ថ តេ យាវជីវំ ឧស្សាហោ ករណីយោ ។** អ្នកបួសត្រូវអាស្រ័យនៅក្រោមម្លប់ឈើជាសេនាសនៈគឺ ទីដេក ទីអង្គុយសេចក្តីព្យាយាមក្នុងការអាស្រ័យ នូវរុក្ខមូលសេនាសនៈនោះ អ្នកគប្បីធ្វើរាបដល់អស់ជីវិត ។

**អតិរេកលាភោ វិហារោ អឌ្ឍយោគោ បាសាទោ ហម្មិយំ គុហា ។** សេនាសនៈជាអតិរេកលាភ ៥ យ៉ាង គឺទីអាវាសដែលបិទបាំងដោយរបង ឬ កំពែងព័ទ្ធជុំវិញ គឺទីវត្តទាំងមូល ១ ប្រាសាទមានសណ្ឋានវែង ឬ សណ្ឋានដូចជាខ្នងដំរី ឬ ក៏ដូចរូបគ្រុឌ ឬ សេនាសនៈដែលមានដំបូលតែម្ខាង គឺបង្ហារ ១ ប្រាសាទមានជ្រុង ៤ ហើយមានជាន់ច្រើន១ ប្រាសាទមានដំបូលរលីង គឺប្រាសាទប្រក់ប្លក ឬ ផ្ទះមានកំពូល១ គុហាដែលគេធ្វើដោយឥដ្ឋ ដោយថ្ម ដោយឈើ ដោយអាចម៍ដី ឬ គុហាដែលកើតឯងក្នុងភ្នំ ១ ( សេនាសនៈជាអតិរេកលាភទាំង ៥ យ៉ាងនេះ បើអ្នកបានហើយ អ្នកគប្បីអាស្រ័យដោយធម៌ចុះ ) ។ នវភិក្ខុត្រូវទទួលថា **អាម ភន្តេ** ករុណាលោកម្ចាស់ ។



www.elibraryofcambodia.org

៤- ឫតិមុត្តភេសជ្ជំ និស្សាយ បព្វជ្ជា តត្ថ តេ យាវ-ជីវំ, ឧស្សាហោ ករណីយោ ។ អ្នកបួស ត្រូវអាស្រ័យនូវទឹកមូត្រ គឺទឹកមូត្រគោ ជាថ្នាំរម្ងាប់រោគ សេចក្ដីព្យាយាម ក្នុងការអាស្រ័យនូវទឹកមូត្រនោះ អ្នកគប្បីធ្វើជារាបដល់អស់ជីវិត ។

អតិរេកលាភោ សប្បិ នវនីតំ តេលំ មធុ ផាណិតំ ភេសជ្ជៈជាអតិរេកលាភ ៥ យ៉ាង គឺទឹកដោះថ្លា ១ ទឹកដោះខាប់ ១ ប្រេង ១ ទឹកឃ្មុំ ១ ទឹកអំពៅ ១ ( ភេសជ្ជៈជាអតិរេកលាភទាំង ៥ យ៉ាងនេះ បើអ្នកបានហើយ អ្នកគប្បីអាស្រ័យដោយធម៌ចុះ ) ។ នវភិក្ខុត្រូវទទួលថា អាម ភន្តេ ករុណាលោកម្ចាស់ ។

អករណីយកិច្ច ៤ យ៉ាង វិន័យធរគប្បីប្រាប់ថា

១- ឧបសម្បន្នេន ភិក្ខុនា មេថុនោ ធម្មោ ន បដិ-សេវិតព្វោ អន្តមសោ តិរច្ឆានគតាយបិ ។ មេថុនធម្ម គឺភិក្ខុដែលបានឧបសម្បទាហើយ មិនត្រូវសេពឡើយ ដោយហោចទៅសូម្បីតែសត្វតិរច្ឆាន ក៏សេពពុំបាន ។ យោ ភិក្ខុ មេថុនំ ធម្មំ បដិសេវតិ អស្សមណោ ហោតិ អសក្យបុត្តិយោ ។ ភិក្ខុឯណាមួយសេពនូវមេថុនធម្ម ( ភិក្ខុនោះ ) មិនមែនជាសមណៈ មិនមែនជាសក្យបុត្រឡើយ ។ សេយ្យថាបិ នាម បុរិសោ សីសច្ឆិន្នោ អភព្វោ តេន សរីរពន្ធនេន ជីវិតុំ ឯវមេវ ភិក្ខុ មេថុនំ ធម្មំ បដិសេវិត្វា អស្សមណោ ហោតិ អសក្យបុត្តិយោ បុរសដែលមានក្បាលដាច់ហើយ មិនអាចដើម្បី នឹងរស់នៅ ដោយកិរិយាតភ្ជាប់

សភាវៈនោះបាន ដូចម្ដេចមិញ ភិក្ខុដែលសេពនូវមេថុនធម្មហើយ ក៏មិនមែនជាសមណៈមិនមែនសក្យបុត្រដូច្នោះឯង ។ ភន្តេ យាវជីវំ អករណីយំ អ្នកមិនត្រូវសេពមេថុនធម្មនោះ ដរាបដល់អស់ជីវិត ។ នវភិក្ខុត្រូវទទួលថា អាម ភន្តេ ករុណាលោកម្ចាស់

២- ឧបសម្បន្នេន ភិក្ខុនា អទិន្នំ ថេយ្យសង្ខាតំ ន អាទាតព្វំ អន្តមសោ តិណសលាកំ ឧបាទាយ ។ ភិក្ខុដែលបានឧបសម្បទាហើយ មិនត្រូវកាន់យកនូវទ្រព្យដែលគេមិនបានឲ្យដោយកាយ ឬដោយវាចា ដោយចំណែកនៃចិត្តលួចនោះឡើយ ដោយហោចទៅស្មៅតែស្នា១បាច់ ក៏យកពុំបាន ។ យោ ភិក្ខុ បាទំ វា បាទារហំ វា អតិរេកបាទំ វា អទិន្នំ ថេយ្យសង្ខាតំ អាទិយតិ អស្សមណោ ហោតិ អសក្យបុត្តិយោ ។ ភិក្ខុណាមួយកាន់យកវត្ថុមានតម្លៃ១បាទក្ដី គួរដល់ថ្លៃ១បាទក្ដី ឬ ថ្លៃជាង១បាទឡើងទៅក្ដី ដែលគេមិនបានឲ្យដោយកាយ ឬ ដោយវាចា ដោយចំណែកនៃចិត្តលួច ( ភិក្ខុនោះ ) មិនមែនជាសមណៈ មិនមែនជាសក្យបុត្រឡើយ ។ សេយ្យថាបិ នាម បណ្ឌុបលាសោ ពន្ធនា បមុត្តោ (១) អភព្វោ ហរិតត្តាយ ឯវមេវ ភិក្ខុ បាទំ វា បាទារហំ វា អតិរេកបាទំ វា អទិន្នំ ថេយ្យសង្ខាតំ អាទិយិត្វា អស្សមណោ ហោតិ អសក្យបុត្តិយោ ។ ស្លឹកឈើទុំមានពណ៌លឿង ដែលជ្រុះផុតចាកទងហើយ មិនអាចដើម្បីត្រឡប់ជាមានពណ៌ខៀវឡើងវិញបាន ដូចម្ដេចមិញ ភិក្ខុដែលកាន់យក នូវវត្ថុមានតម្លៃ ១ បាទក្ដី គួរដល់ថ្លៃ ១ បាទក្ដី ឬ ថ្លៃជាង ១ បាទឡើងទៅក្ដី ដែលគេមិនបានឲ្យដោយកាយ ឬ ដោយវាចា ដោយចំណែកនៃចិត្តលួច ក៏មិនមែនជាសមណៈ មិនមែនជាសក្យបុត្រដូច្នោះឯង ។

១— បវុត្តោ ក៏មាន ។



www.elibraryofcambodia.org

តន្តេ យាវជីវំ អករណីយំ ។ អ្នកមិនត្រូវកាន់យក នូវរបស់ដែលគេមិនបានឲ្យដោយកាយ ឬ ដោយវាចាដរាបដល់អស់ជីវិត នវភិក្ខុត្រូវទទួលថា អាម ភន្តេ ករុណាលោកម្ចាស់ ។

៣– ឧបសម្បន្នេន ភិក្ខុនា សញ្ចិច្ច បាណោ ជីវិតា ន វោរោបេតព្វោ អន្តមសោ កុន្ថកិបិល្លិកំ ឧបាទាយ ។ សត្វមានជីវិត គឺភិក្ខុដែលបានឧបសម្បទាហើយ មិនត្រូវក្លែងសម្លាប់ឲ្យផុតចាកជីវិតឡើយ ដោយហោចទៅ សូម្បីតែស្រមោចខ្មៅ និង ស្រមោចក្រហម ក៏សម្លាប់ពុំបាន ។

យោ ភិក្ខុ សញ្ចិច្ច មនុស្សវិគ្គហំ ជីវិតា វោរោបេតិ អន្តមសោ គព្ភបាតនំ ឧបាទាយ អស្សមណោ ហោតិ អសក្យបុត្តិយោ ។ ភិក្ខុឯណាមួយ ក្លែងសម្លាប់សត្វមានរាងកាយជាមនុស្សឲ្យផុតចាកជីវិត ដោយហោចទៅ សូម្បីតែញុំាងគភ៌នៃមនុស្សឲ្យធ្លាក់ចុះ (ភិក្ខុនោះ) មិនមែនជាសមណៈ មិនមែនជាសក្យបុត្រឡើយ ។ សេយ្យថាបិ នាម បុថុសិលា ទ្វេធា(១) ភិន្នា អប្បដិសន្ធិកា ហោតិ ឯវមេវ ភិក្ខុ សញ្ចិច្ច មនុស្សវិគ្គហំ ជីវិតា វោរោបេត្វា អស្សមណោ ហោតិ អសក្យបុត្តិយោ ។ ថ្មកាន់ដ៏ក្រាស់ដែលបែកចេញជា ២ ភាគនឹងតឲ្យជាប់វិញពុំបាន ដូចម្ដេចមិញ ភិក្ខុក្លែងសម្លាប់សត្វ មានរាងកាយជាមនុស្សឲ្យផុតចាកជីវិតហើយ ក៏មិនមែនជាសមណៈ មិនមែនជា សក្យបុត្រឡើយដូច្នោះឯង ។ តន្តេ យាវជីវំ អករណីយំ អ្នកមិនត្រូវក្លែងសម្លាប់សត្វមានរាងកាយជាមនុស្សនោះ ដរាបដល់អស់ជីវិត ។ នវភិក្ខុត្រូវទទួលថា អាម ភន្តេ ករុណាលោកម្ចាស់ ។

---

១– ធា ទ្វិធា ក៏បាន ។



www.elibraryofcambodia.org

៤- ឧបសម្បន្នេន ភិក្ខុនា ឧត្តរិមនុស្សធម្មោ ន ឧល្លបិតព្វោ អន្តមសោ សុញ្ញាគារេ អភិរមាមីតិ ។ ឧត្តរិមនុស្សធម្មគឺភិក្ខុដែលបានឧបសម្បទាហើយ មិនត្រូវពោលអួតឡើយ ដោយហោចទៅ សូម្បីតែពោលថា ខ្ញុំព្រះករុណាត្រេកអរតែក្នុងសុញ្ញាគារស្ថាន គឺទីសេនាសនៈដ៏ស្ងាត់ ដូច្នេះក៏ពុំបាន ។ យោ ភិក្ខុ បាបិច្ឆោ ឥច្ឆាបកតោ អសន្តំ អភូតំ ឧត្តរិមនុស្សធម្មំ ឧល្លបតិ ឈានំ វា វិមោក្ខំ វា សមាធឹ វា សមាបត្តឹ វា មគ្គំ វា ផលំ វា អស្សមណោ ហោតិ អសក្យបុត្តិយោ ។ ភិក្ខុឯណាមានសេចក្តីប្រាថ្នាលាមក គឺ សេចក្តីលោភគ្របសង្កត់រួបរឹតហើយ ពោលអួតនូវឧត្តរិមនុស្សធម្ម គឺឈានក្តី វិមោក្ខក្តី សមាធិក្តី សមាបត្តិក្តី មគ្គក្តី ផលក្តី ដែលមិនមានហើយដល់ខ្លួន ( ភិក្ខុនោះ ) មិនមែនជាសមណៈ មិនមែនជាសក្យបុត្រឡើយ ។ សេយ្យថាបិ នាម តាលោ មត្ថកច្ឆិន្នោ អភព្វោ បុន វិរុឡ្ហិយា ឯវមេវ ភិក្ខុ បាបិច្ឆោ ឥច្ឆាបកតោ អសន្តំ អភូតំ ឧត្តរិមនុស្សធម្មំ ឧល្លបិត្វា អស្សមណោ ហោតិ អសក្យបុត្តិយោ ។ ដើមត្នោតដែលមានចុងកំបុតត្រឹម ក ហើយ មិនអាចដើម្បីនឹងលូតលាស់ដុះចម្រើនឡើងបានដូចម្តេចមិញ ភិក្ខុដែលមានសេចក្តីប្រាថ្នាលាមក គឺសេចក្តីលោភគ្របសង្កត់រួបរឹតហើយ ពោលអួតនូវឧត្តរិមនុស្សធម្មដែលមិនមានក្នុងខ្លួន ក៏មិនមែនជាសមណៈ មិនមែនជាសក្យបុត្រ ដូច្នោះឯង ។ តន្តេ យាវជីវំ អករណីយំ អ្នកមិនត្រូវពោលអួតនូវឧត្តរិមនុស្សធម្មនោះ ដរាបដល់អស់ជីវិត ។ នវកភិក្ខុត្រូវទទួលថា អាម ភន្តេ ករុណាលោកម្ចាស់ ។

អនុសាសនវិធីនេះ ត្រូវឱ្យកុលបុត្រសិក្សាតែក្នុងអករណីយកិច្ច ៤ យ៉ាង ខាងចុង ឱ្យចាំស្ទាត់ចូលចិត្តស្ដាប់សេចក្ដីបានមុន ។

ចប់ អនុសាសនវិធីតែប៉ុណ្ណេះ

## សព្វវិធ្យាធិប្បាយ

កុលបុត្រ ដែលបានសិក្សាក្នុងវិធីមានអក្ខរវិធីជាដើម មានអនុសាសនវិធីជាទីបំផុត ក្នុងបញ្ញាខន្ធកសង្ខេបនេះ បានចាំស្ទាត់ក្រោកដហើយ ក៏គង់នឹងមានសេចក្ដីសង្ស័យក្នុងវិធីនោះ ៗ ខ្លះមិនខាន ព្រោះសេចក្ដីដែលបានពោលមកហើយទាំងប៉ុន្មាននោះ សុទ្ធតែជាសេចក្ដីសង្ខេប តាមបែបបាលីដែលមានមកក្នុងបញ្ញាខន្ធកៈមិនមានសេចក្ដីអធិប្បាយឱ្យចូលចិត្ត តាមអដ្ឋកថា ដីកា គណ្ឋីដោយសព្វគ្រប់ បើទុកជាមានអធិប្បាយខ្លះ ក៏ជាសេចក្ដីយ៉ាងខ្លី ៗ មិនអាចនឹងញាំងអ្នកសិក្សាឱ្យចូលចិត្តដោយសេចក្ដីជ្រាលជ្រៅច្បាស់លាស់បាន ។ បានជាមិនអធិប្បាយក្នុងវិធីទាំងពួងឱ្យពិស្ដារស្រេចតែម្ដងនោះ ព្រោះយល់ឃើញថា បើនឹងអធិប្បាយដោយពិស្ដារឱ្យស្រេចក្នុងទីនោះ ៗ តែម្ដងទៅ ឃើញថានឹងនាំឱ្យកុលបុត្រអ្នកសិក្សា ធុញថប់រាយមាយក្នុងការសិក្សា ។

ហេតុដូច្នោះ ទើបបានស្រង់យកសេចក្ដីអធិប្បាយក្នុងគម្ពីរនោះ ៗ ដូចមានឈ្មោះដែលនឹងពោលតទៅខាងមុខ នាំមកអធិប្បាយក្នុងខាងចុងនេះ តែថាដែលនឹងអធិប្បាយនោះ ក៏មិនបានជាពិស្ដារណាស់ តាមសេចក្ដីដែលមានក្នុងគម្ពីរនោះ ៗ ទេ មឹងអធិប្បាយតែត្រង់សេចក្ដីណា ដែលគួរនឹងឱ្យមានសង្ស័យដល់កុលបុត្រអ្នកសិក្សាប៉ុណ្ណោះឯង ។

កុលបុត្រអ្នកសិក្សា បើមានសេចក្ដីសង្ស័យ ឱ្យពិនិត្យមើលក្នុងសព្វវិធ្យា-ធិប្បាយដូចមានសេចក្ដីតទៅនេះចុះ ។

## ១ អធិប្បាយក្នុងអក្ខរវិធី

ត្រង់សេចក្ដីដែលពោលអំពីឋានករណៈនៃអក្ខរៈនោះ ក្នុងគម្ពីរទាំងពួង មានគម្ពីរចុល្លគណ្ឋិមហារត្ត គម្ពីរមុខមត្តទីបនី និងគម្ពីររូបសិទ្ធិជាដើម សឹងមានសេចក្ដីពោលខុសគ្នា គម្ពីរខ្លះថា មានឋាន ៥ គឺ ក ពិតាន ក្បាល ធ្មេញ បបូរមាត់ ។

គម្ពីរខ្លះថា មានឋាន ៦ គឺ ក ពិតាន ក្បាល ធ្មេញ បបូរមាត់ ច្រមុះ ។

គម្ពីរខ្លះថា មានឋាន ៧ គឺ ក ពិតាន ក្បាល ធ្មេញ បបូរមាត់ ច្រមុះ ទ្រូង និងលើអណ្ដាត ដែលហៅថា ជិវ្ហាជៈ មួយទៀតជា ៨ ។

សេចក្ដីដែលពោលក្នុងខាងដើមរួចហើយថា ឋានទីតាំងដែលនឹងឲ្យកើតអក្ខរៈ មាន ៧ យ៉ាងនោះ គឺពោលតាមសមគួរ តាមពាក្យវិនយបញ្ញត្តិ ។

អធិប្បាយក្នុងអក្ខរវិធី ចប់ ។

## ២ អធិប្បាយក្នុងឧបជ្ឈាយវិធី

ត្រង់ពាក្យថា ឧបជ្ឈាយ៍នោះ គឺពាក្យហៅតាមអានុភាពដែលលោកជាធំជាអធិបតីលើអាចារ្យទាំងពួង អាចបង្គាប់បញ្ជាអាចារ្យ ដែលឆ្លៀវឈ្លាសចេះចាំស្ទាត់ក្នុងវិធីអក្ខរៈ មានឋានករណៈជាដើម ឲ្យៗនូវព្រះត្រៃសរណគមន៍ឬឲ្យសូធ្យញត្តិកម្មវាចាឲ្យញាំងឧបសម្បទាបេក្ខៈ ឲ្យបានឡើងជាភិក្ខុភាវៈក្នុង ព្រះពុទ្ធសាសនា ឬលោកឲ្យព្រះត្រៃសរណគមន៍ និង សូធ្យញត្តិកម្មវាចារ្យឧបសម្បទាដល់កុលបុត្រក៏បាន ចំពោះឧបជ្ឈាយ៍ដែលនៅក្មេងចេះដឹងច្រើន មានធ្មេញមិនទាន់បាក់ មិនមានវស្សា១០ឡើងទៅ ទើបឲ្យសរណគមន៍សូធ្យញត្តិបាន ឯព្រះឧបជ្ឈាយ៍ដែលចាស់ជរាមានធ្មេញបាក់អស់ហើយ បើគ្រាន់តែបំបួសឲ្យតចបញ្ចកកម្មដ្ឋានប៉ុណ្ណោះបាន នឹងឲ្យត្រៃសរណគមន៍ សូធ្យញត្តិផងពុំបានឡើយ បានតែបង្គាប់អាចារ្យដែលឆ្លៀវឈ្លាសក្នុងវិធីអក្ខរៈ ឲ្យៗព្រះត្រៃសរណគមន៍ និងសូធ្យញត្តិកម្មវាចាជំនួសលោកបាន ព្រោះលោកជាអធិបតី អាចសម្រេចកិច្ចគ្រប់


www.elibraryofcambodia.org

ជំពូកក្នុងការបំបួស និងត្រួតត្រាមើលះទោសខុសត្រូវធំតូច គួរធ្វើមណ្ឌកម្មនិងមិនគួរធ្វើទណ្ឌកម្ម ឬប្រៀនប្រដៅសិស្សានុសិស្ស ឱ្យប្រតិបត្តិតាម ត្រូវត្រង់តាមធម៌តាមវិន័យក្នុងព្រះពុទ្ធសាសនា ។

មួយទៀត ព្រះថេរៈដែលបានឱ្យនិស្ស័យដល់ភិក្ខុសាមណេរទាំងឡាយឯណា ភិក្ខុសាមណេរទាំងនោះបានឈ្មោះថា **សទ្ធិវិហារិក** គឺជាសិស្សនៅជាមួយផងបាន ។ ឯព្រះថេរៈអង្គនោះ ក៏បានឈ្មោះថាជាព្រះឧបជ្ឈាយ៍ដោយពិត ។

អធិប្បាយក្នុងឧបជ្ឈាយ៍ ចប់ ។

## ៣ អធិប្បាយក្នុងកម្មវាចាចារិយវិធិ

ត្រង់ពាក្យថា កម្មវាចាចារនោះ គឺសំដៅយកអាចារ្យដែលចេះដឹងជ្រៅជ្រះស្ទាញត្តិឱ្យឧបសម្បទាបេក្ខៈ ដោយត្រឹមត្រូវតាមអក្ខរប្បភេទ ទើបឧបសម្បទា-បេក្ខៈកុលបុត្រនោះ ឡើងឧបសម្បទាជាភិក្ខុភាវៈក្នុងព្រះពុទ្ធសាសនាបាន ។

ឯអក្ខរប្បភេទនោះ មាន១០យ៉ាងគឺ សិថិល១ ធនិត១ ទីឃៈ១ រស្សៈ១ គរុ១ លហុ១ សម្ពន្ធៈ១ វវត្ថិតៈ១ និគ្គហិត១ វិមុត្ត១ ។

បើកម្មវាចាចារ្យ ស្វាធ្យាយឱ្យភ្លាត់ខុសអក្ខរប្បភេទទាំង៦យ៉ាងគឺ ស្វាធ្យាយទីឃៈជារស្សៈៗជាទីឃៈ គរុជាលហុៗជាគរុ សម្ពន្ធៈជាវវត្ថិតៈៗជាសម្ពន្ធៈ ។ ស្វាធ្យាយយ៉ាងនេះ កុលបុត្រដែលសម្ប៊ីងនូវឧបសម្បទា ក៏នៅឡើងជាភិក្ខុភាវៈដែរ តែកម្មវាចាចារ្យ ត្រូវអាបត្តិទុក្កដ ។

បើកម្មវាចាចារ្យ ស្វាធ្យាយញត្តិភ្លាត់ខុសអក្ខរប្បភេទ៤យ៉ាងគឺ ស្វាធ្យាយសិថិលជាធនិតៗជាសិថិល និគ្គហិតជាវិមុត្តៗជានិគ្គហិត ស្វាធ្យាយភ្លាត់យ៉ាងនេះ កុលបុត្រដែលសម្ញឹងនូវឧបសម្បទា ក៏ពុំបានឡើងជាភិក្ខុភាវៈឡើយ នៅជាសាមណេរដដែល ឯកម្មវាចាចារ្យ និងព្រះឧបជ្ឈាយ៍ ត្រូវអាបត្តិបាចិត្តិយៈ ការកសង្ឃដែលគង់ហត្ថបាស ត្រូវអាបត្តិទុក្កដទាំងអស់ ។

ម្យ៉ាងទៀត ពាក្យថាអាចារ្យនោះមាន៤យ៉ាងគឺ លោកអ្នកបំបួស បព្វជ្ជាបេក្ខៈឱ្យបានជាសាមណេរ បានឈ្មោះថា **បព្វជ្ជាចារ្យ ១** ។



www.elibraryofcambodia.org

លោកអ្នកឲ្យនិស្ស័យ ដល់ភិក្ខុសាមណេរ ដែលនៅមិនទាន់ជានិស្សយមុត្តកៈ គឺដែលមិនទាន់រួចផុតចាកនិស្ស័យ ព្រះឧបជ្ឈាយ៍នៅឡើយ ហើយមកសូមទីនៅអាស្រ័យផង បានឈ្មោះថា និស្សយាចារ្យ ១ ។

លោកដែលសូត្រញត្តិកម្មវាចា ឲ្យឧបសម្បទាបេក្ខៈ ឡើងបានជាភិក្ខុភាវៈក្នុងព្រះពុទ្ធសាសនា បានឈ្មោះថា ឧបសម្បទាចារ្យ ១ ។

លោកដែលបង្ហាត់បង្ហាញបាលី ឬ បង្ហាញធម៌អាថ៌ដល់សិស្សានុសិស្សទាំង-ឡាយ បានឈ្មោះថា ឧទ្ទេសាចារ្យ ឬ ធម្មាចារ្យ ១ ។

អធិប្បាយក្នុងកម្មវាចាចរិយវត្តចប់

## ៤ អធិប្បាយក្នុងបព្វជ្ជាវិធី

ត្រង់ពាក្យថា បព្វជ្ជាបេក្ខៈ នោះចំពោះកុលបុត្រដែលកាន់យកនូវគ្រឿងសក្ការបូជា មានទៀនធូបជាដើម ចូលទៅបូជាព្រះពុទ្ធរូបក្នុងខណ្ឌសីមា ធ្វើកាយបណាម និងវចីបណាមដោយគោរព រួចហើយចូលទៅសូមបព្វជ្ជាជាសាមណេរ ។

ឯបណាមទាំង២នោះ ដូចមានបាលីក្នុងគម្ពីរ ចុល្លគណ្ឋិមហាវគ្គថា

តេសុ កាយបណាមោ នាម បញ្ចប្បតិដ្ឋេន វន្ទនា ។

បណ្ដាបណាមទាំង ២ នោះ កិរិយាថ្វាយបង្គំ ដោយអវយវៈមានអង្គ៥ គឺក្បាល១ ដៃ ២ ជង្គង់ ២ ក្រាបចុះក៏ព្រមដោយអវយវៈទាំង៥ ងើបឡើងក៏ព្រមដោយអវយវៈទាំង៥ គឺអង្គុយច្រហោង ឈ្មោះថា កាយបណាម ពុកអំពីកិរិយាថ្វាយបង្គំរបស់គិហិទាំងអស់ ។

ឯពួកគិហិទាំងអស់ តែងថ្វាយបង្គំប្រកបដោយអង្គ៣ គឺ ក្បាល១ ដៃ២ ក្រាបចុះក៏ប្រកបដោយអង្គ៣ ងើបឡើងក៏ប្រកបដោយអង្គ៣ ឬ ថ្វាយបង្គំដោយក្រាបទ្រោលសន្ធឹងកាយទាំងស្រុង ឈ្មោះថា សព្វកាយវន្ទា ។



www.elibraryofcambodia.org

សព្វកាយវន្ទា ពុទ្ធសាសនេ ន ហោតិ ។ កិរិយាថ្វាយបង្គំដោយកាយទាំងអស់ យ៉ាងនេះ ក្នុងព្រះពុទ្ធសាសនាមិនមានឡើយ ។

ឯវចីបណាមនោះ គឺ សូធ្យនមស្ការ ពុទ្ធគុណ ធម្មគុណ សង្ឃគុណ មានសូធ្យថា ឥតិបិ សោ ភគវា ជាដើម ដោយវចីភេទ ឈ្មោះថា វចីបណាម រួចហើយត្រូវកាន់យកសំពត់កាសាវៈ ចូលទៅកាន់សំណាក់ឧបជ្ឈាយ៍ ឬអាចារ្យ ដាក់ចុះនូវសំពត់កាសាវៈទៀបទីដែលខ្លួនអង្គុយ ហើយក្រាបថ្វាយបង្គំ ចុះដោយបញ្ចង្គប្រតិស្ឋាន ហើយចីសំពត់កាសាវៈក្រោកឈរឡើង ប្រណម្យអញ្ជលី ធ្វើវចីបណាមចំពោះព្រះឧបជ្ឈាយ៍ ឬ អាចារ្យ ដោយវចីភេទថា ឱកាស វន្ទាមិ ភន្តេ ។ល។ សាធុ សាធុ អនុមោទាមិ ដូច្នេះ ឈ្មោះថា វចីបណាម ។

ឯពាក្យថា ឱកាស នោះ ក្នុងបាលីព្រមទាំងគណ្ឋិនិងអដ្ឋកថា ដីកា ពុំមានឡើយ តែបើពោលថា ឱកាស ផងទៅក៏ជាការល្អ ព្រោះជាពាក្យសម្ដែងនូវសេចក្ដីគោរព ។

ត្រង់បាលីដែលសូធ្យថា វន្ទាមិ ភន្តេ ជាបាលីនមស្ការថ្វាយបង្គំដោយវចីភេទ ។

ត្រង់បាលីថា សព្វំ អបរាធំ ខមថ មេ ភន្តេ ។ល។ សាធុ សាធុ អនុមោទាមិ ជាបាលីសម្រាប់សូធ្យសូមខមាទោស ចំពោះព្រះឧបជ្ឈាយ៍ ឬ អាចារ្យ ។

ត្រង់ក្រោកឈរឡើងហើយសូធ្យថា វន្ទាមិ ភន្តេ ជាដើមនេះ ក្នុងបាលី អដ្ឋកថា ដីកា គណ្ឋិ មិនមានបង្គាប់ទេ បានបង្គាប់តែត្រង់ថា ឲ្យអង្គុយច្រហោងហើយសូធ្យនមស្ការ សូមខមាទោសតែប៉ុណ្ណោះ ។

ត្រង់ពាក្យថា ស្លៀកស្បង់ត្រងចីវរ ពាក់សង្ឃាដីលើស្មាឆ្វេងឱ្យជាបរិមណ្ឌល និងក្រវាត់វត្ថពន្ធទ្រូងនោះ មានក្នុងបាលីព្រមទាំងអដ្ឋកថា ជាច្រើនគម្ពីរ តែត្រង់ក្រវាត់វត្ថពន្ធទ្រូងនោះ បានឃើញមានក្នុងគម្ពីរចុល្លគណ្ឋិមហាវគ្គ និងគម្ពីរ ធម្មសមុហ-វិន័យតែបុណ្ណោះថា ឧរពន្ធនវត្ថេន ឧរជេនគោ ហេដ្ឋាចតុ-រង្គុលប្បមាណំ ពន្ធិតព្វំ គួរក្រវាត់វត្ថពន្ធទ្រូងខាងក្រោមដោះទាំងពីរមានប្រមាណ៤ធ្នាប់ ។ បារុបនមណ្ឌលំ រក្ខនត្ថាយ ឧរពន្ធន-វត្ថំ ពន្ធិតព្វំ គួរក្រវាត់សំពត់វត្ថពន្ធទ្រូង ដើម្បីរក្សានូវបរិមណ្ឌលដែលបានគ្រងហើយ មិនឱ្យរយិករយាកក្នុងពេលធ្វើសង្ឃកម្មមានបួសជាដើម ។ ឧរពន្ធនវត្ថំ ទីឃសោ ចតុហត្ថប្បមាណំ តិរិយំ វិទត្ថិប្បមាណំ ជាវត្ថពន្ធទ្រូង បណ្តោយប្រមាណ៤ហត្ថ ទទឹងប្រមាណមួយចំអាមជាកំណត់ ។

មួយវិញទៀត ក្នុងគម្ពីរមហាវគ្គ លោកសម្តែងសេចក្តីថា គប្បីឱ្យបព្វជ្ជាបេក្ខៈកុលបុត្រដែលសំឡឹងយកនូវផ្នួស កោរសក់និងពុកចង្ការ ហើយឱ្យស្លៀកដណ្តប់សំពត់កាសាវៈទាំងឡាយ រៀងស្មាម្ខាង ឱ្យថ្វាយបង្គំបាទានៃភិក្ខុទាំងឡាយ ហើយឱ្យអង្គុយច្រហោងលើកដៃប្រណម្យឡើង ។

ឯព្រះឧបជ្ឈាយ៍ ឬ បព្វជ្ជាចារ្យ ត្រូវបង្គាប់ថា ឯវំ វទេហិ អ្នកចូរពោលយ៉ាងនេះ ហើយឱ្យទទួលព្រះត្រៃសរណគមន៍ ដូច្នេះថា ពុទ្ធំ សរណំ គច្ឆាមិ ។ ។ល។ តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ដោយវិធីប៉ុណ្ណោះ បព្វជ្ជាបេក្ខៈនោះបានឈ្មោះថា បានតាំងនៅក្នុងសាមណេរភូមិ គឺទីជាសាមណេរ ។

មានន័យក្នុងអដ្ឋកថា និង ដីកា គណ្ឋិ សម្តែងថា កិច្ចដែលបួសជាសាមណេរនោះ ត្រូវធ្វើប្រកបដោយអង្គ ៣ ប្រការ ទើបសម្រេចពេញបរិបូណ៌បាន ។



www.elibraryofcambodia.org

អង្គ ៣ ប្រការនោះ គឺ

កេសច្ឆេទនំ កោរសក់ កោរពុកមាត់ ពុកចង្កា ១

កាសាវច្ឆាទនំ ស្លៀកដណ្តប់សំពត់កាសាវៈ ១

សរណគមនំ ឱ្យដឹកកិច្ចទទួលយកព្រះត្រៃសរណគមន៍ ១។

នឹងអធិប្បាយដោយសង្ខេប ក្នុងអង្គទាំងបីប្រការ ដូចសេចក្តីតទៅនេះ ថា ភិក្ខុដែលនៅក្នុងអាវាសមានមហាសីមា កាលនឹងបំបួស បើកុលបុត្រនោះ មិនទាន់កោរសក់នៅឡើយទេ កុំអាលកោរសក់បំបួសឱ្យស្រេចតែម្នាក់ឯងឡើយ ដ្បិតមានពុទ្ធានុញ្ញាតឱ្យប្រាប់ភណ្ឌុកម្ម ដល់ភិក្ខុសង្ឃ គឺប្រាប់អំពីកិច្ចកោរសក់ របស់បព្វជ្ជាបេក្ខៈ ។

ឯវិធីប្រាប់ភណ្ឌុកម្មនោះ ត្រូវឱ្យភិក្ខុជាអ្នកបំបួស ប្រជុំភិក្ខុទាំងឡាយដែល នៅក្នុងសីមា ឱ្យមកជួបជុំព្រមព្រៀងគ្នា ហើយនាំបព្វជ្ជាបេក្ខៈទៅក្នុងទីប្រជុំនោះ ហើយប្រាប់ថា សង្ឃំ ភន្តេ ឥមស្ស ទារកស្ស ភណ្ឌុកម្មំ អាបុច្ឆាមិ ៣ ដងក៏បាន ២ ដងក៏បាន ម្តងក៏បាន (ប្រែថា) បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំប្រាប់នូវភណ្ឌុកម្មនៃទារកនេះដល់សង្ឃ ។ ឬនឹងប្រាប់ថា ឥមស្ស សមណករណំ អាបុច្ឆាមិ ដូច្នេះក៏បាន (ប្រែថា) ខ្ញុំប្រាប់នូវកិរិយាធ្វើនូវទារកនេះឱ្យជាសមណៈ ។ ពុំនោះនឹងប្រាប់ថា អយំ បព្វជិតុកាមោ ដូច្នេះក៏បាន ( ប្រែថា ) ទារកនេះចង់បួស ។

បើកំណត់ដឹងបានថា ភិក្ខុទាំងឡាយនៅក្នុងទីណា ៗ ខ្លះ ក៏ត្រូវដើរទៅប្រាប់ដល់ភិក្ខុទាំងឡាយក្នុងទីនោះៗ ដោយទំនងមុនក៏បាន ។ បើមិនបាច់នាំបព្វជ្ជាបេក្ខៈទៅ គ្រាន់តែប្រើភិក្ខុកំលោះ ឬសាមណេរឱ្យទៅប្រាប់ជួសក៏បាន ត្រូវឱ្យប្រាប់ថា ឯកោ ភន្តេ បព្វជ្ជាបេក្ខោ អត្ថិ តស្ស ភណ្ឌុកម្មំ អាបុច្ឆាមិ (ប្រែថា) បពិត្រលោកដ៏ចម្រើន ដ្បិតមានបព្វជ្ជាបេក្ខៈ១ រូប ខ្ញុំព្រះករុណា សូមប្រាប់នូវភណ្ឌុកម្ម នៃបព្វជ្ជាបេក្ខៈនោះ ។ បើមិន



www.elibraryofcambodia.org

បានដើរប្រាប់ឱ្យគ្រប់អង្គទេ តែសម្គាល់ថាបានប្រាប់គ្រប់អង្គហើយ បព្វជ្ជាបេក្ខៈ ដែលបួសហើយ ក៏បានឈ្មោះថា បួសដោយល្អ លោកអ្នកចំបួស ក៏ឥតមានត្រូវអាបត្តិអ្វីឡើយ ព្រោះកិច្ចនៃបព្វជ្ជាជាលហុកម្ម គឺកិច្ចត្រូវធ្វើយ៉ាងស្រាលល្មមទេ ។

បើបព្វជ្ជាបេក្ខៈនោះ កោរសក់រួចស្រេចមកហើយក្តី ទើបនឹងសឹកក្តី ដែលមានសក់កោរបារហើយ ដុះឡើងត្រឹម២ធ្នាប់ ឬ ខ្វះជាង២ធ្នាប់ក្តី កិច្ចដោយកោរសក់ទៀតនោះក៏មិនមាន ទាំងភណ្ឌុកម្ម ក៏មិនត្រូវប្រាប់ដល់សង្ឃឡើយ ត្រូវបំបួសតែម្តងទៅចុះ ។

ប្រសិនបើមានកិច្ចដោយកោរសក់នោះ កាលមុននឹងកោរត្រូវអាចារ្យ ឬ ឧបជ្ឈាយ៍ និយាយពន្យល់បព្វជ្ជាបេក្ខៈឱ្យប្រុងតម្កល់ស្មារតី ឱ្យល្អដើម្បីចារពណ៌នាព្រះកម្មដ្ឋាន ហើយត្រូវប្រាប់ **តចបញ្ចកកម្មដ្ឋាន** គឺកម្មដ្ឋានមានស្បែកជាគម្រប់៥ ថា **កេសា** សក់ទាំងឡាយ **លោមា** រោមទាំងឡាយ **នខា** ក្រចកទាំងឡាយ **ទន្តា** ធ្មេញទាំងឡាយ **តចោ** ស្បែក ។

កាលដែលនឹងប្រាប់នោះ ត្រូវអធិប្បាយពន្យល់បព្វជ្ជាបេក្ខៈ ឱ្យចូលចិត្តស្គាល់បាន ឱ្យឃើញច្បាស់ប្រាកដថា ជារបស់មិនស្អាតគួរខ្ពើម ជារបស់បដិកូលដោយពណ៌ សណ្ឋាន ក្លិន ទីលំនៅ ឱកាស ហើយសឹមកោរសក់បព្វជ្ជាបេក្ខៈនោះដោយខ្លួនឯង ឬនឹងឱ្យអ្នកណាម្នាក់ជួយកោរជួសក៏បាន ។ កាលបើកោរសក់រួចហើយ ត្រូវឱ្យទទួលយកសម្ពត់កាសាវៈទៅស្លៀកដណ្តប់ ដោយពាក្យសូម ១ ដង ២ដង ៣ដង ក៏បាន ។

ក្នុងដីកាវិមតិវិនោទនីថា បើសំពត់កាសាវៈ របស់បព្វជ្ជាបេក្ខៈមានហើយ ត្រូវប្រគល់សំពត់កាសាវៈរបស់ខ្លួន ទៅឧបជ្ឈាយ៍ ឬ អាចារ្យដោយពាក្យអង្វរ ១ ដង ២ ដង ៣ដងក៏បាន ថា **សព្វទុក្ខ និស្សរណ និព្វាន សច្ឆិករណត្ថាយ ។ល។ អនុកម្បំ ឧបាទាយ ។**
ព្រះឧបជ្ឈាយ៍ ឬ អាចារ្យត្រូវទទួលយកសំពត់កាសាវៈនោះ អំពីដៃបព្វជ្ជា-បេក្ខៈមក ។

ឯបព្វជ្ជាបេក្ខៈ ត្រូវសូមសំពត់កាសាវៈនោះ យកមកវិញដោយពាក្យអង្វរ ១ ដង ២ ដង ៣ ដងក៏បាន ថា **សព្វទុក្ខ និស្សរណ និព្វាន សច្ឆិករណត្ថាយ ។ល។ អនុកម្បំ ឧបាទាយ ។**

កាលបើបព្វជ្ជាបេក្ខៈ ពោលសូមដូច្នេះហើយ បើព្រះឧបជ្ឈាយ៍ ឬ អាចារ្យ លោកស្លៀកដណ្ដប់ឱ្យ ដោយខ្លួនឯងតែម្ដងក៏បាន ឬ លោកប្រើភិក្ខុកំឡោះ សាមណេរ ឬ ឧបាសកណាមួយស្លៀកដណ្ដប់ឱ្យក៏បាន ឬ លោកប្រាប់បព្វជ្ជាបេក្ខៈឱ្យយកសំពត់កាសាវៈ ទៅស្លៀកដណ្ដប់ដោយខ្លួនឯងក៏បាន ដែលធ្វើយ៉ាងនេះ សំពត់កាសាវៈនោះ ឈ្មោះថាភិក្ខុជាព្រះឧបជ្ឈាយ៍ ឬ អាចារ្យបាន ប្រគល់ឱ្យហើយ ។

បព្វជ្ជាបេក្ខៈ មិនត្រូវស្លៀកដណ្ដប់តាមទំនើងចិត្តរបស់ខ្លួន ដោយឥតមានបង្គាប់ពីព្រះឧបជ្ឈាយ៍ ឬ អាចារ្យឡើយ បើទុកជាស្លៀកដណ្ដប់តាមទំនើងចិត្តរបស់ខ្លួនរួចហើយ ក៏ព្រះឧបជ្ឈាយ៍ឬ អាចារ្យ ត្រូវឱ្យផ្លាស់ចេញ ហើយឱ្យស្លៀកដណ្ដប់ជាថ្មីទៀត ព្រោះកិច្ចត្រង់ប្រគល់សំពត់កាសាវៈ ឱ្យបព្វជ្ជាបេក្ខៈស្លៀកដណ្ដប់នេះ ជាកិច្ចត្រូវតែព្រះឧបជ្ឈាយ៍ ឬ អាចារ្យធ្វើទើបបាន ។

កាលបើបព្វជ្ជាបេក្ខៈ បានស្លៀកស្បង់ត្រងចីពរឆៀងស្មាម្ខាង ជាបរិមណ្ឌលរួចហើយ ព្រះឧបជ្ឈាយ៍ឬ អាចារ្យ គប្បីឱ្យបព្វជ្ជាបេក្ខៈនោះ ថ្វាយបង្គំនូវបាទានៃភិក្ខុទាំងឡាយ ហើយឱ្យអង្គុយច្រហោង លើកកំបង់អញ្ជលីប្រណម្យឡើង ដើម្បីនឹងទទួលយកព្រះត្រៃសរណគមន៍ ។

ព្រះឧបជ្ឈាយ៍ ឬ អាចារ្យ មុននឹងឱ្យនូវព្រះត្រៃសរណគមន៍ ត្រូវប្រាប់បព្វជ្ជាបេក្ខៈថា **យមហំ វទាមិ តំ វទេហិ** អ្នកចូរថាតាមពាក្យយើង ( ឬថា ) យើងថាដូចម្ដេច អ្នកត្រូវថាតាមដូច្នោះ ។

ព្រះឧបជ្ឈាយ៍ឬអាចារ្យប្រាប់ដូច្នេះរួចហើយ ត្រូវឱ្យសរណគមន៍ ដល់បព្វជ្ជាបេក្ខៈ តាំងពី **ពុទ្ធំ សរណំ គច្ឆាមិ ។ល។ តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ។ បព្វជ្ជាបេក្ខៈ ត្រូវទទួលព្រះត្រៃសរណគមន៍ ១ បទម្ដងៗ ដរាបដល់ចប់



www.elibraryofcambodia.org

លុះទទួលចប់ស្រេចក្នុងពេលណា បព្វជ្ជាបេក្ខៈនោះឈ្មោះថា តាំងនៅក្នុងសាមណេរភូមិ គឺពេញទីជាសាមណេរក្នុងពេលនោះ ។

ក្រៅពីនេះ ក្នុងអដ្ឋកថា **គតិយសមន្តបាសាទិកា** សម្ដែងថា បើនឹងឱ្យសរណគមន៍ជា « **អនុនាសិកន្ត:** » ក៏បាន តែត្រូវឱ្យជា **ឯកសម្ពន្ធ** គឺពោលឱ្យមានបទជាប់ជាមួយគ្នាថា **ពុទ្ធំ សរណំ គច្ឆាមិ** ឈប់ម្ដង ។ល។ **តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ឈប់ម្ដង ដូច្នេះ ឬ នឹងឱ្យសរណគមន៍មាន ព្យ «ម» ប្រកបខាងចុងក៏បាន តែត្រូវឱ្យពោលផ្ដាច់បទចេញពីគ្នា ១ បទម្ដងៗ ជាសង្កាត់ៗដូច្នេះ ថា **ពុទ្ធម៑** ឈប់ម្ដង **សរណម៑** ឈប់ម្ដង **គច្ឆាមិ** ឈប់ម្ដង ។ល។ **តតិយម្បិ** ឈប់ម្ដង **សង្ឃម៑** ឈប់ម្ដង **សរណម៑** ឈប់ម្ដង **គច្ឆាមិ** ឈប់ម្ដង ។

ក្នុងគម្ពីរចុល្លគណ្ឋិមហាវគ្គថា បើបព្វជ្ជាបេក្ខៈ មានជរង្គើមខ្ទិតិញ៉ំឬហត់ មិនអាចនឹងពោលសរណគមន៍ ជា **អនុនាសិកន្ត:** ដែលជាប់បទជាមួយគ្នានោះបានទេ គប្បីឱ្យសរណគមន៍ ជា **មការន្ត:** ១បទម្ដងៗ ជាសង្កាត់ៗ ដើម្បីសង្គ្រោះដល់កុលបុត្រដែលមានជរង្គើមខ្ទិ ឱ្យបានបព្វជ្ជាឡើងពេញបរិបូណ៌ជាសាមណេរពេញទី ។

កិច្ចដែលឱ្យនឹងទទួលសរណគមន៍នេះ ក្នុងអដ្ឋកថាគតិយសមន្តបាសាទិកា សម្ដែងថា ព្រះឧបជ្ឈាយ៍ ឬអាចារ្យ គប្បីឱ្យៗត្រូវតាមលំដាប់បទ លំដាប់អក្ខរៈ ប្រសិនបើឱ្យខុសលំដាប់បទ ឬ ខុសលំដាប់អក្ខរៈ ដូចជាឱ្យថា **ពុទ្ធំ សរណំ គច្ឆាមិ** ៣ដង ហើយឱ្យ **ធម្មំ សរណំ គច្ឆាមិ** ៣ដង រួចឱ្យ **សង្ឃំ សរណំ គច្ឆាមិ** ៣ដង ដូច្នេះ មិនបានឈ្មោះថាឱ្យសរណគមន៍ទេ សាមណេរបព្វជ្ជាក៏មិនឡើង ព្រោះសាមណេរបព្វជ្ជានេះជា **ឧភតោសុទ្ធិ** គឺបរិសុទ្ធិភ័អ្នកឱ្យ និងអ្នកទទួល មិនមែនដូចឧបសម្បទាកម្មទេ ដ្បិតឧបសម្បទាកម្ម ជា **ឯកតោសុទ្ធិ** គឺបរិសុទ្ធតែខាងម្ខាង គឺលោក

ជាកម្មវាចាប្រវែលស្ទាប់ បានធ្វើឱ្យផុតអំពីទោសនៃញត្តិ និងទោសនៃកម្មវាចា បានហើយ ឧបសម្បទាកម្មក៏បរិសុទ្ធទៅបាន ។

ឯសារណគមន៍បព្វជ្ជាជាឧភតោសុទ្ធិ គឺបរិសុទ្ធអំពីអ្នកឱ្យនិងអ្នកទទួល បាន ពោលសរណគមន៍ឱ្យ ត្រូវតាមលំដាប់ឋានករណៈ របស់ព្យញ្ជនៈទាំងឡាយនិង ស្ទាប់ថាត្រូវតាមលំដាប់បទ និងលំដាប់អក្ខរៈ ដូចគ្នាទាំងពីររូប ។

បើអ្នកឱ្យ ឬ អ្នកទទួល ថាមិនត្រូវតាមឋានករណៈរបស់អក្ខរៈ ណាមួយ ឬ ថាឱ្យក្លាត់ ហើយមិនត្រឡប់ថាថែមទៀតឱ្យត្រូវ ឬថាឱ្យខុសលំដាប់អក្ខរៈក្តីនោះ សារណគមន៍បព្វជ្ជាមិនឡើងឡើយ ។

ព្រោះហេតុនោះ បានជាព្រះគន្ថរចនាចារ្យ លោកបានពោលទុកក្នុងគម្ពីរ ចុល្លគណ្ឋិមហារត្ថថា សរណគមន៍នេះជាគរុកម្ម គឺកម្មមានទម្ងន់របស់បព្វជ្ជា-បេក្ខៈ ព្រះឧបជ្ឈាយ៍ ឬ អាចារ្យ គប្បីឱ្យព្រះត្រៃសរណគមន៍ ដល់បព្វជ្ជាបេក្ខៈ ឬ ដល់សារណរវែលជាច់ស័លក្នុងពេលមួយ ។ បានតែត្រឹម ១ រូប មិនត្រូវឱ្យ ក្នុងខណៈមួយៗច្រើនរូបទេ បើឱ្យច្រើនតាំងពី ២-៣-៤ រូប ជាដើមឡើងទៅនោះ សារណរបព្វជ្ជាមិនឡើងឡើយ។លុះអ្នកឱ្យតែម្នាក់អ្នកទទួលតែម្នាក់ដូចគ្នា ហើយ ពោលត្រឹមត្រូវបរិបូណ៌ដោយឋានករណៈរបស់អក្ខរៈ ប្រកបដោយ ចតុរង្គៈ មានជ្រុង ៤ ដូចបទថា ពុទ្ធំ សរណំ គច្ឆាមិ ជាដើម ។

ត្រង់ពាក្យថា ពុទ្ធំ ត្រូវពោលឱ្យមានជ្រុង ៤ គឺ ឱដ្ឋដ្ឋានំ ទីកើត ត្រង់រិមបបូរមាត់ ១ ឱដ្ឋករណំ ធ្វើសំឡេងឱ្យលាន់ឮតាមរិមបបូរមាត់ ១ សិថិលំ សំឡេងធូរ ១ ឃោសំ សំឡេងគឹកកង ១ ឈ្មោះថា អនុនាសិកន្តៈ មានជ្រុង ៤ ។

ធំ ត្រូវពោលឱ្យមានជ្រុង ៤ គឺ ទន្តដ្ឋានំ ទីកើតត្រង់ប្រទល់ធ្មេញ ១ ជិវ្ហាករណំ ធ្វើសំឡេងឱ្យលាន់ឮតាមចុងអណ្តាត ១ ធនិតំ សំឡេងតឹង ១ ឃោសំ សំឡេងគឹកកង ១ ឈ្មោះថា នាសិកន្តៈ មានជ្រុង ៤ ។



www.elibraryofcambodia.org

ស ត្រូវពោលឲ្យមានជ្រុង៤ គឺ ទន្តដ្ឋានំ ទីកើតត្រង់ប្រទល់ធ្មេញ ១ ជិវ្ហករណំ ធ្វើសំឡេងឲ្យលាន់ឮតាមចុងអណ្ដាត១ សិថិលំ បន្ទរសំឡេងឲ្យឮធូរ ១ វិវដរឃោសំ មានសំឡេងគឹកកងប្រោសចេញ ១ ឈ្មោះថា អនុនាសិកន្តៈ មានជ្រុង៤ ។

រ ត្រូវពោលឲ្យមានជ្រុង ៤ គឺ មុទ្ធដ្ឋានំ ទីកើតក្នុងក្បាល ១ ជិវ្ហោបគ្គករណំ ធ្វើសំឡេងឲ្យលាន់ឮរលាស់ចុងអណ្ដាតចូលមក ១ ឃោសំ សំឡេងលាន់ឮគឹកកង ១ ឦសសម្ផុដ្ឋំ ស្ទរសំឡេងប៉ះពាល់បន្តិចបន្តួច ពុំពេញមាត្រាអក្សរ ១ ឈ្មោះថា អនុនាសិកន្តៈ មានជ្រុង ៤ ។

ណំ ត្រូវពោលឲ្យមានជ្រុង ៤ គឺ មុទ្ធដ្ឋានំ ទីកើតក្នុងក្បាល ១ ជិវ្ហោបគ្គករណំ ធ្វើសំឡេងឲ្យលាន់ឮរលាស់ចុងអណ្ដាតចូល ១ ឃោសំ សំឡេងលាន់ឮគឹកកង ១ ឦសសម្ផុដ្ឋំ ស្ទរសំឡេងប៉ះពាល់បន្តិចបន្តួចពុំពេញមាត្រាអក្សរ ១ ឈ្មោះថា នាសិកន្តៈ មានជ្រុង៤ ។

ត័ច ត្រូវពោលឲ្យមានជ្រុង ៤ គឺ កណ្ឋដ្ឋានំ ទីកើតក្នុងក១ ខុទ្ទកជិវ្ហាករណំ ធ្វើសំឡេងឲ្យហើបអណ្ដាតឡើងបន្តិច ១ សិថិលំ បន្ទរសំឡេងឲ្យឮធូរ ១ ឃោសំ សំឡេងលាន់ឮគឹកកង ១ ឈ្មោះថាអនុនាសិកន្តៈមានជ្រុង ៤ ។

ឆា ត្រូវពោលឲ្យមានជ្រុង ៤ គឺ តាលុដ្ឋានំ ទីកើតត្រង់ពិតានៈ ១ ជិវ្ហាមជ្ឈករណំ ធ្វើសំឡេងឲ្យលាន់ឮត្រង់ពាក់កណ្ដាលអណ្ដាត ១ ធនិតំ ធ្វើសំឡេងឲ្យឮតឹង ១ អឃោសំ សំឡេងមិនលាន់ឮគឹកកង ១ ឈ្មោះថាអនុនាសិកន្តៈ មានជ្រុង៤ ។

ម៉ិ ត្រូវពោលឲ្យមានជ្រុង ៤ គឺ ឱដ្ឋដ្ឋានំ ចំកើតត្រង់រីមបបូរមាត់ ១ ឱដ្ឋករណំ ធ្វើសំឡេងឲ្យលាន់ឮតាមរីមបបូរមាត់ ១ សិថិលំ សំឡេងធូរ ១ រស្សៈសំ សំឡេងលាន់ឮតឹកកង ១ ឈ្មោះថា អនុនាសិកន្តៈ មានជ្រុង ៤ ។ ល ។ ។ ល ។

ឯបព្វជ្ជាបេក្ខៈ កាលបើបានទទួលយកសរណគមន៍ត្រឹមត្រូវ តាមចតុរស្សៈ ដូចបានអធិប្បាយមកនេះហើយ ទើបបានឡើងជាសាមណេរពេញទី ។ ព្រះឧបជ្ឈាយ៍ ឬ អាចារ្យ គប្បីសម្ដែងប្រាប់នូវសិក្ខាបទទាំង ១០ ដល់សាមណេរថ្មីនោះ តាមពុទ្ធានុញ្ញាត ដែលមានមក ក្នុងគម្ពីរមហាវគ្គថា បាណាតិបាតា វេរមណី ។ល។ ជាតរូប រជតប្បដិគ្គហណា វេរមណី ដូច្នេះ។

ឯបព្វជ្ជានេះ សម្រេចឡើងបានតែដោយសរណគមន៍ មិនមែនសម្រេចដោយសិក្ខាបទទេ ។ សិក្ខាបទជាធម៌សម្រាប់នឹង ដើម្បីនឹងបំពេញនូវសិក្ខាបទតែម្យ៉ាងប៉ុណ្ណោះ ។ ព្រោះហេតុនោះ បើសាមណេរមិនអាចរៀនយកនូវសិក្ខាបទ តាមន័យដែលមានក្នុងបាលិនោះបានទេ ព្រះឧបជ្ឈាយ៍ ឬ អាចារ្យគប្បីអធិប្បាយសិក្ខាបទទាំង ១០ នោះ ដោយភាសាណាមួយក៏បាន ។

ក្នុងគម្ពីរចុល្លវគ្គណ៍មហាវគ្គ មានសេចក្ដីថា កាលបើសាមណេរបានទទួលនូវព្រះត្រៃសរណគមន៍ចប់ស្រេចពេលណា ព្រះឧបជ្ឈាយ៍ ឬ អាចារ្យ គប្បីឲ្យសាមណេរថ្មីនោះ ទទួលសមាទាននូវសិក្ខាបទទាំង ១០ ក្នុងពេលនោះ ថា បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ ។ល។ ជាតរូប រជតប្បដិគ្គហណា វេរមណីសិក្ខាបទំ សមាទិយាមិ ដូច្នេះ ។

ម្យ៉ាងទៀត បើសាមណេរនោះ មិនទាន់ចេះដឹងនូវសិក្ខាបទដែលខ្លួនត្រូវសិក្សា ឬ មិនទាន់ឈ្លាសក្នុងកិច្ចទាំងឡាយ មានប្រើប្រាស់នូវសង្ឃាដី បាត្រ ចីវរ និងកិច្ចរៀបចំនូវឥរិយាបថទាំង៤ មានឈរនិងអង្គុយជាដើម ឬ មិនទាន់

ឈ្លាសក្នុងវិធីផ្សេង ៗ ម្រានរបៀបឆាន់ទឹកនិងភោជនាហារជាដើមទៅទៀតទេ នោះព្រះឧបជ្ឈាយ៍ ឬ អាចារ្យ មិនត្រូវប្រើ ឬ ចាត់សាមណេរនោះឲ្យទៅឯ សាលាឆាន់ ទីសម្រាប់ចែកស្លាក ឬ ទីឯណាមួយទៀត ត្រូវបង្ហាត់បង្រៀន សាមណេរនោះ ក្នុងសំណាក់របស់ខ្លួនដូចជាក្មេងតូច ដែលមាតាបិតាថែរក្សា ក្នុងសំណាក់របស់ខ្លួនដូច្នោះ ។

ម្យ៉ាងទៀត ព្រះឧបជ្ឈាយ៍ ឬ អាចារ្យ គប្បីប្រាប់នូវកិច្ចការដែលគួរនិង មិនគួរគ្រប់យ៉ាងដល់សាមណេរនោះ និងគប្បីទូន្មានប្រៀនប្រដៅ ឲ្យប្រព្រឹត្តក្នុង អភិសមាចារិកវត្តទាំងឡាយ មានកិច្ចស្លៀកស្បង់ និងដណ្តប់ចីវរជាដើម ។

ក្នុងគម្ពីរដីកាវិមតិវិនោទនី មានសេចក្តីថា សាមណេរត្រូវប្រព្រឹត្ត ប្រតិបត្តិ ក្នុងសេខិយវត្ត និងខន្ធកវត្ត និងវត្តទាំងឡាយឯទៀតផង ត្រូវប្រតិបត្តិ ក្នុងសិក្ខាបទ ទាំងឡាយដែលជាលោកវជ្ជៈ មានសុក្កវិស្សដ្ឋិសិក្ខាបទជាដើម (សេខិយវត្តខន្ធក-វត្ត និងលោកវជ្ជសិក្ខាបទទាំងនោះ ភិក្ខុត្រូវប្រព្រឹត្តកាន់មិនឲ្យល្មៀងយ៉ាងណា សាមណេរក៏ត្រូវប្រព្រឹត្តកាន់មិនឲ្យល្មៀង យ៉ាងនោះដែរ) ។ កាលបើសាមណេរ មិនប្រព្រឹត្តប្រតិបត្តិ ក្នុងវត្តមានសេខិយវត្តជាដើម ឬ មិនប្រព្រឹត្តក្នុងលោក-វជ្ជសិក្ខាបទទាំងឡាយ មានសុក្កវិស្សដ្ឋិសិក្ខាបទជាដើមនោះទេ សាមណេរនោះ ឈ្មោះថាអលជ្ជីផង ជាអ្នកគួរដល់ទណ្ឌកម្ម គឺថា ព្រះឧបជ្ឈាយ៍ ឬ អាចារ្យ គប្បីធ្វើនូវទណ្ឌកម្មផង ។

ម្យ៉ាងទៀត សាមណេរគប្បីតាំងចិត្តប្រតិបត្តិ វៀរចាកនាសនង្គៈហើយ បំពេញ នូវអភិសមាចារិកវត្ត និងគប្បីសិក្សាដោយប្រពៃ ក្នុងសីលទាំង ១០ ឲ្យ ពេញបរិបូណ៌ ។

សេចក្តីដែលសម្តែងបព្វជ្ជាកិច្ចមកនេះ តាមន័យក្នុងបាលីព្រមទាំងអដ្ឋកថាដីកា និងគម្ពីរជាសេចក្តីសង្ខេប ។

អធិប្បាយបព្វជ្ជាវិធី ចប់ ។



www.elibraryofcambodia.org

# ៥- អធិប្បាយក្នុងឧបសម្បទាវិធី

ត្រង់ពាក្យថា ឧបសម្បទាបេក្ខៈចូលមកក្នុងកណ្តាលការកសង្ឃនោះ បានពិនិត្យឃើញក្នុងគម្ពីរមហាវគ្គ តតិយសមន្តប្បាសាទិកា អដ្ឋកថា និងគម្ពីរកង្ខាវិតរណីជាដើម សម្តែងពន្យល់សេចក្តីថា ប្រជុំនៃភិក្ខុច្រើនរូបដោយសេចក្តីមិនបែកគ្នា បានឈ្មោះថាសង្ឃ ។

ឯសង្ឃនោះ មាន ២ យ៉ាងគឺ

ប្រជុំនៃព្រះអរិយបុគ្គលទាំង៨ពួក ជាភិក្ខុឈ្មោះថា**ទក្ខិណេយ្យសង្ឃ**១ ប្រជុំនៃភិក្ខុជាបុថុជ្ជន ដែលលោកសន្មតឈ្មោះថា **សម្មតិសង្ឃ**១ ជាសង្ឃ ២យ៉ាង សម្រាប់ធ្វើសង្ឃកម្មនោះៗ ។

ក៏សង្ឃទាំង២យ៉ាងនេះ ចែកចេញទៅទៀតជា៥ពួកផ្សេងគ្នា គឺប្រជុំនៃភិក្ខុ ៤រូប ឈ្មោះថា **សង្ឃចតុវគ្គ** ១ ប្រជុំនៃភិក្ខុ៥រូប ឈ្មោះថា **សង្ឃបញ្ចវគ្គ** ១ ប្រជុំនៃភិក្ខុ១០រូប ឈ្មោះថា **សង្ឃទសវគ្គ** ១ ប្រជុំនៃភិក្ខុ២០រូប ឈ្មោះថា **សង្ឃវីសតិវគ្គ** ១ ប្រជុំនៃភិក្ខុច្រើនជាង ២០រូបឡើងទៅ ឈ្មោះថា **សង្ឃអតិរេកវីសតិវគ្គ** ១ ។

ឯសង្ឃចតុវគ្គនោះ គួរនឹងធ្វើសង្ឃកម្មទាំងអស់បាន វៀរលែងតែសង្ឃកម្ម៤យ៉ាងគឺ ឧបសម្បទាកម្ម ១ បវារណាកម្ម ១ កឋិនកម្ម ១ អព្ភានកម្ម ១ ធ្វើពុំបានឡើយ ។

សង្ឃបញ្ចវគ្គ គួរនឹងធ្វើសង្ឃកម្មទាំងអស់បាន វៀរលែងតែសង្ឃកម្ម២យ៉ាង គឺ ឧបសម្បទាកម្មក្នុងមជ្ឈិមប្រទេស១ និង អព្ភានកម្ម ១ ចេញ ធ្វើពុំបានឡើយ ។ សង្ឃទសវគ្គ គួរនឹងធ្វើសង្ឃកម្មទាំងអស់បាន វៀរលែងតែអព្ភានកម្ម ១ ចេញ ធ្វើពុំបានឡើយ ។ សង្ឃវីសតិវគ្គ គួរនឹងធ្វើសង្ឃកម្មទាំងអស់មានអព្ភានកម្មជាដើម បាន ឥតមានទើសទាស់អ្វីឡើយ ។ សង្ឃអតិរេកវីសតិវគ្គ គួរនឹងធ្វើសង្ឃកម្មទាំងអស់បានដោយប្រពៃ ។



www.elibraryofcambodia.org

( ដូចជាក្នុងកម្ពុជាដូនេះ ភិក្ខុសង្ឃមានច្រើន បើនឹងបំបួសភិក្ខុ-សាមណេរ ត្រូវនិមន្តលោកហត្ថបាសពី ២០អង្គឡើងទៅ ទើបគួរ (១) )។

ត្រង់ពាក្យថា ឧបសម្បទាចារ្យ គឺត្រូវឲ្យលោកសន្មតឧបសម្បទាបេក្ខៈ ឲ្យជាគង្គណិកនាមនោះ បានពិនិត្យបាលីនិងអដ្ឋកថា ដីកា ព្រមទាំងគណីជាដើម ដូចមានសេចក្តីអធិប្បាយតទៅនេះថា វេលាដែលធ្វើ នូវឧបសម្បទាកម្មនោះ សង្ឃត្រូវប្រជុំគ្នា ក្នុងទីដែលមានសីមា រួចអង្គុយឲ្យត្រឹមត្រូវតាមហត្ថបាស គឺអង្គុយឲ្យជិត ឃ្លាតចេញពីគ្នាចំនួន១ចំអាម តែឲ្យឃ្លាតឆ្ងាយពី១ចំអាមទៅ ពុំគួរឡើយ ។

ទើបភិក្ខុអ្នកឈ្លាសប្រតិពលអង់អាច ត្រូវសន្មតនាមឧបសម្បទាបេក្ខៈ និងសន្មតនាមព្រះឧបជ្ឈាយ៍ជាមុន ហើយសឹមសូត្រញត្តិជាដើមតទៅ ។

ក្នុងគម្ពីរមហាវគ្គ មិនឃើញមានពុទ្ធានុញ្ញាត ត្រង់កិច្ចដែលឲ្យនាមដល់ឧបសម្បទាបេក្ខៈ និងឲ្យនាមដល់ព្រះឧបជ្ឈាយ៍ ដោយសេចក្តីពិស្តារឡើយ ឃើញមានតែបាលីថា **អយំ ឥត្ថន្នាមោ ឥត្ថន្នាមស្ស អាយស្មតោ ឧបសម្បទាបេក្ខោ** ប្រែថា បុគ្គលមានឈ្មោះនេះ ជាអ្នកសំឡឹងយកនូវឧបសម្បទា ចំពោះលោកដ៏មានអាយុមានឈ្មោះនេះប៉ុណ្ណោះឯង ។

លុះកាលជាខាងក្រោយមក មានរឿងដំណាលអំពីព្រះមហាកស្សបត្ថេរថា នាមដើមរបស់លោកឈ្មោះ **បិប្ផលិ** តែដែលហៅថា **កស្សបៈ** នោះគឺហៅតាមគោត្ររបស់លោកទេ ព្រោះគោត្ររបស់លោក ជាកស្សបគោត្រ លោកមានបំណង នឹងបំបួសកូនសិស្សរបស់លោក ហើយចាត់បម្រើទៅនិមន្តព្រះអានន្ទត្ថេរ ឲ្យមកសូត្រញត្តិកម្មវាចា ។

---

១ សេចក្តីដែលមានក្នុងវង់ក្រចកនេះ ជាសេចក្តីយល់របស់សម្តេចព្រះធម្មលិខិតសង្ឃនាយក វត្តឧណ្ណាលោម ។

ឯព្រះអានន្ទត្ថេរ ប្រកែកមិនហ៊ានសូធ្យញត្តិឡើយ ព្រោះឃើញថា ព្រះមហាកស្សបត្ថេរនោះ ជាទីគោរពរបស់លោក តែសូធ្យញត្តិឡើងកាលណា មុខជានឹងចេញឈ្មោះថា បិប្ផលិ ៗ មិនខាន បានជាព្រះអានន្ទត្ថេរញញើត មិនព្រមទទួលសូធ្យញត្តិឡើយ ។

វេលានោះ ភិក្ខុទាំងឡាយនាំយកសេចក្ដីនោះ ទៅក្រាបបង្គំទូលព្រះមានព្រះភាគជាម្ចាស់ ទើបព្រះអង្គទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ គោត្តេនបិ អនុស្សាវេតុំ ប្រែថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុសូធ្យញត្តិកម្មវាចា ជាគោត្តនាមក៏បាន ។ សេចក្ដីក្នុងគម្ពីរមហាវគ្គមានតែប៉ុណ្ណេះ ។

ក្នុងគម្ពីរគតិយសមន្តប្បាសាទិកា អដ្ឋកថាមហាវគ្គ មានសេចក្ដីពន្យល់ថា ដែលព្រះពុទ្ធជាម្ចាស់ទ្រង់អនុញ្ញាត ឱ្យសូធ្យជាគោត្តនាមក៏បាន នោះសូធ្យតាមនាមគោត្តរបស់ព្រះមហាកស្សបថា មហាកស្សបស្ស ឧបសម្បទាបេក្ខោ ដូច្នេះវិញ ( បើគោត្តអ្វីឱ្យសូធ្យចេញឈ្មោះតាមគោត្តនោះក៏បាន ) ។

ក្នុងគម្ពីរចុល្លគណ្ឋីមហាវគ្គ និងគម្ពីរវិនយាលង្ការដីកាវិនយសង្គហៈ មានសេចក្ដីពិស្ដារដោយសព្វគ្រប់ លោកបានសម្ដែងពន្យល់ត្រង់ បិ ស័ព្ទ ដែលមានពុទ្ធានុញ្ញាតថា អនុជានាមិ ភិក្ខវេ គោត្តេន បិ អនុស្សាវេតុំ ត្រង់ បិ ស័ព្ទដែលប្រែថា ក៏បាននោះ មិនមែនសូធ្យញត្តិបានតែត្រឹមគោត្តនាមប៉ុណ្ណោះទេ ព្រោះ បិ ស័ព្ទនេះ អាចនឹងប្រមូលនាម៤យ៉ាងមកទៀត គឺ បកតិនាម១ គោត្តនាម១ នាគនាម១ តិស្សនាម១ ។

ឯបកតិនាម គឺឈ្មោះជាប្រក្រតី ( ឈ្មោះដើម ឬឈ្មោះកំណើត ) ឱ្យសូធ្យញត្តិថា ពុទ្ធរក្ខិតោ ធម្មរក្ខិតោ សង្ឃរក្ខិតោ ដូច្នេះជាដើម ។ គោត្តនាម ឱ្យសូធ្យញត្តិថា អាយស្មា កស្សបោ ដូច្នេះជាដើម ។ នាគនាម ឱ្យសូធ្យញត្តិថា អយំ នាគោ ដូច្នេះ ។ តិស្សនាមឱ្យសូធ្យញត្តិថា អយស្មតោ តិស្សស្ស ដូច្នេះ ។

នាមទាំង៤យ៉ាងនេះ សូត្របានតាមត្រូវការ ចង់យកនាមណាមួយមកសន្មត សូត្រក៏បាន បើសន្មតនាមដទៃផ្សេងអំពីនាមទាំង៤យ៉ាងនេះហើយ នោះបីសូត្រញត្តិកម្មវាចា ពាន់ចុំទ្នានចប់ក្តី ក៏មិនកើតបានជាតិក្ខុភាវៈទៀយ ឬនឹងសូត្រញត្តិនាម១ សូត្រអនុស្សាវនៈបទ១ ផ្សេងគ្នាយ៉ាងនេះ ក៏មិនកើតបានជាភិក្ខុភាវៈដែរ ដូចសូត្រញត្តិខាងដើមជាបកតិនាម ដល់មកសូត្រអនុស្សាវនៈខាងចុង ត្រឡប់ជាសូត្រគោត្តនាមវិញ ក៏មិនកើតជាភិក្ខុភាវៈទៀយ បើញត្តិខាងដើមដោយនាមអ្វីត្រូវសូត្រអនុស្សាវនៈដោយនាមនោះ ដូចជាសូត្រញត្តិខាងដើមជាបកតិនាម ត្រូវសូត្រអនុស្សាវនៈខាងចុងជាបកតិនាមដូចគ្នា ឬ សូត្រញត្តិខាងដើមជាគោត្តនាម ត្រូវសូត្រអនុស្សាវនៈខាងចុងជាគោត្តនាម ដូចគ្នា ទើបគួរ ។

មួយទៀត បើញត្តិខាងដើមដោយបកតិនាម ឬ គោត្តនាមហើយ ដល់មកសូត្រអនុស្សាវនៈខាងចុង ត្រឡប់ទៅជាសូត្រនាគនាម តិស្សនាមវិញក្តី ឬ សូត្រខាងដើមជានាគនាម តិស្សនាម ដល់មកសូត្រអនុសាវនៈខាងចុង ត្រឡប់ទៅជាសូត្រ បកតិនាម គោត្តនាមវិញក្តី ក៏មិនគួរទៀយ ។

បើសូត្រញត្តិខាងដើម ជាបកតិនាម គោត្តនាម ដល់មកសូត្រអនុសាវនៈខាងចុង ក៏សូត្រជាបកតិនាម គោត្តនាមវិញដដែល ឬ សូត្រញត្តិខាងដើមជានាគនាម តិស្សនាម ដល់មកសូត្រអនុស្សាវនៈខាងចុង ក៏សូត្រជានាគនាម តិស្សនាមវិញដដែល ដូច្នេះទើបគួរ ។

បើសន្មតឧបសម្បទាបេក្ខៈជាបកតិនាម ត្រូវសន្មតព្រះឧបជ្ឈាយ៍ ជាបកតិនាមដូចគ្នា ។

បើសន្មតឧបសម្បទាបេក្ខៈជាគោត្តនាម ត្រូវសន្មតព្រះឧបជ្ឈាយ៍ ជាគោត្តនាមដូចគ្នា ។

បើសន្មត ឧបសម្បទាបេក្ខៈជានាគនាម ត្រូវសន្មតព្រះឧបជ្ឈាយ៍ជាតិស្សនាម យ៉ាងនេះឈ្មោះថា **អនុបុព្វនាម** គឺឲ្យឈ្មោះតាមលំដាប់គ្នា បើសន្មតឲ្យខុសអំពីលំដាប់នេះហើយ សូត្រញត្តិកម្មវាចាឧបសម្បទាកម្មពុំទទែងទៀយ ។

ម្ខាងទៀត ឯបកតិនាមនិងគោត្តនាមក្នុងប្រទេសទាំងអស់នេះ បកតិនាមនិងគោត្តនាមនៃមនុស្សខ្លះ សមគួរតាមបាលីភាសា បកតិនាមនិងគោត្តនាមនៃមនុស្សខ្លះ ពុំសមគួរតាមបាលីភាសាឡើយព្រោះហេតុដូច្នោះ បានជាព្រះគន្ធរចនាចារ្យ លោកចារិកទុកក្នុងគម្ពីរចុល្លគណ្ឋិមហាវគ្គជារបៀបបាលី សម្រាប់សូធ្យញត្តិកម្មវាចាជា២បែប គឺ បាលីសម្រាប់សូធ្យញត្តិកម្មវាចា ជាបកតិនាមថា

សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមោ
ឥត្ថន្នាមស្ស អាយស្មតោ ឧបសម្បទាបេក្ខោ ។ល។
ឯវមេតំ ធារយាមីតិ បកតិនាមវសេន អយំ
ញត្តិកម្មវាចា ។ បាលីសម្រាប់សូធ្យញត្តិកម្មវាចា ដោយអំណាចនៃបកតិនាមដូច្នេះជាបែប១ ។

ឯបាលីសម្រាប់សូធ្យញត្តិកម្មវាចា ជា សព្វសង្គាហិកនាមថា

សុណាតុ មេ ភន្តេ សង្ឃោ នាគោ អាយស្មតោ
តិស្សស្ស ឧបសម្បទាបេក្ខោ ។ល។ ឯវមេតំ ធារយា-
មីតិ សព្វសង្គាហិកនាមវសេន អយំ ញត្តិកម្មវាចា ។
បាលីសម្រាប់សូធ្យញត្តិកម្មវាចា ដោយអំណាចនៃសព្វសង្គាហិកនាម ដូច្នេះជាបែប ១ ។

ដោយហេតុនេះហើយ បានជាអ្នកប្រាជ្ញអំពីបុរាណ បានដកយកនាគនាម តិស្សនាម មកចារិកទុកក្នុងភាណវារៈ ដែលហៅថា ភាណវារៈសម្រាប់សូធ្យបំបួសនាគ ជាប់មានតមកដល់សព្វថ្ងៃនេះ ។

ម្យ៉ាងទៀត នាគនាម និងតិស្សនាមនេះ ក្នុងគម្ពីរខ្លះលោកហៅថា តំខណិកនាម ជានាមសម្រាប់សូធ្យញត្តិកម្មវាចា ចំពោះតែក្នុងខណៈមួយរំពេចនោះប៉ុណ្ណោះ ។

ឯក្នុងគម្ពីរចុល្លគណ្ឋិមហាវគ្គ នាគនាម និងតិស្សនាមទាំងពីរនេះ លោកហៅថាសព្វសង្គាហិកនាម វិញ ជានាមសម្រាប់សង្គ្រោះដល់កុលបុត្រទាំងឡាយក្នុង

នានាប្រទេស ដែលមានបកតិនាមនិងគោត្តនាម កុំសមគួរតាមបាលីភាសា ដូចយ៉ាងឈ្មោះ កែ កៅ ពៅ នៅ មែ ម៉ែន ជាដើម នឹងយកមកសូត្រមិនកើត ត្រូវឲ្យសន្មតនាមថា ឆវគ្គៈ វិញ បើសន្មតនាមឧបសម្បទាបេក្ខៈ ថា ឆវគ្គៈ ហើយ នាមឧបជ្ឈាយ៍ក៏ត្រូវផ្លាស់សន្មតថា តិស្សៈ ដែរ ដើម្បីឲ្យស្របគ្នា ។ លោកបានកំណត់ពាក្យទុកថា ឥតោ បដ្ឋាយ សព្វសង្គាហិកនាមេនេវ ញត្តិកម្មវាចា គរេហតព្វា ប្រែថា ចាប់ផ្ដើមតាំងអំពីកាលនេះទៅ ញត្តិកម្មវាចា គឺ ឧបសម្បទាចារ្យទាំងឡាយ គួរកាន់យកដោយអំណាចនៃសព្វសង្គាហិកនាមចុះ ។

មែនពិត សព្វសង្គាហិកនាមនេះ ជានាមងាយសូត្រស្រួលជាងបកតិនាមនិងគោត្តនាម បើទុកជាឧបសម្បទាបេក្ខៈ មានបកតិនាមជាបាលី ដូចយ៉ាងឈ្មោះ នន្ទ ចន្ទ យស ព្រហ្ម សុខ សោម ជាដើម ដែលគួរដល់កម្មវាចាយ៉ាងនេះ ក៏គង់តែនៅលំបាក ដល់ឧបសម្បទាចារ្យខ្លះ ដែលមិនស្ទាត់ក្នុងដំណើរបញ្ចូលបាលី បើហាត់សូត្រសព្វសង្គាហិកនាម ឲ្យចាំស្ទាត់ស្រេចតែម្ដងស្រួលណាស់ ជាឧបការមិនឲ្យភ្លាត់ក្នុងការសូត្រ ។

ឯគម្ពីរចុល្លគណ្ឋិមហារត្តនោះ បានសង្កេតពិនិត្យមើលទៅឃើញថា លោករចនាតាមមតិអដ្ឋកថាចារ្យ និងដីកាចារ្យទាំងឡាយ ដែលលោកជាបពុទ្ធាធិប្បាយច្បាស់ប្រាកដ មិនសង្ស័យ មិនភ្លៀង ។ ក្នុងអដ្ឋកថាវិន័យមានពាក្យថា គណ្ឋិបទ ៗ ដូច្នេះជាញឹកញយ ព្រោះអាស្រ័យពាក្យនេះ ទើបព្រះគន្ថរចនាចារ្យទាំងឡាយ លោករៀបចំគម្ពីរអធិប្បាយ សេចក្ដីវិន័យត្រង់ដែលសង្ខេបនោះ ឲ្យពិស្ដារច្បាស់លាស់ឡើង សន្មតនាមថា គម្ពីរគណ្ឋិ ។ គម្ពីរនេះអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់ប្រទេស ជឿជាក់ថា ជាគម្ពីរត្រឹមត្រូវ ព្រោះហេតុនេះបានជាពុទ្ធសាសនិកជន ក្នុងលង្កាទ្វីប ភូមា សៀម លាវ និងខ្មែរយើងកាន់តាំងពីយូរអង្វែងណាស់មកហើយ ដរាបដល់សព្វថ្ងៃនេះ ប្រកាន់យកនាមថា

នាគៈ តិស្សៈ នេះ មកស្ទុតក្នុងការឲ្យឧបសម្បទាដល់កុលបុត្រ តាមសមគួរដល់សេចក្តីគាប់ចិត្តរបស់ជំនុំសង្ឃព្រោះយល់ឃើញថា បកតិនាម គោត្តនាម និង នាគនាម តិស្សនាម នេះប្រើបានដូចគ្នា ប៉ុន្តែ នាគនាម តិស្សនាម ងាយស្រួលស្តាប់ជាង បកតិនាម និង គោត្តនាម ។

ត្រង់ពាក្យថា ឧបសម្បទាកម្មជាបត្តកល្លៈ គឺមានកាលដ៏សមគួរដល់សង្ឃនោះ អធិប្បាយថា ឧបសម្បទាកម្ម ត្រូវធ្វើឲ្យប្រកបដោយអង្គទាំង ៥ ទើបបានឈ្មោះថា បត្តកល្លៈ មានកាលដ៏សមគួរដល់សង្ឃ ។

## ឯអង្គទាំង ៥ នោះគឺ

វត្ថុសម្បទា បរិបូណ៌ដោយវត្ថុ ១ អន្តរាយិកេហិ ធម្មេហិ ចស្ស បរិសុទ្ធតា គឺភាវៈនៃឧបសម្បទាបេក្ខៈនោះ បរិសុទ្ធផុតស្រឡះចាកអន្តរាយិកធម៌ទាំងឡាយ ១ សីមាសម្បទា បរិបូណ៌ដោយសីមា ១ បរិសសម្បទា បរិបូណ៌ដោយបរិស័ទ ១ បុព្វកិច្ចនិដ្ឋានំ ញុំាងកិច្ចជាខាងដើមឲ្យសម្រេច ១ ។

អង្គទី ១ វត្ថុសម្បទា អធិប្បាយថា បរិបូណ៌ដោយវត្ថុ គឺឧបសម្បទាបេក្ខៈ អ្នកសំឡឹងនូវឧបសម្បទា មិនមែនជាអភព្វបុគ្គលទាំង ១១ យ៉ាង គឺ បណ្ឌកោ មនុស្សខ្ទើយ ១ ឧភតោព្យញ្ជនកោ មនុស្សមានភេទ២ជួនកាលជាប្រុស ជួនកាលជាស្រី១ ថេយ្យសំវាសកោ មនុស្សលួចសង្វាស គឺមិនមែនជាភិក្ខុ ហើយក្លែងខ្លួនជាភិក្ខុ ធ្វើសង្ឃកម្មជាមួយនឹងភិក្ខុបរិស័ទជាដើម ១ តិត្ថិយបក្កន្តកោ មនុស្សរត់ចូលទៅតិរ្ថិយ ១ តិរច្ឆានោ សត្វតិរច្ឆាន១ មាតុឃាតកោ មនុស្សសម្លាប់មាតា ១ បិតុឃាតកោ មនុស្សសម្លាប់បិតា ១ អរហន្តឃាតកោ មនុស្សសម្លាប់ព្រះអរហន្ត ១ លោហិតុ-

ច្បានគេា មនុស្សទ្រុះព្រះលោហិតព្រះពុទ្ធឲ្យពុរពងឡើង ១ សង្ឃភេទ-កោ មនុស្សផ្តាច់បែកសង្ឃ ១ ភិក្ខុនីទូសកោ មនុស្សប្រទុស្តនាងភិក្ខុនី១ បុគ្គលទាំង ១៧ យ៉ាងនេះ សូម្បីតែបួសជាសាមណេរក៏ពុំបានឡើយ ។

បុគ្គល ២ ទៀតគឺ ឩនវីសតិវស្សោ មានអាយុមិនគ្រប់ ២០ឆ្នាំ១ អន្តិមវត្ថុកោ ត្រូវអាបត្តិបារាជិក កាលពីនៅជាភិក្ខុ១ ។ បុគ្គលទាំង២ នេះនឹងបួសជាភិក្ខុមិនបាន តែបួសជាសាមណេរបាន ។

ឧបសម្បទាបេក្ខៈ ដែលមិនមែនជាបុគ្គលទាំង ១៣ យ៉ាងនេះ ទើបបានឈ្មោះថា បរិសុទ្ធដោយវត្ថុ ។

អង្គទី ២ អធិប្បាយថា អាពាធទាំង ៥ យ៉ាង គឺ កុដ្ឋំ រោគឃ្លង់ ១ គណ្ឌោ រោគពកឬបូស ១ កិលាសោ រោគស្រែង១ សោសោ រោគហឹត ១ អបមារោ រោគឆ្កួតជ្រូក ១ និងកុលបុត្រ ដែលមាតាបិតាមិនអនុញ្ញាតឲ្យ១ និងធម៌ជាទោសទាំងឡាយមានកំបុតដៃ-ជើងជាដើម១ បានឈ្មោះថា អន្តរាយិកធម៌ ។ ឧបសម្បទាបេក្ខៈ ដែលប្រាសចាកធម៌ជាទោសទាំងអស់នោះ ទើបបានឈ្មោះថា បរិសុទ្ធផុតស្រឡះចាកអន្តរាយិកធម៌ ។

អង្គទី ៣ អធិប្បាយថា សីមាដែលខុសទាំង១១យ៉ាងគឺ

អតិខុទ្ទកា សីមាតូចពេក ភិក្ខុ២១អង្គ អង្គុយធ្វើសង្ឃកម្មមិនបាន ១ អតិមហា សីមាធំពេកហួសកំណត់៣យោជន៍ឡើងទៅ ១ ខណ្ឌនិមិត្តា សីមាខាននិមិត្តដាច់មិនតគ្នា គឺថា ភិក្ខុសូត្រនិមិត្តទិសខាងកើតជាដើម ទៅភាយលំដាប់ទិសហើយ មិនសូត្រនិមិត្តទិសខាងកើតថែមទៀត ១ ឆាយានិមិត្តា សីមាដែលភិក្ខុយកស្រមោលភ្នំជាដើម ជានិមិត្ត១ អនិមិត្តា សីមាដែលឥតមានវត្ថុអ្វីមួយ ជានិមិត្ត ១ ពហិសីមេ ឋិតសម្មតា សីមាដែលសង្ឃឈរនៅខាងក្រៅសីមាហើយសន្មត ១ នទិយា សម្មតា សីមាដែល

សង្ឃសន្មតដោយស្ទឹងឬទន្លេ ១ សមុទ្ទ សម្មុតា សីមាដែលសង្ឃសន្មត ដោយសមុទ្រ ១ ជាតស្សរេ សម្មុតា សីមាដែលសន្មតក្នុងជាតស្រះ គឺស្រះកើតឯង ឥតមានអ្នកណាជីក ១ សីមាយ សីមំ សម្ភិន្ទន្តេន សម្មុតា សីមាដែលសង្ឃសន្មត រំលាយសីមាភិក្ខុដទៃដោយសីមារបស់ខ្លួន១ សីមាយ សីមំ អជ្ឈោត្ថរន្តេន សម្មុតា សីមាដែលសង្ឃសន្មត គ្របសីមាភិក្ខុដទៃ ដោយសីមារបស់ខ្លួន ១ ។ សីមាដែលប្រាសចាកសីមាខុស ទាំង១១ យ៉ាងនេះ បានឈ្មោះថា បរិបុណ៌ដោយសីមា ។

អង្គទី ៤ អធិប្បាយថា ភិក្ខុជាបរិស័ទដែលប្រកបដោយអង្គទាំង ៤ យ៉ាង គឺ គណៈសង្ឃ ៥ អង្គ ឬ ១០ អង្គ ដែលមានសង្វាសស្មើគ្នា មិនបានត្រូវនូវអាបត្តិបារាជិកបានប្រជុំក្នុងសីមា ១ មិនលះបង់ហត្ថបាស ១ ភិក្ខុដែលគួរដល់ឆន្ទៈ ហើយបាននាំមកនូវឆន្ទៈ ១ ភិក្ខុទាំងឡាយដែលនៅក្នុងទីចំពោះមុខព្រះក្រៀងគ្នា មិនបានឃាត់ហាមកម្ម១ វជ្ជនិយបុគ្គល បុគ្គលដែលសង្ឃគប្បីវៀរ ទាំង ២១ ពួក មានគ្រហស្ថជាដើម ១ ។ ភិក្ខុដែលប្រកបដោយអង្គទាំង៤នេះ ទើបបាន ឈ្មោះថា បរិបូណ៌ដោយបរិស័ទ ។

អង្គទី ៥ អធិប្បាយថា កិច្ចជាខាងដើមនៃញត្តិចតុត្ថកម្មវាចានោះ មាន ៨ យ៉ាង គឺឲ្យនូវឧបសម្បទាបេក្ខៈកាន់យកនូវព្រះឧបជ្ឈាយ៍ ១ ឧបសម្បទាចារ្យ ត្រូវប្រាប់នូវបាត្រនិងចីវរ ១ ឧបសម្បទាចារ្យត្រូវប្រាប់ឲ្យឧបសម្បទាបេក្ខៈ ចេញទៅឈរក្រៅហត្ថបាសហើយ ត្រូវឲ្យសន្មតខ្លួនដើម្បីប្រៀនប្រដៅនាគ ១ កិច្ចដែលសន្មតខ្លួនរួចហើយចេញទៅប្រដៅនាគ ១ កិច្ចដែលប្រៀនប្រដៅនាគរួចហើយ ត្រឡប់មកសូត្រប្រកាសប្រាប់សង្ឃ និង ហៅឧបសម្បទាបេក្ខ ឲ្យចូលមកក្នុងហត្ថ-បាស ១ កិច្ចដែលឲ្យឧបសម្បទាបេក្ខៈថ្វាយបង្គំនូវបាទានៃព្រះសង្ឃ ហើយសូមនូវឧបសម្បទាចំពោះការកសង្ឃ ១ កិច្ចដែលឲ្យឧបសម្បទាបេក្ខៈ សូមនូវឧបសម្បទារួចហើយ ទើបសូត្រសន្មតខ្លួន នឹងសួរអន្តរាយិកធម៌ក្នុងកណ្តាលការកសង្ឃ ១ កិច្ចដែលសន្មតខ្លួនរួចហើយ សួរនូវអន្តរាយិកធម៌ក្នុងកណ្តាលជំនុំការកសង្ឃ ១ ។



www.elibraryofcambodia.org

សម្រេចកិច្ចទាំង ៥ នេះ បានឈ្មោះថាពួកកិច្ចជាខាងដើមនៃញត្តិចតុត្ថកម្មវាចាឲ្យសម្រេច ។

ឧបសម្បទាកម្ម ដែលប្រកបដោយអង្គទាំង ៥ ដូចបានអធិប្បាយមកនេះ ទើបបានឈ្មោះថា **បត្តកល្លៈ** មានកាលដ៏សមគួរដល់សង្ឃ ឧបសម្បទាក៏កើតឡើងពេញបរិបូណ៌ តែបើមិនបានប្រកបព្រមដោយអង្គទាំង ៥ នេះទេ មិនបានឈ្មោះថា **បត្តកល្លៈ** មានកាលដ៏សមគួរដល់សង្ឃឡើយ បានឈ្មោះថា វិបត្តិឧបសម្បទាទៅវិញ ។

៦ **វិបត្តិ** នោះ ប្រែថា ខុស ឬ ខ្វះខាត មាន ៥ យ៉ាងគឺ

**វត្ថុវិបត្តិ** វត្ថុខុសគឺអភព្វបុគ្គល ១១ យ៉ាង និង បុគ្គលដែលមិនគួរឧបសម្បទា ២ យ៉ាងទៀត ដូចបានអធិប្បាយមកក្នុងវត្ថុសម្បទារួចហើយ បានឈ្មោះថា វត្ថុវិបត្តិ ១

**ញត្តិវិបត្តិ** គឺញត្តិខុស សូត្រញត្តិមិនចេញឈ្មោះវត្ថុ គឺបុគ្គលដែលប្រាថ្នានូវឧបសម្បទា មានឈ្មោះថា **នាគៈ** ជាដើម ឬ មិនចេញឈ្មោះការកសង្ឃ និងមិនចេញឈ្មោះព្រះឧបជ្ឈាយ៍ មានឈ្មោះថា **តិស្សៈ** ជាដើម ឬ មិនសូត្រញត្តិ សូត្រតែអនុស្សាវនៈ ឬ សូត្រអនុស្សាវនៈមុន ទើបសូត្រញត្តិខាងក្រោយវិញ បានឈ្មោះថា ញត្តិវិបត្តិ ១

**អនុស្សាវនវិបត្តិ** គឺអនុស្សាវនៈខុស មិនចេញឈ្មោះវត្ថុ គឺបុគ្គលដែលប្រាថ្នានូវឧបសម្បទា មានឈ្មោះថា **នាគៈ** ជាដើម ឬមិនចេញឈ្មោះការកសង្ឃមិនចេញឈ្មោះព្រះឧបជ្ឈាយ៍មិនសូត្រកម្មវាចាសូត្រតែញត្តិ៤ផង កុំនោះសោតសូត្រឲ្យភ្លាត់បានអក្ខរៈ គឺ **សិថិល** ជា **ធនិត** ។ ជា **សិថិល** **និគ្គហិត** ជា **វិមុត្ត** ។ ជា **និគ្គហិត** សូត្រខុសខ្យល់កំណើតអក្ខរៈ មាន **ឧន្តជៈ** ជាដើម ឬ មិនសូត្រអនុស្សាវនៈឡើយ សូត្រតែញត្តិ បានឈ្មោះថា អនុស្សាវនវិបត្តិ ១

**សីមាវិបត្តិ** សីមាខុសទាំង ១១ យ៉ាង ដូចបានអធិប្បាយមកក្នុងសីមាសម្បទារួចហើយ បានឈ្មោះថា សីមាវិបត្តិ ១



www.elibraryofcambodia.org

**បរិសវិបត្តិ** បរិស័ទខុសមិនប្រកបដោយអង្គ ៨ ដូចបានអធិប្បាយមកក្នុងបរិសសម្បទារួចហើយ បានឈ្មោះថា បរិសវិបត្តិ ១ ។

វិបត្តិទាំង ៥ យ៉ាងនេះ ឧបសម្បទាកម្ម ប្រកបដោយវិបត្តិណាមួយ ឧបសម្បទាខូច មិនកើតជាភិក្ខុភាវៈក្នុងព្រះពុទ្ធសាសនាឡើយ ។

អធិប្បាយមកក្នុងឧបសម្បទាវិធី ចប់សេចក្ដីតែប៉ុណ្ណេះ ។

## ៦· អធិប្បាយក្នុងអនុសាសនវិធី

ត្រង់សេចក្ដីថា និស្ស័យ ៤ យ៉ាងខាងដើមនោះ ព្រះវិនយធរ មិនគួរនឹងប្រាប់ដល់កុលបុត្រ ដែលពុំទាន់បានឧបសម្បទាឲ្យដឹងជាមុនឡើយ ។

ព្រោះមានពុទ្ធប្បញ្ញត្តិហាម ក្នុងគម្ពីរមហាវគ្គថា មិនឲ្យភិក្ខុប្រាប់និស្ស័យ ៤ យ៉ាង ដល់អនុបសម្បន្នឲ្យដឹងជាមុនទេ លុះតែបានឧបសម្បទារួចហើយ ទើបមានពុទ្ធានុញ្ញាតឲ្យប្រាប់ ក្នុងលំដាប់បន្ទាប់អំពីឧបសម្បទាកម្មនោះមក ។

ព្រះវិន័យធរ ត្រូវប្រាប់កិច្ចទាំង ៣ យ៉ាង មុននិស្ស័យទាំង ៤ ដូច្នេះថា ស្រមោលនៃសរីរៈបានចំនួនប៉ុណ្ណេះ ប្រមាណនៃរដូវមានប៉ុណ្ណេះ ចំណែកនៃថ្ងៃមានប៉ុណ្ណេះ ហើយពន្យល់រួបរួមស្រមោលរដូវ និងចំណែកនៃថ្ងៃ ឲ្យនវកភិក្ខុ (ភិក្ខុថ្មី) បានដឹងច្បាស់ដូច្នេះថា អ្នកបើមានភិក្ខុទាំងឡាយដទៃសួរថា អ្នកបាននូវឧបសម្បទាដូចម្ដេច ឆាយាប៉ុន្មាន រដូវប៉ុន្មាន ចំណែកនៃថ្ងៃប៉ុន្មាន ត្រូវអ្នកប្រាប់ថា ខ្ញុំមានវស្សាប៉ុណ្ណេះ ឆាយាខ្ញុំប៉ុណ្ណេះ រដូវខ្ញុំឈ្មោះនេះ ចំណែកនៃថ្ងៃពេលប៉ុណ្ណេះ ដើម្បីឲ្យដឹងចំនួនឆាយា រដូវ ចំណែកនៃថ្ងៃ កំណត់ថា ចាស់ ខ្ចី វស្សា ដើម្បីនឹងអង្គុយមុនក្រោយ តាមលំដាប់លំដោយអាសនៈ និងហៅគ្នាទៅវិញទៅមក ឲ្យសមគួរតាមពុទ្ធានុញ្ញាត បើខ្លួនខ្ចីវស្សា ត្រូវពោលទៅរកចាស់វស្សាថា **ភន្តេ** បើខ្លួនចាស់វស្សាវិញ ត្រូវពោលទៅរកលោកខ្ចីវស្សាថា **អាវុសោ** ប៉ុណ្ណេះឯង ។ ឬនិងសំពះថ្វាយបង្គំគ្នា ក៏ត្រូវតែកំណត់តាមវស្សាចាស់ និងខ្ចី ភិក្ខុមានវស្សាចាស់ជាងមិនត្រូវសំពះភិក្ខុមានវស្សាខ្ចីជាងខ្លួនឡើយ ។

អធិប្បាយមកក្នុងអនុសាសនវិធី ចប់តែប៉ុណ្ណេះ ។



www.elibraryofcambodia.org

# បទានុក្រម

## ប្រែសព្ទតាមលំដាប់បទ

## ដែលបាននាំយកមកប្រើក្នុងសៀវភៅនេះ

| បទានុក្រម | ទំព័រ | បន្ទាត់ |
|---|---|---|
| **អក្ខរៈ** ម(១): (សំ(២) អក្សរ) ន (៣) ស្នូរសំឡេងដែលលាន់ឮព្រោកដឡើង ទន់ទោតាមសម្តីរបស់ជាតិផ្សេងៗ ឬ ស្នាមតំឧសជាតួរាងដែលល្មមកំណត់ចំណាំបានតាមការស្រួល | ១ | ៧ |
| **អក្ខរប្បភេទ** ម. (សំ. ប្រភេទ) ន. ផ្នែក, ចំណែក ឬ សេចក្តីផ្សេងនៃអក្សរ | ៦ | ១១ |
| **អក្ខរវិធី** ម.ន. របៀបផែនអក្សរ ឬ គម្រោងវេយ្យាករណ៍ដែលនិយាយដោយតួអក្សរ និង ការអានការសរសេរ | ១ | ៣ |
| **អង្គ** ម. (សំ. អង្គ) ន. ចំណែករបស់រាងកាយ, អវយវៈ, តួខ្លួន, (ក្នុងរាជស័ព្ទថាព្រះអង្គ) | ២០ | ១ |
| **អតិរេកលាភ** ម.ន. លាភច្រើន ឬ លាភដែលបានច្រើនលើសប្រក្រតី | ៤១ | ៥ |
| **អធិបតី** ម.ន. អ្នកធំ, អ្នកគ្រប់គ្រង ឬអ្នកដែលជាប្រធាន | ៥៣ | ៩ |
| **អធិសីលសិក្ខា** ម.ន ការសិក្សាក្នុងសីលដ៏ខ្ពង់ខ្ពស់ ឬឧក្រិដ្ឋ, គុណជាតិដែលគួរសិក្សា៣យ៉ាង គឺ អធិសីល អធិចិត្ត អធិប្បញ្ញា ហៅថា ត្រៃសិក្ខា | ២៥ | ១៩ |

១ មគធ ។ ២ សំស្ក្រឹត ។ ៣ នាមសព្ទ



www.elibraryofcambodia.org

| បទានុក្រម | ទំព័រ | បន្ទាត់ |
|---|---|---|
| **អន្តរាយិកធម៌** ម.សំ.ន. ធម៌ជាទីតាំងនៃសេចក្ដីអន្តរាយ គឺហេតុដែល ជាទំនាស់ផ្សេង ៗ ដូចហេតុដល់ការឧបសម្បទា ៨ យ៉ាង មានរោគឃ្លង់ជាដើម | ១៣ | ១ |
| **អភិវាទនកម្ម** ម.ន. ការក្រាបសំពះ ការថ្វាយបង្គំដោយគោរព | ២៣ | ១៥ |
| **អភិសមាចារិកវត្ត** ម.ន. កិច្ចដែលគួរប្រព្រឹត្តដោយល្អ គឺធ្វើមារយាទ ឬចក្ខុ ឲ្យរៀបរយ គឺឲ្យមានសណ្ដាប់ធ្នាប់ | ៧៣ | ៩ |
| **អាបត្តិ** ប.ន. សេចក្ដីល្មើស, ទោស, ទោសដែលកើតព្រោះសេចក្ដីល្មើស និង វិនយបញ្ញត្តិដែលព្រះសម្មាសម្ពុទ្ធទ្រង់ហាម | ៩ | ១០ |
| **ឧត្តរិមនុស្សធម៌** ប.ន. គុណភាពរបស់មនុស្សដ៏ក្រៃលែង ឬគុណវិសេសដ៏ក្រៃលែងជារបស់មនុស្ស | ៤៥ | ៧ |
| **ឧបសម្បទា** ម.ន. ដល់ព្រមដោយល្អនូវភាវៈខាងលើ គឺភាវៈជាភិក្ខុ, ឬ ការបួសជាភិក្ខុ, ចូលទៅដល់ព្រម គឺចូលទៅព្រមដោយបាតិៈមោក្ខសំវរសីល តាមពុទ្ធបញ្ញត្តិ, ឬដល់ព្រមដោយសិក្ខា និងអាជីវៈរបស់ភិក្ខុទាំងឡាយ, ពាក្យនេះបើតាមរបៀបបាលីភាសា ជានាមស័ព្ទតែម្យ៉ាង តែខ្មែរយើង នាំយកមកប្រើជាកិរិយាស័ព្ទថា ឧបសម្បទាជាភិក្ខុ | ២៦ | ៩ |
| **ឧបសម្បទាកម្ម** ម.ន. ការឲ្យឧបសម្បទា ការបំបួសភិក្ខុ | ២៩ | ៤ |



www.elibraryofcambodia.org

| បទានុក្រម | ទំព័រ | បន្ទាត់ |
|---|---|---|
| **ឧបោសថ** ម.ន. ធម៌ គឺសីល ដែលបុគ្គលអ្នកមានប្រយោជន៍ ដោយបុណ្យគប្បីអាស្រ័យនៅ, សភាវធម៌ជាគ្រឿងផុតខ្ទះកិលេស , ថ្ងៃជាទីរក្សានូវធម៌ដែលបុគ្គលគប្បីរក្សា, ការរក្សាសីល ៨ របស់គ្រហស្ថ , ការសម្តែងបាតិមោក្ខ របស់ភិក្ខុរាល់ ៗ កន្លះខែ | ១១ | ៤ |
| **ឧបោសថកម្ម** ម.ន. ការធ្វើឧបោសថ | ១១ | ៦ |
| **កាយប្បណាម** ម.(សំ.ប្រណាម) ន. ការថ្វាយបង្គំដោយកាយ | ១៤ | ៨ |
| **កាយគតាសតិកម្មដ្ឋាន** ម.ន.កម្មដ្ឋានធានសតិរលឹកទៅក្នុងកាយ | ១៧ | ១៣ |
| **កុលបុត្រ** សំ. (ម.កុលបុត្ត) ន.កូនអ្នកមានត្រកូល,កុលបុត្រចែកជា២គឺ ជាតិកុលបុត្រ កូនអ្នកមានត្រកូលខ្ពស់អំពីកំណើត,អាចារកុលបុត្រកូនដែល កើតក្នុងត្រកូលណាក៏ដោយ ឲ្យតែបរិបូណ៌ដោយកិរិយាមារយាទសណ្តាប់ធ្នាប់ល្អ ឬ បានចូលមកបួសក្នុងពុទ្ធសាសនា | ១៤ | ២ |
| **ឃរាវាស** ម.ន. ជនអ្នកនៅគ្រប់គ្រងផ្ទះ, ជនដែលមិនបួស | ១៤ | ៥ |
| **ញត្តិ** ម.ន.ពាក្យញុំាងសង្ឃឲ្យដឹង,ពាក្យផ្តៀងសង្ឃ គឺវាចាសម្រាប់ប្រកាសឲ្យដឹងថានឹងធ្វើការអ្វី ពាក្យនេះជាគូគ្នានឹងអនុស្សាវនាគឺពាក្យប្រឹក្សាឬពាក្យពិភាក្សាគ្នានឹងគ្នា របស់សង្ឃ ដែលព្រមព្រៀងគ្នាធ្វើតាមបញ្ញត្តិនោះៗ មាន៣គឺ ១. ញត្តិកម្ម កម្មដែល | | |

| បទានុក្រម | ទំព័រ | បន្ទាត់ |
|---|---|---|
| ធ្វើដោយតាំងញត្តិ មិនមានអនុស្សាវនា ដូចហៅឧបសម្បទាបេក្ខៈ ដែលបានសាកសួរអន្តរាយិកធម៌ហើយ ឱ្យចូលមកក្នុងពួកសង្ឃ ២ - ញត្តិទុតិយកម្ម កម្មមានវាចាតម្រប់ពីរទាំងញត្តិ គឺកម្មដែលធ្វើដោយតាំងញត្តិ ហើយសូត្រអនុស្សាវនាតែម្តង ដូចឱ្យសំពត់កឋិន (សូត្រកឋិន) ៣ - ញត្តិចតុត្ថកម្ម កម្មមានវាចាតម្រប់ ៤-ទាំងញត្តិ គឺកម្មដែលធ្វើដោយតាំងញត្តិហើយ អនុសាវនាបីដង ដូចការឱ្យឧបសម្បទា ( សូត្រ ញត្តិបំបួសភិក្ខុ )។ កម្មដែលសូត្រអនុស្សាវនាបីដង លោករាប់ថាជាកម្មដ៏សំខាន់, ការកសង្ឃ ដែលនៅក្នុងទីប្រជុំនោះ នឹងមានឱកាសត្រិះត្រិះរិះពិចារណាសេចក្តីនោះ យ៉ាងវែង | ៥៣ | ៤ |
| **ត្រៃសរណគមន៍** ម.សំ. (តិសរណគមន)ន. សរណៈ ប្រែថាទីពឹង,ទីពំនាក់,ទីអាស្រ័យ,ទីរង្គារ,គ្រឿងការពារ , គ្រឿងជ្រកកោន ; ត្រៃ ប្រែថាបី ; សរណគមន៍ ប្រែថា ការកាន់យក ព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង | ១០ | ១៦ |
| **ទណ្ឌកម្ម** ម.ន. ការធ្វើអាជ្ញា,ការធ្វើទោស | ៥៣ | ១១ |
| **នាគ** ម.សំ ន.ពស់,ពស់មានសិរ,ដំរី, ដើមខ្ទឹង,សំណេភក់,សំណាបាំហាំង,អ្នកប្រសើរ , អ្នកមិនធ្វើបាប ហៅបុរសដែលបម្រុងខ្លួននឹងបួសថានាគ, បើស្ត្រីថា នាគិនី ឬ នាគី នាគស័ព្ទនេះ ប្រែបានច្រើន យ៉ាងដូចថាមកហើយ តែក្នុងទីដែលលោកយកមក | | |



www.elibraryofcambodia.org

ះប្រិផាឈ្មោះនៃឧបសម្បទាបេក្ខៈ ថា "នាគ, នោះលោកសំដៅយកចំពោះតែត្រង់សេចក្ដីថា អ្នកប្រសើរ ឬអ្នកមិនធ្វើបាបតែម្យ៉ាងចុំណោះ វិគ្រោះថា " ន អាគុំ ករោតីតិ នាគោ អ្នកណាមិនធ្វើបាប អ្នកនោះឈ្មោះថា 'នាគ, (អ្នកមិនធ្វើបាប) "អដ្ឋកថាពន្យល់សេចក្ដីថា អ្នកដែលមិនធ្វើបាប ដោយអកុសលចិត្ត១១ ឈ្មោះថា "នាគ" ។ ក្នុងបាលីភាសាច្ជួនកាលះលោកហៅព្រះនាម របស់ព្រះសម្មាសម្ពុទ្ធថា 'នាគ „ ក៏មាន , ដូចក្នុងគាថាដែលព្រះកាឡុទាយី ពោលសរសើរព្រះសម្មាសម្ពុទ្ធថា «សព្វេ អច្ចរុចី នាគោ ហិមវាវញ្ញ សិលុច្ចយោ សព្វេសំ នាគនាមានំ សច្ចនាមោ អនុត្តរោ» ប្រែថា ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមថា "នាគ, ទ្រង់រុងរឿងកន្លងនូវភ្នំហិមពាន្តផងទៀត, ព្រះអង្គមានព្រះនាមដ៏ពិតប្រាកដថា 'នាគ, ទ្រង់ប្រសើរបំផុតជាងជនទាំងពួងដែលមាននាមថា 'នាគ„ ដែរ ជួនកាលហៅថា ពុទ្ធនាគ ក៏មាន ប្រែថា ព្រះពុទ្ធប្រៀបដូចដំរីដ៏ប្រសើរ វិគ្រោះថា " ពុទ្ធោ នាគោ ឯវ ពុទ្ធនាគោ„ ។ ប្រែថា ដំរីដ៏ប្រសើរគឺព្រះពុទ្ធ ក៏មាន , វិគ្រោះថា " ពុទ្ធោ ឥវ នាគោ ពុទ្ធនាគោ„ ។ អដ្ឋកថាពន្យល់សេចក្ដីថា មនុស្សដែលគួរហៅថា ' នាគ , បាននោះដោយហេតុ ៤ យ៉ាង គឺ ១- ព្រោះជាអ្នកមិនលំអៀងដោយអគតិទាំង៤ មានឆន្ទាគតិជាដើម, ២- ព្រោះជាអ្នកមិនបានត្រឡប់មកកាន់កិលេស



www.elibraryofcambodia.org

| បទានុក្រម | ទំព័រ | បន្ទាត់ |
|---|---|---|
| ដែលខ្លួនលះបង់ហើយ , ៣- ព្រោះជាអ្នកមិនធ្វើអំពើអាក្រក់ , ៤- ព្រោះជាអ្នកមានកម្ទេចមាំមួន ( អាចកម្ចាត់នូវកិលេសបាន ) | ២៧ | ៧ |
| បដិក្កូល ម. កិ. វិ. មុខតួរនឹងខ្មើម , តបនឹងខ្មើម | ១៧ | ១៣ |
| ប្រណាម្យអញ្ជលី ម. សំ. ន. ការប្រណម្យដៃ, ការសំពះ | ១៤ | ១៤ |
| បញ្ជរា ម. ន. រៀនខ្លួនទៅ , រៀនសព្វ , ដល់ខ្លួនទៅ , តបនឹងដល់ផាដំបូងមែនពិត , រៀនធំ គឺរៀនចាកទេចុនធម្មជាដើម | ២៣ | ៩ |
| បរិមណ្ឌល ម. សំ. ន. រង់ជុំវិញ , រង់មូល , សេចក្តីរៀបរយ , ទីប្រជុំ | ១៨ | ៣ |
| បវេណិធម៌ ម. ( សំ-ប្រវេណី ) ន. បែបផែន , ដៅពង្ស , មំនៀម | ២៥ | ៨ |
| បាតិមោក្ខ ម. ន. ធម៌ជាគ្រឿងញ៉ាំងភិក្ខុ អ្នករក្សាឱ្យរួចចាកអបាយទុក្ខ , ជាឈ្មោះបាលីដែលប្រមូលពុទ្ធបញ្ញត្តិ ដែលទ្រង់តាំងទៀងជាពុទ្ធ-អាជ្ញា បានដល់អាទិព្រហ្មចរិយកាសិក្ខា មានពុទ្ធានុញ្ញាតឱ្យសូធ្យក្នុងទីប្រជុំសង្ឃគ្រប់ៗកន្លះខែ | ១០ | ១៣ |
| ពុទ្ធប្បញ្ញត្តិ ម. ន. វាចាដែលព្រះពុទ្ធទ្រង់តែងតាំង , ច្បាប់ដែលព្រះពុទ្ធទ្រង់ហាមប្រាម | ៩៤ | ៣ |



www.elibraryofcambodia.org

| បទានុក្រម | ទំព័រ | បន្ទាត់ |
|---|---|---|
| **ពុទ្ធានុញ្ញាត** ម.ន. សេចក្ដីយល់ព្រមរបស់ព្រះពុទ្ធ, ព្រះពុទ្ធទ្រង់យល់ព្រម, ព្រះពុទ្ធទ្រង់ព្រមឲ្យ | ៣៩ | ៩ |
| **មេថុនធម្ម** ម.ន. ធម៌ជាគូគ្នា, ប្រវេណីរបស់ប្ដីប្រពន្ធ, ធម៌ជារបស់បុគ្គលពីរនាក់ ដែលស្មើគ្នា ដោយកិរិយាដែលរាគៈគ្របសង្កត់ | ៤៤ | ៩ |
| **វចីបណាម** ម.ន. ការថ្វាយបង្គំដោយវាចា | ១៤ | ១៦ |
| **វចីភេទ** ម.ន. ពាក្យនិយាយផ្សេងៗ ពាក្យនិយាយយ៉ាងល្អិត, បញ្ចេញសម្ដី | ១៤ | ១៥ |
| **វិនយបញ្ញត្តិ** ម.ន. សេចក្ដីបញ្ញត្តិក្នុងព្រះវិន័យ | ១៤ | ៤ |
| **សំសារទុក្ខ** ម.ន. ទុក្ខ ប្រែថា សេចក្ដីអត់ទ្រាំបាន ដោយកម្រ, សេចក្ដីព្រួយ, សេចក្ដីលំបាក, សំសារៈ ប្រែថា ការទៅ ការអន្ទោលទៅ, ការវិលស្លាប់កើត, ការវិលស្លាប់វិលកើត, ការផ្លាស់ប្ដូរលោក, សេចក្ដីប្រព្រឹត្តទៅរបស់លោក, សំសារទុក្ខ ប្រែថា សេចក្ដីលំបាកក្នុងការអន្ទោលទៅ | ២៥ | ១ |
| **សិក្ខា** ម. ( សំ. សិក្សា ) ការរៀន, ការហ្វឹកហ្វឺន, សេចក្ដីប្រតិបត្តិ គឺ សីល សមាធិ បញ្ញា ហៅថា ត្រៃសិក្ខា | ២៥ | ៩ |
| **សិក្ខាបទ** ម.ន. បទៈ ប្រែថា ហេតុ, គោលដើម, ឫសគល់, និព្វាន, វត្ថុ, ចំណែក, ជើង, ស្នាម | | |



www.elibraryofcambodia.org

| បទានុក្រម | ទំព័រ | បន្ទាត់ |
|---|---|---|
| ជើង, ពាក្យជាគ្រឿងដល់នូវសេចក្ដី បមស័ព្ទ ប្រែបានច្រើនយ៉ាង ដូចជាថា ឧបាយ, រឿង, ទី, ការរក្សា, ផ្លូវ, ដំណើរទំនង, ដើមទង ។ គ្នាម, លំនាំ នៃសម្លេងសព្ទ្យ ឬ ដែលច្រៀង ។ បទសរភញ្ញ (ម.ព សរភញ្ញ)។តែក្នុងពាក្យថា សិក្ខាបទគួរប្រែថា ហេតុ, ថាគោលដើម ឬ ចាចំណែកដែលត្រូវសិក្សា ។ | ៦១ | ២ |

**សីមា** ម.ន. ដែន ខេត្ត ។



www.elibraryofcambodia.org

# សាមណេរវិន័យ

ការផ្សាយរបស់

វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

បោះពុម្ពលើកទី ១

ព.ស. ២៥៣៣ គ.ស. ១៩៨៩

www.elibraryofcambodia.org

# បណាមគាថា

ពុទ្ធំ ធម្មញ្ច សង្ឃញ្ច នមិត្វា រតនត្តយំ
យោបិ ខោ សាមណេរានំ សម្ពុទ្ធេនានុជានិតោ
ឥធេវ តំ បវក្ខាមិ សុខេនេវ បពោធិតុំ
ពុទ្ធាទិអានុភាវេន តេសញ្ច សោត្ថិ សព្វទា

*យើងខ្ញុំទាំងឡាយ សូមនមស្ការនូវប្រជុំ៣ នៃព្រះរតនៈ គឺពុទ្ធរតនៈ ១ ធម្មរតនៈ ១ សង្ឃរតនៈ ១ ( ដោយកាយ វាចា ចិត្ត ) វិន័យឯណា ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់អនុញ្ញាត ទុកហើយដល់សាមណេរទាំងឡាយ ក្នុងព្រះពុទ្ធសាសនា យើងខ្ញុំទាំង-ឡាយនឹងពោលនូវវិន័យនោះ ទុកក្នុងទីនេះ ដើម្បីនឹងញុំាងសាមណេរជាអ្នកសិក្សាទាំងឡាយ ឲ្យដឹងដោយងាយ ដោយអានុភាព នៃព្រះរតនត្រ័យ មានព្រះពុទ្ធរតនៈជាដើម សូមសិរីសួស្តី ចូរចម្រើនដល់យើងខ្ញុំទាំងឡាយផង ដល់សាមណេរជាអ្នកសិក្សាទាំងឡាយផងសព្វ ៗ កាលវេលាហោង ។*

# សាមណេរវិន័យ

កុលបុត្រដែលចូលបួសជាសាមណេរ ត្រូវសិក្សាឲ្យចេះផង ក្នុង **សាមណេរវិន័យ**ជាមុន គឺវិន័យដែលសាមណេរ ត្រូវសិក្សាតាម ពុទ្ធានុញ្ញាត និង ពុទ្ធប្បញ្ញត្តិ ឯវិន័យដែលសាមណេរត្រូវសិក្សានោះ មាន៣០ បើចែកតាមឈ្មោះដើមមាន៣ពួក គឺ**សិក្ខាបទ**១០ ជាពួក១ **ទណ្ឌកម្ម**១០ ជាពួក១ **នាសនង្គៈ** ១០ជាពួក ១ រួមត្រូវជា ៣០ ។ ចំណែកធម៌ដែលសាមណេរត្រូវសិក្សា ឈ្មោះថា **សិក្ខាបទ** សេចក្តីខុសដែលសាមណេរធ្វើឲ្យកន្លង ហើយភិក្ខុត្រូវធ្វើទោសមានឲ្យដងទឹកជាដើម ដើម្បីនឹងឲ្យរាងចាលឈ្មោះថា **ទណ្ឌកម្ម** អង្គដែលជាហេតុនឹងត្រូវឲ្យសាមណេរវិនាស គឺឲ្យសឹកចេញ ឈ្មោះថា **នាសនង្គៈ** ។

ក៏ក្នុង**សាមណេរវិន័យ**នេះ នឹង ពោលនូវ**សាមណេរវិនយបាឋ** ដែលជាពុទ្ធានុញ្ញាតរៀបទុកជាមុន មិនបានប្រែចងជាប្រយោគទេ ព្រោះដើម្បីនឹងឲ្យស្រួលក្នុងការសិក្សា តែថាបានពោលអធិប្បាយក្នុងបាលីនោះ ជាសេចក្តីសព្វគ្រប់ គឺពោលពី**សិក្ខាបទ** **ទណ្ឌកម្ម** និង **នាសនង្គៈ** និង **វត្ត** មាន **សេខិយវត្ត** ជាដើមជាលំដាប់អំពី**សាមណេរវិនយបាឋ**នោះតទៅ ។

# សាមណេរវិនយបាឋ

អនុជានាមិ ភិក្ខវេ សាមណេរានំ ទស សិក្ខាបទានិ តេសុ ច សាមណេរេហិ សិក្ខិតុំ បាណាតិបាតា វេរមណី អទិន្នាទានា វេរមណី អព្រហ្មចរិយា វេរមណី មុសាវាទា វេរមណី សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី វិកាលភោជនា វេរមណី នច្ច គីត វាទិត វិសូក ទស្សនា វេរមណី មាលា គន្ធ វិលេបន ធារណ មណ្ឌន វិភូសនដ្ឋានា វេរមណី ឧច្ចាសយន មហាសយនា វេរមណី ជាតរូប រជតប្បដិគ្គហណា វេរមណី អនុជានាមិ ភិក្ខវេ សាមណេរានំ ឥមានិ ទស សិក្ខាបទានិ ឥមេសុ ច សាមណេរេហិ សិក្ខិតុន្តិ ។

អនុជានាមិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស សាមណេរស្ស ទណ្ឌកម្មំ កាតុំ ភិក្ខូនំ អលាភាយ បរិសក្កតិ ភិក្ខូនំ អនត្ថាយ បរិសក្កតិ ភិក្ខូនំ



www.elibraryofcambodia.org

អនាវាសាយ បរិសក្កតិ ភិក្ខូ អក្កោសតិ បរិភាសតិ ភិក្ខូ ភិក្ខូហិ ភេទេតិ អនុជានាមិ ភិក្ខវេ ឥមេហិ បញ្ចហង្គេហិ សមន្នាគតស្ស សាមណេរស្ស ទណ្ឌកម្មំ កាតុន្តិ ។

អនុជានាមិ ភិក្ខវេ ទសហង្គេហិ សមន្នាគតំ សាមណេរំ នាសេតុំ បាណាតិបាតី ហោតិ អទិន្នា-ទាយី ហោតិ អព្រហ្មចារី ហោតិ មុសាវាទី ហោតិ មជ្ជបាយី ហោតិ ពុទ្ធស្ស អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ សង្ឃស្ស អវណ្ណំ ភាសតិ មិច្ឆា-ទិដ្ឋិកោ ហោតិ ភិក្ខុនីទូសកោ ហោតិ អនុជានាមិ ភិក្ខវេ ឥមេហិ ទសហង្គេហិ សមន្នាគតំ សាមណេរំ នាសេតុន្តិ ។

សេក្ខិយវត្តក្ខន្ធកវត្តេសុ អញ្ញាសុ ច សុក្កវិស្សដ្ឋិ អាទិលោកវជ្ជសិក្ខាបទេសុ ច សាមណេរេហិ វត្តិតព្វំ តត្ថ អវត្តមានោ អលជ្ជី ទណ្ឌកម្មារហោ ច ហោតិ។

# សិក្ខាបទ ១០

១- បាណាតិបាតា វេរមណី ចេតនាជាហេតុវៀរចាកធ្វើសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ ។

២- អទិន្នាទានា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យដោយកាយឬដោយវាចា ។

៣- អព្រហ្មចរិយា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម ។

៤- មុសាវាទា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

៥- សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី ចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺ ផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។

៦- វិកាលភោជនា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស ។

៧- នច្ចគីតវាទិតវិសូកទស្សនា វេរមណី ចេតនាជាហេតុវៀរចាកកិរិយារាំ និងច្រៀង និងប្រគំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ ។

៨_មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាទ្រទ្រង់ និងប្រដាប់ និងតាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។

៩– ឧច្ចាសយនមហាសយនា វេរមណី ចេតនាជាហេតុវៀរចាកទីសេនាសនៈ ដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។

១០– ជាតរូបរជតប្បដិគ្គហណា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាទទួលកាន់យកនូវមាស និងប្រាក់ដោយខ្លួនឯង ឬ ប្រើអ្នកដទៃឲ្យទទួលកាន់យក ហើយត្រេកអរចំពោះមាសនិងប្រាក់នោះ ។

***

## ទណ្ឌកម្ម ១០

១- វិកាលភោជី ហោតិ សាមណេរបរិភោគនូវភោជនាហារក្នុងកាលខុស ។

២- នច្ចាគិតវិសូកទស្សនោ ហោតិ សាមណេររាំនិងច្រៀង និងប្រគំនិងមើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ ។



www.elibraryofcambodia.org

៣- មាលាទិធារណាទិតោ ហោតិ សាមណេរទ្រទ្រង់ និងប្រដាប់ និងតាក់តែងស្អិតស្អាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេង ៗ ។

៤- ឧច្ចាសយនាទិតោ ហោតិ សាមណេរដេកឬអង្គុយលើទីសេនាសនៈ ដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈ ដ៏ប្រសើរ ។

៥- ជាតរូបរជតប្បដិគ្គហណាតោ ហោតិ សាមណេរ ទទួលកាន់យកនូវមាស និងប្រាក់ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យទទួលកាន់យក ហើយត្រេកអរ ចំពោះមាស និងប្រាក់នោះ ។

៦- ភិក្ខូនំ អលាភាយ បរិសក្កតិ សាមណេរព្យាយាម ដើម្បីនឹងឲ្យសាបសូន្យលាភរបស់ភិក្ខុទាំងឡាយ ។

៧- ភិក្ខូនំ អនត្ថាយ បរិសក្កតិ សាមណេរព្យាយាមដើម្បីមិនឲ្យជាប្រយោជន៍ដល់ភិក្ខុទាំងឡាយ ។

៨- ភិក្ខូនំ អនាវាសាយ បរិសក្កតិ សាមណេរព្យាយាម ដើម្បីនឹងមិនឲ្យភិក្ខុទាំងឡាយបាននូវទីលំនៅ ។

៩- ភិក្ខូ អក្កោសតិ បរិភាសតិ សាមណេរជេរប្រទេចនូវភិក្ខុទាំងឡាយ ។

១០- ភិក្ខូ ភិក្ខូហិ ភេទេតិ សាមណេរញុំាងភិក្ខុទាំងឡាយឲ្យបែកចាកភិក្ខុទាំងឡាយ ។

* * *



www.elibraryofcambodia.org

# នាសនត្ថ ១០

១- បាណាតិបាតី ហោតិ សាមណេរធ្វើសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ ។

២- អទិន្នាទាយី ហោតិ សាមណេរកាន់យកនូវវត្ថុ ដែលគេមិនបានឲ្យដោយកាយ ឬ ដោយវាចា ។

៣- អព្រហ្មចារី ហោតិ សាមណេរប្រព្រឹត្តនូវធម៌មិន ប្រសើរ គឺសេពនូវមេថុនធម្ម ។

៤- មុសាវាទី ហោតិ សាមណេរពោលនូវពាក្យកុហក ។

៥- មជ្ជបាយី ហោតិ សាមណេរផឹកនូវទឹកស្រវឹង គឺ សុរា និង មេរ័យ ។

៦- ពុទ្ធស្ស អវណ្ណំ ភាសតិ សាមណេរពោល តិះដៀលនូវព្រះសម្មាសម្ពុទ្ធ ។

៧- ធម្មស្ស អវណ្ណំ ភាសិត សាមណេរពោល តិះដៀលនូវព្រះធម៌ ។

៨- សង្ឃស្ស អវណ្ណំ ភាសតិ សាមណេរពោល តិះដៀលនូវព្រះសង្ឃ ។

៩- មិច្ឆាទិដ្ឋិកោ ហោតិ សាមណេរមានទិដ្ឋិខុស ។

១០- ភិក្ខុនីទូសកោ ហោតិ សាមណេរប្រទូស្ត និង នាងភិក្ខុនី ។

# អង្គនៃសិក្ខាបទ ១០

សាមណេរកាលបើបានសិក្សាចាំស្ទាត់ ក្នុងសិក្ខាបទទាំង ១០ ហើយ ត្រូវសិក្សាឲ្យចាំចូលចិត្តស្ទាត់ ក្នុងអង្គនៃសិក្ខាបទទាំង ១០ តទៅទៀត ព្រោះសិក្ខាបទដែលនឹងបរិសុទ្ធ ឬ នឹងសៅហ្មង នឹងដាច់ឆ្ងាយនោះ លុះតែបានសិក្សាចាំអង្គចូលចិត្តស្ទាត់ ទើបនឹងអាចវិនិច្ឆ័យ ពិចារណាកាត់សេចក្ដីដោយខ្លួនឯងថា សិក្ខាបទនោះ ៗ បរិសុទ្ធ ឬ សៅហ្មងដាច់ឆ្ងាយនោះបាន ៗ

ឯអង្គនៃសិក្ខាបទ១០ នោះ ដូចមានសេចក្ដីតទៅនេះ

## បាណាតិបាត មានអង្គ ៥

១- បាណោ សត្វមានជីវិត

២- បាណសញ្ញិតា សេចក្ដីដឹងថាសត្វមានជីវិត

៣- វធកចិត្តំ គិតនឹងសម្លាប់

៤- ឧបក្កមោ ព្យាយាមនឹងសម្លាប់

៥- តេន មរណំ សត្វស្លាប់ដោយព្យាយាមនោះ ៗ

## អទិន្នាទាន មានអង្គ ៥

១- បរបរិគ្គហិតំ ទ្រព្យដែលមានម្ចាស់របស់គេហួងហែងរក្សា

២- បរបរិគ្គហិតសញ្ញិតា សេចក្ដីដឹងថាទ្រព្យមានម្ចាស់របស់គេ ហួងហែងរក្សា

៣- ថេយ្យចិត្តំ គិតនឹងលួច



www.elibraryofcambodia.org

៤- ឧបក្កមោ ព្យាយាមនឹងលួច

៥- តេន ហរណំ លួចបានមកដោយព្យាយាមនោះ ៗ

## អព្រហ្មចរិយ មានអង្គ ៤

១- អគមនវត្ថុ វត្ថុជាទីទម្លាយនូវសីល គឺក្នុងទ្វារទាំង៣០ ទ្វារណាមួយ

២- សេវនចិត្តំ គិតនឹងសេព

៣- តជ្ជោ វាយាមោ ព្យាយាមនឹងសេពនូវមេថុនធម្មនោះ

៤- មគ្គេន មគ្គប្បដិបាទនំ ញុំាងមគ្គនិងមគ្គឲ្យដល់គ្នា ៗ

## មុសាវាទ មានអង្គ ៤

១- អតថំ វត្ថុ វត្ថុមិនពិត

២- វិសំវាទនចិត្តំ គិតនឹងពោលឲ្យខុស

៣- តជ្ជោ វាយាមោ ព្យាយាម នឹងពោលឲ្យខុសនោះ

៤- បរស្ស តទត្ថវិជាននំ ញុំាងអ្នកដទៃឲ្យដឹងច្បាស់ នូវសេចក្តីនោះ ៗ

## សុរាមេរយ មានអង្គ ៤

១- មជ្ជនីយវត្ថុ វត្ថុជាទីតាំងនៃសេចក្តីស្រវឹង គឺសុរានិងមេរ័យ

២- បាតុកម្យតាចិត្តំ ចិត្តប្រាថ្នាដើម្បីនឹងផឹក

៣- តជ្ជោ វាយាមោ ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ



www.elibraryofcambodia.org

៤- តស្ស បានំ  បានផឹកនូវទឹកស្រវឹងនោះ ឲ្យកន្លងបំពង់ក ចូលទៅ ។

## វិកាលភោជន មានអង្គ ៣

១- វិកាលោ  កាលខុស គឺព្រះអាទិត្យជ្រេទៅហើយដរាបទល់នឹងអរុណរះ

២- យាវកាលិកំ  របស់ដែលគួរបរិភោគបានក្នុងកាល គឺតាំងពីអរុណរះឡើង ដរាបដល់ថ្ងៃត្រង់

៣- អជ្ឈោហរណំ  បានលេបចូលទៅក្នុងបំពង់ក ។

## នច្ចគីត មានអង្គ ៣

១- នច្ចគីតាទិ  ការល្បែងមានរាំនិងច្រៀងជាដើម

២- ភត្តុភម្យតាចិត្តំ  ចិត្តប្រាថ្នាដើម្បីនឹងមើល

៣- សុតទស្សនត្ថាយ គមនំ  ទៅដើម្បីនឹងស្ដាប់ ឬ មើល ហើយបានស្ដាប់ឬមើល ។

## មាលា មានអង្គ ៣

១- មាលាទិ  វត្ថុសម្រាប់ប្រដាប់កាយមានផ្កាកម្រងជាដើម

២- ធារណច្ឆន្ទតា  សេចក្ដីប្រាថ្នា នឹងប្រដាប់តាក់តែង

៣- តស្ស ធារណំ  បានប្រដាប់តាក់តែង នូវវត្ថុសម្រាប់ប្រដាប់កាយមានផ្កាកម្រងជាដើមនោះ ។



www.elibraryofcambodia.org

## ឧច្ចាសយន មានអង្គ ៣

១- ឧច្ចាសយន មហាសយនំ ទីដេកទីអង្គុយ ដ៏ខ្ពស់ដ៏ប្រសើរហួសប្រមាណ

២- បរិភោគ ចិត្តំ គិតនឹងដេកឬអង្គុយ

៣- បរិភោគ ករណំ បានដេកឬអង្គុយ ។

## ជាតរូប មានអង្គ ៣

១- ជាតរូបរជតំ មាស ឬ ប្រាក់ដែលជាអកប្បិយភណ្ឌ

២- អត្តុទ្ទិសកា ចំពោះជារបស់ខ្លួន

៣- បដិគ្គណ្ហាតិ បានទទួលកាន់យកដោយខ្លួនឯង ឬ ប្រើគេឲ្យទទួលកាន់យកទុកដាក់ឲ្យ ហើយត្រេកអរ ចំពោះមាស ឬ ប្រាក់នោះដោយឧបាយឯណានមួយ ។

កាលបើសាមណេរប្រព្រឹត្តឲ្យកន្លង នូវសិក្ខាបទណា ១ លុះតែព្រមដោយអង្គក្នុងសិក្ខាបទនោះ ៗ ទើបបានឈ្មោះថាកន្លង បើមិនទាន់ព្រមដោយអង្គនោះ ក៏មិនបានឈ្មោះថា កន្លងនូវសិក្ខាបទនោះ ១ ទេ ។

# បរយោគ

សេចក្ដីព្យាយាមខំប្រព្រឹត្ត ធ្វើឲ្យកន្លងនូវសិក្ខាបទ ឈ្មោះថា **បរយោគ** ។ នោះ មាន ២ គឺសាហត្ថិកប្បយោគ ១ អាណត្តិកប្បយោគ ១ ។ ធ្វើឲ្យកន្លងដោយខ្លួនឯងហៅថា **សាហត្ថិកប្បយោគ** ប្រើអ្នកដទៃឲ្យធ្វើហៅថា **អាណត្តិកប្បយោគ** ។

ក្នុងសិក្ខាបទទាំង ១០ នោះ សិក្ខាបទទី ៣ គឺ អព្រហ្មចរិយៈ សិក្ខាបទទី ៤ គឺមុសាវាទៈ សិក្ខាបទទី ៥ គឺ សុរាមេរយៈ សិក្ខាបទទី ៦ គឺវិកាលភោជនៈ សិក្ខាបទទី ៧ គឺនច្ចគីតៈ សិក្ខាបទទី ៨ គឺ មាលា និងសិក្ខាបទទី ៩ គឺឧច្ចាសយនៈ ទាំង ៧ សិក្ខាបទនេះ ជា **សាហត្ថិកប្បយោគ** ។

សិក្ខាបទទី១ គឺបាណាតិបាតៈ សិក្ខាបទទី២ គឺអទិន្នាទានៈនិងសិក្ខាបទទី១០គឺជាតរូបៈ ទាំង៣ សិក្ខាបទនេះជា **អាណត្តិកប្បយោគ** ។

ម្យ៉ាងទៀត សិក្ខាបទទាំង ១០ នោះ លោកចែកចេញជា ២ ពួក គឺជា **សាណត្តិកៈ** ពួក ១ ជា **អនាណត្តិកៈ** ពួក ១ ។

សិក្ខាបទ ឯណា ដែលជា **អាណត្តិកប្បយោគ** សិក្ខាបទនោះជា **សាណត្តិកៈ** ព្រោះអ្នករក្សាធ្វើដោយខ្លួនឯងក្ដី ប្រើអ្នកដទៃឲ្យធ្វើក្ដី ឈ្មោះថាកន្លងដូចគ្នា ។

សិក្ខាបទឯណា ដែលជា**សាហត្ថិកប្បយោគ** សិក្ខាបទនោះ ជា **អនាណត្តិកៈ** ព្រោះអ្នករក្សាធ្វើដោយខ្លួនឯង ទើបឈ្មោះថាកន្លង បើប្រើអ្នកដទៃឲ្យធ្វើនោះ មិនបានឈ្មោះថា កន្លងទេ ។



www.elibraryofcambodia.org

# កិច្ចនៃទណ្ឌកម្ម

កិច្ចដែលនឹងធ្វើនូវទណ្ឌកម្មដល់សាមណេរនោះ គឺក្នុងទណ្ឌកម្មទាំង ១០ នោះ បើសាមណេរធ្វើខុសគន្លងដោយទណ្ឌកម្ម ឯណាមួយហើយ ត្រូវភិក្ខុជាឧបជ្ឈាយ៍ ឬអាចារ្យ ធ្វើទោសដោយទណ្ឌកម្ម ឯទណ្ឌកម្មនោះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ អនុញ្ញាតឲ្យភិក្ខុធ្វើ **អាវរណកម្ម** គឺហាមដល់សាមណេរទាំងឡាយ ដែលមានសេចក្តីខុសគួរដល់ទណ្ឌកម្ម ឯការដែលនឹងហាមនោះ គឺបើសាមណេរនោះនៅក្នុងទីណា តែងតែដើរចូលទៅក្នុងទីណា ត្រូវហាមកុំឲ្យនៅក្នុងទីនោះ កុំឲ្យដើរចូលទៅក្នុងទីនោះ ឯទីដែលសាមណេរនៅនោះ គឺទីលំនៅដែលសាមណេរនៅជានិច្ច របស់ខ្លួនក្តី ទីដែលសាមណេរបានដោយលំដាប់វស្សាក្តី ឈ្មោះថា ទីលំនៅរបស់សាមណេរ ទីដែលសាមណេរតែងតែដើរចូលទៅនោះ គឺទីបរិវេណ ឬទីលំនៅរបស់ឧបជ្ឈាយ៍ ឬអាចារ្យ ឈ្មោះថា ទីដើរចូលទៅនៃសាមណេរ ។

ឯកិច្ចដែលនឹងហាមនោះ ត្រូវហាមដោយពាក្យថា អ្នកកុំនៅក្នុងទីនេះ អ្នកកុំដើរចូលទៅក្នុងទីនោះ ពាក្យហាមប៉ុណ្ណេះជាដើម ហៅថា **អាវរណកម្ម** ។

ម្យ៉ាងទៀត ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តថា មិនឲ្យភិក្ខុហាមសាមណេរមិនឲ្យនៅក្នុងទីអាវាសទាំងមូល ឬហាមនូវមុខ(១)ទ្វារ គឺបន្ទប់

១ គាថា មុខៈ-ទ្វារ

មិនឲ្យសាមណេរបរិភោគអាហារ បើភិក្ខុឯណា ហាមមិនឲ្យនៅក្នុងសា-លាសចាំងមូលក្តី ហាមនូវមុខទ្វារដោយពាក្យថា អ្នកកុំបរិភោគអាហារ ដូច្នេះក្តី ឬ យកបាត្រនិងចីវរ របស់សាមណេរទៅទុកក្នុងកុដិ ដោយគិតថា អញនឹងបង្អត់អាហារដូច្នេះក្តី ភិក្ខុនោះត្រូវទុក្កដាបត្តិ តែថា បើសាមណេរជាទុព្វចៈ គឺសាមណេរដែលរឹងរូស និងប្រដៅបានដោយក្រ ហើយជាអនាចារ ប្រព្រឹត្តកន្លងសិក្ខាបទផ្សេង ១ នោះបើភិក្ខុនឹងធ្វើទណ្ឌកម្មដោយកិច្ច គឺយកយាគូ ឬ ភត្ត ឬ បាត្រ និង ចីវរ របស់សាមណេរនោះ មកតម្កល់ទុកក្នុងទី ១ ហើយបង្ហាញដោយពាក្យថា កិច្ចទណ្ឌកម្មមានប្រមាណប៉ុណ្ណេះ បើអ្នកធ្វើរួចស្រេចហើយ អ្នកនឹងបាននូវរបស់ទាំងអស់នេះ ដូច្នេះគួរ ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់អនុញ្ញាតទណ្ឌកម្មដោយកិច្ចជា **អាវរណកម្ម** គឺហាមមិនឲ្យសាមណេរ នៅក្នុងទីដែលធ្លាប់នៅ និងហាមមិនឲ្យចេញចូលក្នុងទីដែលធ្លាប់ចេញចូល តែម្យ៉ាងប៉ុណ្ណេះ តែព្រះធម្មសង្គាហកត្ថេរទាំងឡាយ កាលដែលលើកសង្គាយនានោះ លោកបង្គាប់ថា ឲ្យដាក់ទណ្ឌកម្មដោយកិច្ច គឺឲ្យដងទឹក រែកខ្សស ជញ្ជូនដីខ្សាច់ច្រើនតិចតាមទោសដែលធ្វើខុស តែថាដែលនឹងឲ្យធ្វើដូច្នេះនោះ លុះតែឲ្យធ្វើដោយសេចក្តីករុណា ប្រាថ្នានឹងឲ្យវៀរចាកសេចក្តីខុសនោះ ទើបគួរ និងធ្វើដោយបាបចិត្ត គិតប្រាថ្នា នឹងឲ្យសឹកចេញចាកសាមណេរភេទនោះ មិនគួរទេ ។

ម៉្យាងទៀត នឹងឲ្យសាមណេរនោះដេកលើថ្មក្តៅ ឬ នឹងយករបស់ធ្ងន់ មានថ្មនិងឥដ្ឋជាដើម ដាក់សង្កត់ពីលើក្បាល ឬនឹងឲ្យចុះក្រាំទឹក ឬមុជចុះទៅក្នុងទឹកនោះ ក៏មិនគួរទេ ។

ឯកិច្ចដែលនឹងធ្វើទណ្ឌកម្មនោះ ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតនិងបញ្ញត្តហាមថា ត្រូវព្រះឧបជ្ឈាយ៍ ឬ អាចារ្យធ្វើ បើភិក្ខុឯទៀតឃើញសាមណេរធ្វើខុសមិនបានប្រាប់ឧបជ្ឈាយ៍ ឬ អាចារ្យរបស់សាមណេរនោះឲ្យដឹងជាមុន ហើយទៅធ្វើទណ្ឌកម្មដល់សាមណេរនោះ ភិក្ខុអ្នកធ្វើត្រូវទុក្កដាបត្តិ បើបានប្រាប់ដល់ឧបជ្ឈាយ៍ ឬ អាចារ្យរបស់សាមណេរជាគម្រប់បីដង ហើយឧបជ្ឈាយ៍ឬអាចារ្យក៏មិនធ្វើទណ្ឌកម្មដល់សាមណេរនោះ ភិក្ខុនោះ នឹងធ្វើដោយខ្លួនឯងក៏គួរ ។

ម៉្យាងទៀត បើឧបជ្ឈាយ៍ ឬ អាចារ្យរបស់សាមណេរនោះ បានអនុញ្ញាត គឺនិយាយផ្តាំផ្ញើទុកថា បើសាមណេររបស់ខ្ញុំ មានទោសខុស លោកចូរធ្វើទណ្ឌកម្មឲ្យខ្ញុំផង បើបានអនុញ្ញាតដូច្នេះហើយ មិនបាច់ប្រាប់ដល់ឧបជ្ឈាយ៍ ឬ អាចារ្យ ភិក្ខុនោះ ឃើញសាមណេរមានទោសខុសហើយ នឹងធ្វើទណ្ឌកម្មដោយខ្លួនឯងទៅក៏គួរ ។

ចំណែកខាងសាមណេរវិញ បើត្រូវទោសគួរដល់ទណ្ឌកម្មហើយ គប្បីចូលទៅសូមទណ្ឌកម្ម ក្នុងសំណាក់ព្រះឧបជ្ឈាយ៍ ឬ អាចារ្យ ដោយពាក្យដូច្នេះ ៣ ដងថា **លភេយ្យាហំ ភន្តេ ទណ្ឌកម្មំ អាយតឹ សំវរំ អាបជ្ជិស្សាមិ** បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំ

ព្រោះករុណាត្រូវបាននូវទណ្ឌកម្ម ទុំព្រោះករុណានឹងផល់នូវសេចក្ដីសង្រួម គឺជានឹងប្រព្រឹត្តឲ្យល្អតទៅខាងមុខទៀត ។

លុះស្ងួតស្ងួមទណ្ឌកម្មជូនខ្លះ ៣ ដងរួចហើយ ព្រះឧបជ្ឈាយ៍ ឬអាចារ្យ ត្រូវដាក់ទណ្ឌកម្មឲ្យសាមណេរនោះ ធ្វើតាមសមគួរដល់ទោសខុស ដូចន័យដែលបានពោលមកក្នុងខាងដើមហើយ បើបានធ្វើទណ្ឌកម្មរួចស្រេចហើយ សាមណេរនោះក៏ឈ្មោះថា បានតាំងនៅក្នុងសេចក្ដីបរិសុទ្ធ ដូចប្រក្រតីអំពីដើម ។

កិច្ចនៃទណ្ឌកម្មចប់ ។

## កិច្ចនៃនាសនង្គៈ

កិច្ចដែលនឹងឲ្យសាមណេរវិនាសនោះ គឺក្នុងនាសនង្គៈ ទាំង១០ នោះ បើសាមណេរធ្វើឲ្យកន្លងដោយនាសនង្គៈឯណាមួយហើយ ត្រូវព្រះឧបជ្ឈាយ៍ ឬ អាចារ្យធ្វើឲ្យសាមណេរនោះវិនាស គឺឲ្យសឹកចេញ តែថាកិច្ចដែលនឹងធ្វើនោះ មានវិធីខុសអំពីគ្នាខ្លះ ព្រោះក្នុងនាសនង្គៈ ទាំង១០នោះ លោកចែកចេញជាពីរពួកគឺ នាសនង្គៈ ៥ខាងដើម ដែលជាសិក្ខាបទ គឺតាំងពីសិក្ខាបទទី១ ដល់សិក្ខាបទទី៥ ជាពួក១ នាសនង្គៈ ៥ខាងចុង គឺតាំងពីទី៦ដល់ទី១០ជាពួក១ ។

បើសាមណេរឯណា ប្រព្រឹត្តធ្វើឲ្យកន្លងនូវសិក្ខាបទ គឺនាសនង្គៈ ៥ខាងដើម ក្នុងនាសនង្គៈឯណាមួយហើយ សរណគមន៍ក្ដី សេចក្ដីកាន់

យកនូវព្រះឧបជ្ឈាយ៍ក្តី ទីលំនៅដែលខ្លួនធ្លាប់នៅនោះក្តី ក៏ដាច់ គឺថា មិនមានសរណគមន៍ មិនមានព្រះឧបជ្ឈាយ៍ មិនមានទីលំនៅឡើយ សង្ឃលោកដែលខ្លួនត្រូវបាននោះក្តី ក៏ដាច់ គឺថា មិនត្រូវបានឡើយ សល់នៅតែភេទម្យ៉ាង ព្រោះអាស្រ័យហេតុដែលស្លៀកដណ្តប់សំពត់កាសាវៈប៉ុណ្ណោះឯង ព្រោះហេតុនោះព្រះឧបជ្ឈាយ៍ ឬ អាចារ្យ ត្រូវឲ្យសាមណេរនោះសឹកចេញ ក្នុងខណៈដែលប្រព្រឹត្តខុសក្នុងសីលនោះ បើសាមណេរនោះជាមនុស្សអាក្រក់ ប្រឡូកពេញដោយទោសក្នុងសីលទាំង៤ ខាងដើមនោះក្រៃពេកណាស់ ព្រះឧបជ្ឈាយ៍ ឬ អាចារ្យ បានពោលប្រដៅគេបញ្ចប់ហើយ នៅតែមិនស្តាប់ មិនមានសេចក្តីប្រាថ្នា នឹងតាំងនៅក្នុងសេចក្តីសង្រួមតទៅទៀតទេ នោះព្រះឧបជ្ឈាយ៍ ឬ អាចារ្យ ត្រូវអបលោកន៍ប្រាប់សង្ឃឲ្យដឹង ហើយឲ្យសឹកចេញ បើសឹកចេញហើយមានប្រាថ្នានឹងចង់បួសវិញ បានចូលមកសូមផ្នួសទៀត ក៏គប្បីអបលោកន៍ប្រាប់សង្ឃឲ្យដឹងហើយឲ្យបួសទៀតចុះ ។

ម្យ៉ាងទៀត បើសាមណេរឯណា ធ្វើខុសក្នុងសិក្ខាបទណាមួយ ហើយដឹងទោសខ្លួនដោយមួយរំពេចថា អញធ្វើនេះខុសហើយ ហើយមានចិត្តប្រាថ្នានឹងតាំងនៅក្នុងសេចក្តីសង្រួមតទៅទៀត ព្រះឧបជ្ឈាយ៍ ឬអាចារ្យ កុំគប្បីឲ្យសាមណេរនោះសឹកឡើយ គប្បីឲ្យទទួលនូវព្រះត្រៃសរណគមន៍ និងកាន់យកនូវព្រះឧបជ្ឈាយ៍ទៀតចុះ ឯសិក្ខាបទទាំង ១០ នោះ ក៏សម្រេចព្រមដោយការទទួលយក នូវព្រះត្រៃសរណគមន៍

នោះហើយ ដូចជាចតុប្បារិសុទ្ធិសីលដែលសម្រេចដល់ភិក្ខុ ដោយញត្តិចតុត្ថកម្មវាចានោះដែរ តែថាបើនឹងសមាទានថ្មីទៀតក៏គួរ ដើម្បីនឹងឲ្យមាំមួន នឹងបានជាទីគោរព និងសង្រួមតទៅខាងមុខ បើសាមណេរដែលទទួលយក នូវព្រះត្រៃសរណគមន៍ថ្មីទៀតនោះ បានទទួលយក ក្នុងថ្ងៃចូលបុរិមិកវស្សាហើយ បានចូលបុរិមិកវស្សាក្នុងថ្ងៃនោះ សាមណេរនោះក៏ត្រូវបានសំពត់បំណាំវស្សាផង បើបាននៅចាំវស្សាគ្រប់៣ខែ ចាំងកាលចីវរ ដែលកើតដល់សង្ឃ ក្នុង១ខែ គឺតាំងពីថ្ងៃ១កើតខែអស្សុជ ដរាបដល់ថ្ងៃពេញបូណ៌មីខែកត្តិកនោះ សាមណេរនោះក៏ត្រូវបានស្មើភាគនឹងភិក្ខុដែរ ម្យ៉ាងទៀត បើសាមណេរឯណាដែលបានចូលបុរិមិកវស្សាហើយ ត្រូវខាសខន្ធៈ ក្នុងថ្ងៃមុនថ្ងៃចូលបច្ឆិមិកវស្សា គឺតាំងពីថ្ងៃ២ កើតខែអាសាឍ ដរាបដល់ថ្ងៃចូលបច្ឆិមិក-វស្សា គឺថ្ងៃ១កើតខែស្រាពណ៍ ក្នុងថ្ងៃណាមួយ ហើយបានទទួលយកព្រះត្រៃសរណគមន៍ និងកាន់យកព្រះឧបជ្ឈាយ៍ ហើយបានចូលបច្ឆិមិកវស្សាទៀតក្ដី សាមណេរ ដែលមិនបានចូលបុរិមិកវស្សាលុះដល់ថ្ងៃ១កើតខែស្រាពណ៍ ទើបចូលបច្ឆិមិកវស្សាក្ដី ឬ សាមណេរដែលមានវស្សាដាច់ក្ដី កាលចីវរបរិភោគ គឺកិរិយាបានប្រើប្រាស់នូវកាលចីវរ ក៏មិនបានសម្រេច ដល់សាមណេរនោះៗទេ ហេតុដូច្នោះ លាភដែលកើតឡើងដល់សង្ឃនោះ សង្ឃគប្បីធ្វើអបលោកនកម្ម ហើយចែកដល់សាមណេរនោះៗ ចុះ ឯវស្សាវាសិកលាភ គឺ

លោកដែលភិក្ខុសាមណេរនៅចាំវស្សាត្រូវបាននោះ បើតាយកជាម្ចាស់សេនាសនៈ គេបាននិយាយទុកមកអំពីមុន ដើម្បីនឹងគ្រប់គ្រងទីសេនាសនៈរបស់គេថា បើមានលោកម្ចាស់អង្គណា ចូលបច្ឆិមិកវស្សាអាស្រ័យនៅក្នុងទីសេនាសនៈរបស់ខ្ញុំ នោះព្រះសង្ឃគប្បីឲ្យនូវវស្សាវាសិកលាភនោះ ដល់លោកម្ចាស់អង្គនោះផងចុះ ដូច្នេះសង្ឃមិន បាច់ធ្វើអបលោកនកម្មទេ គប្បីឲ្យនូវវស្សាវាសិកលាភដល់សាមណេរដែលបានចូលបច្ឆិមិកវស្សា តាមពាក្យតាយកជាម្ចាស់សេនាសនៈនោះចុះ

សាមណេរមានទោសខុសក្នុងនាសនង្គៈ ៥ ខាងដើម ព្រះឧបជ្ឈាយ៍ ឬ អាចារ្យ ត្រូវធ្វើទោសដូចន័យដែលបានពោលមកហើយ ។

បើសាមណេរមានទោសខុសក្នុងនាសនង្គៈ ៥ ខាងចុងនោះត្រូវធ្វើទោសដោយកិច្ចប្លែកគ្នា អំពីនាសនង្គៈ ៥ ខាងដើមខ្លះ គឺថាបើសាមណេរឯណា ប្រព្រឹត្តឲ្យកន្លងក្នុងនាសនង្គៈទី ៦-៧-៨ នោះព្រះឧបជ្ឈាយ៍ ឬ អាចារ្យ ត្រូវសម្តែងទោសប្រាប់សាមណេរនោះថា ឯការពោលតិះដៀលព្រះរតនត្រ័យនេះ មានទោសជាទម្ងន់ណាស់ អ្នកពោលតិះដៀលព្រះរតនត្រ័យ ដូច្នេះមិនត្រូវទេ ក្រោយៗកុំពោលដូច្នេះទៀត បើបានពោលហាមប្រាមដោយពាក្យ មានដូច្នេះជាដើមហើយ សាមណេរនោះលះបង់ទិដ្ឋិនោះចេញ ក៏គប្បីដាក់ទណ្ឌកម្មខ្លះហើយ ឲ្យសម្តែងទោសក្នុងកណ្តាលជំនុំសង្ឃដូច្នេះថា

អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមុឡ្ហំ
យថាអកុសលំ យោហំ ភន្តេ ឯវំ អកាសឹ តស្ស មេ
អច្ចយំ អច្ចយតោ បដិគ្គណ្ហាថ អាយតឹ សំវរេយ្យាមិ

បពិត្រលោកម្ចាស់ដ៏ចម្រើន ទោស គឺសេចក្ដីខុសប្រព្រឹត្តកន្លងគ្របសង្កត់ហើយនូវខ្ញុំព្រះករុណា ព្រោះជាមនុស្សពាលពេកណាស់ ជាមនុស្សវង្វេងពេកណាស់ ជាមនុស្សមិនឈ្លាសពេកណាស់ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណា ឯណាបានពោលហើយ នូវពាក្យតិះដៀលព្រះរតនត្រ័យយ៉ាងនេះ សូមលោកម្ចាស់ មេត្តាប្រោសអត់នូវទោស គឺសេចក្ដីខុសដល់ខ្ញុំព្រះករុណា ជាអ្នកមានទោសខុសនោះ ខ្ញុំព្រះករុណាគប្បីសង្រួម គឺថានឹងប្រព្រឹត្តឲ្យល្អតទៅខាងមុខទៀត ។

លុះសម្ដែងទោសដូច្នេះរួចហើយ ត្រូវឲ្យព្រះត្រៃសរណគមន៍ និងសីលជាថ្មីទៀត ព្រោះសាមណេរនោះ ជាបារាជិកហើយ បើបានហាមប្រាមដូច្នេះហើយ មិនលះបង់ទិដ្ឋិនោះចោលចេញទេនោះ ព្រះឧបជ្ឈាយ៍ ឬ អាចារ្យ ត្រូវឲ្យសាមណេរនោះសឹកចេញ ។

បើសាមណេរមានទោសខុសក្នុងនាសនង្គៈទី ៩ នោះ ព្រះឧបជ្ឈាយ៍ឬអាចារ្យ ត្រូវសម្ដែងទោសអំពីមិច្ឆាទិដ្ឋិប្រាប់សាមណេរនោះ ហើយហាមប្រាមឲ្យលះបង់ទិដ្ឋិនោះចេញ បើសាមណេរនោះលះបង់ទិដ្ឋិនោះចេញ ក៏គប្បីដាក់ទណ្ឌកម្មរួចហើយ ឲ្យសម្ដែងទោសក្នុងកណ្ដាលជំនុំសង្ឃថា

**អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យោហំ ភន្តេ ឯវំ ទិដ្ឋិកោ អហោសឹ តស្ស មេ អច្ចយំ អច្ចយតោ បដិគ្គណ្ហថ អាយតឹ សំវរេយ្យាមិ** បពិត្រលោកម្ចាស់ដ៏ចម្រើន ទោស គឺសេចក្ដីខុស ប្រព្រឹត្តកន្លងគ្របសង្កត់ហើយ នូវខ្ញុំព្រះករុណា ព្រោះជាមនុស្សពាលពេកណាស់ ជាមនុស្សវង្វេងពេកណាស់ ជាមនុស្សមិនឈ្លាសពេកណាស់ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាឯណា ជាមនុស្សឃើញខុសយ៉ាងនេះ សូមលោកម្ចាស់មេត្ដាប្រោស អត់នូវទោសគឺសេចក្ដីខុសដល់ខ្ញុំព្រះករុណា ជាអ្នកមានទោសខុសនោះ ខ្ញុំព្រះករុណាគប្បីសង្រួម គឺជានឹងប្រព្រឹត្តឲ្យល្អតទៅខាងមុខទៀត ។

លុះសម្ដែងទោសដូច្នេះរួចហើយ ត្រូវឲ្យព្រះត្រៃសរណគមន៍ និងសីលជាថ្មីទៀត បើបានហាមប្រាមដូច្នេះ ហើយមិនលះបង់ទិដ្ឋិនោះពោលចេញទេ នោះព្រះឧបជ្ឈាយ៍ឬអាចារ្យ ត្រូវផ្សឹកសាមណេរនោះចេញ ។

ម្យ៉ាងទៀត បើសាមណេរឯណា មិនបានកាន់យកនូវទិដ្ឋិដូច្នេះទេ គ្រាន់តែកាន់យកដោយវិបរិត្ត ខុសពាក្យនូវវចនាធិប្បាយ ភិក្ខុទាំងឡាយពោលទូន្មានហាមប្រាម ក៏មិនលះបង់ នៅតែពោលដោយវិបរិត្តខុសដូច្នោះដដែល សាមណេរនោះឈ្មោះថាមិនដល់បារាជិកទេ តែថាព្រះឧបជ្ឈាយ៍ ឬ អាចារ្យ ត្រូវធ្វើកណ្ដកនាសនៈ គឺឲ្យសាមណេរនោះសឹកចេញ ដូចជាកណ្ដកសាមណេរ បើមានប្រាថ្នានឹងតាំងនៅក្នុងសេចក្ដី

សង្រួមតទៅទៀតនោះ ព្រះឧបជ្ឈាយ៍ ឬ អាចារ្យ គប្បីអប់លោកន៏ ប្រាប់សង្ឃ ហើយបំបួសទៀតចុះ បើមិនមានប្រាជ្ញានឹងកាន់នៅក្នុង សេចក្តីសង្រួមតទៅទៀតនោះ មិនត្រូវឲ្យបួសទៀតទេ ។

បើសាមណេរមានទោសខុសក្នុងនាសនង្គៈទី ១០នោះ ត្រូវព្រះ ឧបជ្ឈាយ៍ ឬអាចារ្យ ផ្តេកសាមណេរនោះចេញ បើទុកជាប្រាជ្ញានឹង កាន់នៅ ក្នុងសេចក្តីសង្រួមតទៅទៀត ក៏មិនត្រូវឲ្យបំបួសទៀតទេ ព្រោះក្នុងនាសនង្គៈទី១០នេះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ហាម ផ្តាច់ថា មិនត្រូវឲ្យបំបួសទៀតឡើយ ប៉ុន្តែនាសនង្គៈទី១០នេះ ក្នុង កាលឥឡូវនេះ មិនមានទេ ព្រោះមិនមានភិក្ខុនី ។

កិច្ចនៃនាសនង្គចប់ ។

ក្នុងកិច្ចនៃទណ្ឌកម្មនោះ សាមណេរត្រូវសិក្សាត្រង់សេចក្តីដែល សូត្រសូមទណ្ឌកម្ម ឲ្យចាំស្ទាត់ទាំងបាលី និងសេចក្តីប្រែជាសម្រាយៗ

ក្នុងកិច្ចនៃនាសនង្គៈនោះ ត្រូវសិក្សាត្រង់សេចក្តីដែលសូត្រ សម្តែងទោសឲ្យចាំស្ទាត់ទាំងបាលី និងសេចក្តីប្រែ ឯកិច្ចក្រៅពីនោះ បើមិនអាចនឹងសិក្សាឲ្យចាំទាំងអស់បាន គ្រាន់តែសិក្សាឲ្យដឹងសេចក្តី ជាធំៗក៏បាន ព្រោះជាកិច្ចរបស់ព្រះឧបជ្ឈាយាចារ្យទេ តែថាបើ សាមណេរឯណា មានប្រាជ្ញាក្លៃ ប្រកបដោយសេចក្តីព្យាយាមមាំ អាចនឹងសិក្សាឲ្យចាំទាំងអស់បាន ចូរឲ្យសាមណេរនោះ សិក្សាចុះ ឈ្មោះថា ជាការចម្រើនល្អណាស់ ។

សាមណេរវិន័យចប់ដោយសង្ខេប ។

# សេក្ខិយវត្ត

វត្តដែលសាមណេរគប្បីសិក្សា ឈ្មោះសេក្ខិយវត្ត ។ នោះ ចាត់ជា ៤ ពួក ពួកទី ១ ឈ្មោះ **សារូបៈ** ពួកទី ២ ឈ្មោះ **ភោជនប្បដិសំយុត្តៈ** ពួកទី ៣ ឈ្មោះ **ធម្មទេសនាបដិសំយុត្តៈ** ពួកទី ៤ ឈ្មោះ **បកិណ្ណកៈ** ។

## សារូប ទី ១ មាន ២៦

១- **បរិមណ្ឌលនិវាសន** សាមណេរ គប្បីសិក្សាថា អញនឹងស្លៀកឲ្យជាបរិមណ្ឌល គឺខាងក្រោមគ្របក្បាលជង្គង់ចុះទៅ ៨ ធ្នាប់ ខាងលើបិទមណ្ឌលផ្ចិត ខាងមុខ-ក្រោយត្រឹមស្មើគ្នា ។

២- **បរិមណ្ឌលបារុបន** សាមណេរ គប្បីសិក្សាថា អញនឹងគ្រងចីវរឲ្យជាបរិមណ្ឌល គឺខាងក្រោមទីបទៀនលើស្បង់ ៤ ធ្នាប់ ខាងលើបិទចុងកែងដៃខាងឆ្វេង ឲ្យរៀបរយមិនឲ្យរយីករយាក ។

៣- **សុប្បដិច្ឆន្នោ អន្តរឃរេ គមន** សាមណេរ គប្បីសិក្សាថា អញនឹងបិទបាំងកាយឲ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ ។

៤- **សុប្បដិច្ឆន្នោ អន្តរឃរេ និសីទន** សាមណេរ គប្បីសិក្សាថា អញនឹងបិទបាំងកាយឲ្យល្អ អង្គុយនៅក្នុងចន្លោះផ្ទះ ។

៥- **សុសំវុតោ អន្តរឃរេ គមន** សាមណេរគប្បីសិក្សាថា អញនឹងសង្រួមប្រយ័ត្នដោយល្អ គឺមិនបានលាស់ដៃ-ជើង ដើរទៅក្នុងចន្លោះផ្ទះ ។

៦- សុសិរុគោ អន្តរាយរ និសីទន សាមណេរ គប្បីសិក្សាថា អញនឹងស្រ្ទីមប្រយ័ត្នដោយល្អ គឺមិនបាចរលាស់ដៃជើង អង្គុយនៅក្នុងចន្លោះផ្ទះ ។

៧- ឧក្ខិត្តចក្ខុ អន្តរាឃរ គមន សាមណេរគប្បីសិក្សាថា អញនឹងសម្លឹងខាងក្រោម គឺក្រឡេកមើលប្រមាណ១ជួរនឹម ដើរទៅក្នុងចន្លោះផ្ទះ ។

៨- ឧក្ខិត្តចក្ខុ អន្តរឃរ និសីទន សាមណេរគប្បីសិក្សាថា អញនឹងសម្លឹងខាងក្រោម គឺក្រឡេកមើលប្រមាណ ១ ជួរនឹម អង្គុយនៅក្នុងចន្លោះផ្ទះ ។

៩- ន ឧក្ខិត្តកាយ អន្តរឃរ គមន សាមណេរគប្បីសិក្សាថា អញនឹងមិនសើយចីវរលាតកន្សើញ ដើរទៅក្នុងចន្លោះផ្ទះ ។

១០- ន ឧក្ខិត្តកាយ អន្តរឃរ និសីទន សមណេរគប្បីសិក្សាថា អញនឹងមិនសើយចីវរលាតកន្សើញ អង្គុយនៅក្នុងចន្លោះផ្ទះ ។

១១ ន ឧជ្ជគ្ឃិកាយ អន្តរឃរ គមន សាមណេរគប្បីសិក្សាថា អញនឹងមិនសើចខ្លាំង ដើរទៅក្នុងចន្លោះផ្ទះ ។

១២- ន ឧជ្ជគ្ឃិកាយ អន្តរឃរ និសីទន សាមណេរគប្បីសិក្សាថា អញនឹងមិនសើចខ្លាំង អង្គុយនៅក្នុងចន្លោះផ្ទះ ។

១៣- អប្បសទ្ទា អន្តរឃរ គមន សាមណេរគប្បីសិក្សាថា អញនឹងនិយាយសម្លេងតិច ១ ដើរទៅក្នុងចន្លោះផ្ទះ ។

១៤- អប្បសទ្ទា អន្តរឃរេ និសីទន សាមណេរ គប្បីសិក្សាថា អញនឹងនិយាយសម្លេងតិចៗ អង្គុយនៅក្នុងចន្លោះផ្ទះ ។

១៥- ន កាយប្បចាលកំ អន្តរឃរេ គមន សាមណេរ គប្បីសិក្សាថា អញនឹងមិនគ្រលែងកាយ ដើរទៅក្នុងចន្លោះផ្ទះ ។

១៦- ន កាយប្បចាលកំ អន្តរឃរេ និសីទន សាមណេរគប្បីសិក្សាថា អញនឹងមិនគ្រលែងកាយ អង្គុយនៅក្នុងចន្លោះផ្ទះ ។

១៧- ន ពាហុប្បចាលកំ អន្តរឃរេ គមន សាមណេរ គប្បីសិក្សាថា អញនឹងមិនបង់ដោយ ដើរទៅក្នុងចន្លោះផ្ទះ ។

១៨- ន ពាហុប្បចាលកំ អន្តរឃរេ និសីទន សាមណេរគប្បីសិក្សាថា អញនឹងមិនយោលដៃ អង្គុយនៅក្នុងចន្លោះផ្ទះ ។

១៩- ន សីសប្បចាលកំ អន្តរឃរេ គមន សាមណេរគប្បីសិក្សាថា អញនឹងមិនអង្រួនក្បាល ដើរទៅក្នុងចន្លោះផ្ទះ ។

២០- ន សីសប្បចាលកំ អន្តរឃរេ និសីទន សាមណេរគប្បីសិក្សាថា អញនឹងមិនអង្រួនក្បាល អង្គុយនៅក្នុងចន្លោះផ្ទះ ។

២១- ន ខម្ភកតោ អន្តរឃរេ គមន សាមណេរ គប្បីសិក្សាថា អញនឹងមិនស្ទីមចង្កេះ ដើរទៅក្នុងចន្លោះផ្ទះ ។

២២- ន ខម្ភកតោ អន្តរឃរេ និសីទន សាមណេរ គប្បីសិក្សាថា អញនឹងមិនស្ទីមចង្កេះ អង្គុយនៅក្នុងចន្លោះផ្ទះ ។



www.elibraryofcambodia.org

២៣. ន ឧក្កុណ្ឌិកោ អន្តរឃរេ គមន សាមណេរគប្បីសិក្សាថា អញនឹងមិនទទូរក្បាល ដើរទៅក្នុងចន្លោះផ្ទះ ។

២៤- ន ឧក្កុណ្ឌិកោ អន្តរឃរេ និសីទន សាមណេរគប្បីសិក្សាថា អញនឹងមិនទទូរក្បាល អង្គុយនៅក្នុងចន្លោះផ្ទះ ។

២៥- ន ឧក្កុដិកាយ អន្តរឃរេ គមន សាមណេរគប្បីសិក្សាថា អញនឹងមិនចំអើតជើង ដើរទៅក្នុងចន្លោះផ្ទះ ។

២៦- ន បល្លត្ថិកាយ អន្តរឃរេ និសីទន សាមណេរគប្បីសិក្សាថា អញនឹងមិនត្របោមក្បាលជង្គង់ អង្គុយនៅក្នុងចន្លោះផ្ទះ ។

សារូប ចប់ ។

## ភោជនប្បដិសំយុត្ត ទី ២ មាន ៣០

១- សក្កច្ចំ បិណ្ឌបាតប្បដិគ្គហណ សាមណេរគប្បីសិក្សាថា អញនឹងទទួលបិណ្ឌបាតដោយគោរព គឺមិនធ្វើអាការដូចជាចាក់ចោល ។

២- បត្តសញ្ញី បិណ្ឌបាតប្បដិគ្គហណ សាមណេរគប្បីសិក្សាថា អញនឹងសម្គាល់តែក្នុងបាត្រ ទទួលបិណ្ឌបាត គឺមិនបានក្រឡេកមើលទៅទីដទៃ ។



www.elibraryofcambodia.org

៣- សមសូបកបិណ្ឌបាតប្បដិគ្គហណ សាមណេរគប្បីសិក្សាថា អញនឹងទទួលបិណ្ឌបាតឲ្យមានសម្លស្មើគ្នា ។

៤- សមតិត្តិកបិណ្ឌបាតប្បដិគ្គហណ សាមណេរគប្បីសិក្សាថា អញនឹងទទួលបិណ្ឌបាតស្មើតែត្រឹមមាត់បាត្រ ។

៥- សក្កច្ចំ បិណ្ឌបាតភុញ្ជន សាមណេរគប្បីសិក្សាថា អញនឹងបរិភោគចង្ហាន់បិណ្ឌបាតដោយគោរព គឺមិនធ្វើអាការដូចជាមិនចង់បរិភោគ ។

៦- បត្តសញ្ញី បិណ្ឌបាតភុញ្ជន សាមណេរគប្បីសិក្សាថា អញនឹងសម្គាល់តែក្នុងបាត្រ បរិភោគចង្ហាន់បិណ្ឌបាត គឺ មិនបានក្រឡេកមើលទៅទីដទៃ ៗ ។

៧- សបទានបិណ្ឌបាតភុញ្ជន សាមណេរគប្បីសិក្សាថា អញនឹងបរិភោគចង្ហាន់បិណ្ឌបាតរាបឲ្យស្មើ គឺមិនបានកកាយរូងខាងកណ្ដាល ។

៨- សមសូបកបិណ្ឌបាតភុញ្ជន សាមណេរគប្បីសិក្សាថា អញនឹងបរិភោគចង្ហាន់បិណ្ឌបាតមានសម្លស្មើគ្នា ។

៩- ន ថូបតោ ឱមទ្ទិត្វា បិណ្ឌបាតភុញ្ជន សាមណេរគប្បីសិក្សាថា អញនឹងមិនបានប្រមចុះអំពីកំពូលបាយ ហើយបរិភោគនូវចង្ហាន់បិណ្ឌបាត ។



www.elibraryofcambodia.org

១០- ន សូបំ វា ព្យញ្ជនំ វា ឱទនេន បដិច្ឆាទេន សាមណេរគប្បីសិក្សាថា អញនឹងមិនកកាយបាយ លុបសម្ល ឬ ម្ហូបក្រៀម ដើម្បីនឹងឲ្យទាយកគេឲ្យច្រើន ។

១១- ន សូបំ វា ព្យញ្ជនំ វា ឱទនំ វា អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជេន សាមណេរគប្បីសិក្សាថា អញមិនមានជំងឺនឹងមិនសុំសម្ល ឬ ម្ហូបក្រៀម ឬ បាយ ដើម្បីខ្លួនហើយបរិភោគ ។

១២- ន ឧជ្ឈានសញ្ញី បរេសំ បត្តឱលោកេន សាមណេរគប្បីសិក្សាថា អញនឹងមិនសម្គាល់គិតលើកទោស សម្លឹងមើលបាត្រសាមណេរដទៃ ។

១៣- នាតិមហន្តកពឡករណ សាមណេរគប្បីសិក្សាថា អញនឹង មិនធ្វើពំនូតបាយឲ្យធំហួសប្រមាណ ។

១៤- ន កពឡាវច្ឆេទកភុញ្ជេន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគ ខាំកាត់ពំនូតបាយមុះបេក់ណាក់មួន ។

១៥- បរិមណ្ឌលអាលោបករណ សាមណេរគប្បីសិក្សាថា អញនឹង ធ្វើពំនូតបាយឲ្យជាបរិមណ្ឌល គឺឲ្យមូល ។

១៦- ន អនាហដេ កពឡេ មុខទ្វារវិវរណ សាមណេរគប្បីសិក្សាថា អញកាលបើពំនូតបាយ មិនទាន់ដល់មាត់ នឹងមិនហាមាត់ចាំ ។



www.elibraryofcambodia.org

១៧- ន ភុញ្ជមានោ សព្វំ ហត្ថំ មុខេ បក្ខិបន សាមណេរគប្បីសិក្សាថា អញកាលបរិភោគ នឹងមិនញាត់ម្រាមដៃទាំងអស់ក្នុងមាត់ ។

១៨- ន សកពឡេន មុខេន ព្យាហរណា សាមណេរគប្បីសិក្សាថា អញនឹងមិននិយាយទាំងពោជខក្នុងមាត់ ។

១៩- ន បិណ្ឌុក្ខេបកភុញ្ជន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគបោះដុំបាយ ដុំត្រី ដុំសាច់ជាដើម ចូលក្នុងមាត់ ។

២០- ន អវគណ្ឌការភុញ្ជន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគ បៀមពំនូតបាយឲ្យទុលថ្ពាល់ឡើងដូចជាស្វា ។

២១- ន ហត្ថនិទ្ធូនភុញ្ជន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគរលាស់ដៃបណ្ដើរ ។

២២- ន សិត្ថាវការភុញ្ជន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគឲ្យពោយពាយគ្រាប់បាយ ។

២៣- ន ជិវ្ហានិច្ឆារភុញ្ជន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគលៀនអណ្ដាតចេញមកខាងក្រៅ ។

២៤- ន ចបុចបុការភុញ្ជន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគឲ្យឮថ្លប់ ៗ ។

២៥- ន សុរុសុរុការភុញ្ជន សាមណេគប្បីសិក្សាថា អញនឹងមិនបរិភោគហុតទឹកសម្លជាដើមឲ្យឮគ្រូក ៗ ។



www.elibraryofcambodia.org

២៦- ន ហត្ថនិល្លេហកភុញ្ជន *សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគលិទ្ធដៃ ។*

២៧- ន បត្តនិល្លេហកភុញ្ជន *សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគលិទ្ធបាត្រ ។*

២៨- ន ឱដ្ឋនិល្លេហកភុញ្ជន *សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគលិទ្ធបបូរមាត់ ។*

២៩- ន សាមិសេន ហត្ថេន បានីយថាលកប្បដិគ្គហណ *សាមណេរគប្បីសិក្សាថា អញនឹងមិនទទួលភាជនៈទឹក ដោយដៃប្រឡាកអាមិស ។*

៣០- ន សសិត្ថកំ បត្តធោវនំ អន្តរឃរេ ឆឌ្ឌន *សាមណេរគប្បីសិក្សាថា អញនឹងមិនចាក់ទឹកដែលលាងបាត្រ ក្នុងចន្លោះផ្ទះ ទាំងគ្រាប់បាយ ។*

ភោជនប្បដិសំយុត្ត ចប់ ។

## ធម្មទេសនាបដិសំយុត្ត ទី ៣ មាន ១៦

១- ន ឆត្តបាណិស្ស អគ្គិលានស្ស ធម្មទេសន *សាមណេរគប្បីសិក្សាថា អញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជំងឺ មានឆ័ត្រក្នុងដៃ ។*

២- ន ឧណ្ណាបាណិស្ស អគ្គិលានស្ស ធម្មំទេសន

សាមណេរគប្បីសិក្សាថា អញនឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ មានឈើច្រត់ក្នុងដៃ ។

៣- ន សត្ថបាណិស្ស អគ្គិលានស្ស ធម្មំទេសន

សាមណេរគប្បីសិក្សាថា អញនឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ មានគ្រឿងសស្ត្រាក្នុងដៃ ។

៤- ន អាវុធបាណិស្ស អគ្គិលានស្ស ធម្មំទេសន

សាមណេរគប្បីសិក្សាថា អញនឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ មានអាវុធក្នុងដៃ ។

៥- ន បាទុការូឡ្ហស្ស អគ្គិលានស្ស ធម្មំទេសន

សាមណេរគប្បីសិក្សាថា អញនឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ ពាក់ទ្រនាប់ជើងឈើ ឬទ្រនាប់ជើងស្បែកជាដើម ។

៦- ន ឧបាហនារូឡ្ហស្ស អគ្គិលានស្ស ធម្មំទេសន

សាមណេរគប្បីសិក្សាថា អញនឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ ពាក់ស្បែកជើង ។

៧- ន យានគតស្ស អគ្គិលានស្ស ធម្មំទេសន

សាមណេរគប្បីសិក្សាថា អញនឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ នៅលើយានមានរថជាដើម ។

៨- ន សយនគតស្ស អគ្គិលានស្ស ធម្មទេសន សាមណេរគប្បីសិក្សាថា អញនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ នៅលើទីដេក ។

៩- ន បល្លត្ថិកាយ និសិន្នស្ស អគ្គិលានស្ស ធម្មទេសន សាមណេរគប្បីសិក្សាថា អញនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ អង្គុយក្របោមក្បាលជង្គង់ ។

១០- ន វេឋិតសីសស្ស អគ្គិលានស្ស ធម្មទេសន សាមណេរគប្បីសិក្សាថា អញនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ ឈ្នួតក្បាល ។

១១- ន ឱគុណ្ឋិតសីសស្ស អគ្គិលានស្ស ធម្មទេសន សាមណេរគប្បីសិក្សាថា អញនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺទទូរក្បាល ។

១២- ន ឆមាយំ និសីទិត្វា អាសនេ និសិន្នស្ស អគ្គិលានស្ស ធម្មទេសន សាមណេរគប្បីសិក្សាថា អញនឹងមិនអង្គុយលើផែនដី សម្តែងធម៌ដល់មនុស្សគ្មានជំងឺ អង្គុយលើទីអាសនៈ មានកន្ទេលជាដើម ។

១៣- ន នីចេ អាសនេ និសីទិត្វា ឧច្ចេ អាសនេ និសិន្នស្ស អគ្គិលានស្ស ធម្មទេសន សាមណេរគប្បី



www.elibraryofcambodia.org

*សិក្សាថា អញនឹងមិនអង្គុយលើទីអាសនៈទាប សម្តែងធម៌ដល់មនុស្ស គ្មានជំងឺ អង្គុយលើទីអាសនៈខ្ពស់ ។*

១៤- ន ឋិតោ និសិន្នស្ស អគិលានស្ស ធម្មទេសន *សាមណេរគប្បីសិក្សាថា អញនឹងមិនឈរសម្តែងធម៌ដល់ មនុស្សគ្មានជំងឺ ដែលអង្គុយ ។*

១៥- ន បច្ឆតោ គច្ឆន្តោ បុរតោ គច្ឆន្តស្ស អគិលានស្ស ធម្មទេសន *សាមណេរគប្បីសិក្សាថា អញនឹងមិន ដើរអំពីខាងក្រោយ សម្តែងធម៌ដល់មនុស្សគ្មានជំងឺ ដើរអំពីខាងមុខ ។*

១៦- ន ឧប្បថេន គច្ឆន្តោ បថេន គច្ឆន្តស្ស អគិលានស្ស ធម្មទេសន *សាមណេរគប្បីសិក្សាថា អញនឹង មិនដើរក្រៅផ្លូវ សម្តែងធម៌ដល់មនុស្សគ្មានជំងឺ ដើរក្នុងផ្លូវ ។*

ធម្មទេសនាបដិសំយុត្ត ចប់ ។

## បកិណ្ណកៈ ទី ៤ មាន ៣

១- ន ឋិតោ អគិលានោ ឧច្ចារំ វា បស្សាវំ វា ករណ *សាមណេរគប្បីសិក្សាថា អញគ្មានជំងឺ នឹងមិនឈរ បន្ទោរឧច្ចារៈ ឬ បស្សាវៈ ។*

២- ន ហរិតេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករណ *សាមណេរគប្បីសិក្សាថា អញគ្មានជំងឺ*

ខ្ញុំនឹងមិនបន្ទោឧច្ចារៈ បស្សាវៈ ឬ ស្តោះទឹកមាត់ដាក់លើភូតគាម គឺ ដើមឈើ ឬ គុម្ពស្មៅ ។

**៣- ន ឧទកេ អគ្គិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករេយ្យ** សាមណេរគប្បីសិក្សាថា អញគ្មានជំងឺ ខ្ញុំនឹងមិនបន្ទោឧច្ចារៈ បស្សាវៈ ឬ ស្តោះទឹកមាត់ដាក់លើទឹក ដែលមិនគួរនឹងធ្វើជុះធ្លាះបាន ។

បកិណ្ណកៈ ចប់ ។

**សេខិយវត្ត** ទាំង៧៥នេះ កុលបុត្រដែលបានបព្វជ្ជាជាសាមណេររួចហើយ ត្រូវសិក្សាជាលំដាប់អំពី **សាមណេរវិន័យ** មកឯវត្តដែលសាមណេរត្រូវសិក្សានោះ មិនបានមានតែសេខិយវត្តប៉ុណ្ណោះក៏ទេ វត្តដទៃទៀតដែលព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្ត និងអនុញ្ញាតក្នុងខន្ធកវិន័យនោះក្តី សិក្ខាបទដែលជាលោកវជ្ជៈមានសុក្កវិសដ្ឋិសិក្ខាបទជាដើមនោះក្តី សាមណេរក៏ត្រូវសិក្សាឲ្យបានដឹង ហើយត្រូវប្រព្រឹត្តតាម ដូចជាភិក្ខុដែរ បើសាមណេរឯណា មិនប្រព្រឹត្តតាម សាមណេរនោះ ឈ្មោះថា **អលជ្ជី** ព្រះឧបជ្ឈាយ៍ ឬ អាចារ្យ ត្រូវធ្វើទណ្ឌកម្មដល់សាមណេរនោះ តាមសមគួរដល់ទោសដែលប្រព្រឹត្តល្មើសកន្លង ។

សេខិយវត្ត ចប់ ។



www.elibraryofcambodia.org

# បច្ចវេក្ខណៈ

កុលបុត្រដែលបួសក្នុងព្រះពុទ្ធសាសនា ត្រូវសិក្សាក្នុងបច្ចវេក្ខណៈ គឺលក្ខណៈសម្រាប់ពិចារណា នូវបច្ច័យដែលខ្លួនត្រូវអាស្រ័យ ឲ្យប្រះចាំស្ទាត់តាំងបាលី និងសេចក្ដីប្រែជាសម្រាយ ឯបច្ច័យដែលបព្វជិត ត្រូវអាស្រ័យនោះមាន៤ គឺ **ចីវរបច្ច័យ** សំពត់ដែលបព្វជិតគួរស្លៀកដណ្ដប់ប្រើប្រាស់បាន មានត្រៃចីវរជាដើម ១, **បិណ្ឌបាតបច្ច័យ** គោជនាហារ ដែលបព្វជិតត្រូវបរិភោគបាន តាំងអំពីវេលាអរុណរះឡើង ដរាបដល់ថ្ងៃត្រង់ មានបាយទំជាដើម ១, **សេនាសនបច្ច័យ** ទីសេនាសនៈ ដែលបព្វជិតត្រូវអាស្រ័យប្រើប្រាស់បាន មានកុដិ សាលាជាដើម ១, **គិលានបច្ច័យ** ថ្នាំសម្រាប់មនុស្សមានជំងឺ ដែលបព្វជិតត្រូវបរិភោគប្រើប្រាស់បាន មានសប្បិជាដើម ១ ។

ក្នុងបច្ច័យមួយ ៗ នោះ ពោលដោយ**បច្ចវេក្ខណៈ** គឺលក្ខណៈសម្រាប់ពិចារណាមានបួន ។ គឺ **ធាតុបច្ចវេក្ខណៈ** ១ **បដិកូលបច្ចវេក្ខណៈ** ១ **តង្ខណិកបច្ចវេក្ខណៈ** ១ **អតីតបច្ចវេក្ខណៈ** ១ ។

# ធាតុបច្ចវេក្ខណៈ

ធាតុបច្ចវេក្ខណៈនោះ គឺឲ្យពិចារណាក្នុងកាលដែលទទួលនូវបច្ច័យ៤ ឲ្យឃើញថាជា**ធាតុ** ៗ កាលដែលទទួលនូវ**ចីវរបច្ច័យ** ឲ្យពិចារណាដូច្នេះថា

យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ
យទិទំ ចីវរំ តទុបភុញ្ជកោ ច បុគ្គលោ
ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ

*សំពត់ចីវរឯណានេះ សំពត់ចីវរនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកប្រើប្រាស់សំពត់ចីវរនោះក្ដី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។*

*កាលដែលទទួលនូវ* បិណ្ឌបាតបច្ច័យ *ឲ្យពិចារណាដូច្នេះថា*

យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ
យទិទំ បិណ្ឌបាតោ តទុបភុញ្ជកោ ច បុគ្គលោ
ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ

*ចង្ហាន់បិណ្ឌបាតឯណានេះ ចង្ហាន់បិណ្ឌបាតនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគចង្ហាន់បិណ្ឌបាតនោះក្ដី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។*

*កាលដែលទទួលនូវ* សេនាសនបច្ច័យ *ឲ្យពិចារណាដូច្នេះថា*

យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ
យទិទំ សេនាសនំ តទុបភុញ្ជកោ ច បុគ្គលោ
ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ

ទីសេនាសនៈឯណានេះ ទីសេនាសនៈនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគប្រើប្រាស់សេនាសនៈនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

កាលដែលទទួល នូវ **គិលានប្បច្ច័យ** ត្រូវពិចារណាដូច្នេះថា

**យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ**

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺឯណានេះ គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគគ្រឿងបរិក្ខារ ជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

## បដិកូលប្បច្ចវេក្ខណៈ

បដិកូលប្បច្ចវេក្ខណៈនោះ គឺត្រូវពិចារណា ក្នុងខណៈដែលប្រើប្រាស់ និងបរិភោគនូវបច្ច័យ ៤ ត្រូវឃើញថា ជារបស់បដិកូលគួរខ្ពើមរអើម ។



www.elibraryofcambodia.org

កាលដែលព្រះពុទ្ធជនប្រើប្រាស់ នូវចីវរប្បច្ច័យ ត្រូវពិចារណាដូច្នេះថា

សព្វានិ បនិមានិ ចីវរានិ
អជិគុច្ឆនីយានិ ឥមំ បូតិកាយំ បត្វា
អតិវិយ ជិគុច្ឆនីយានិ ជាយន្តិ

សំពត់ចីវរទាំងឡាយទាំងអស់នេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។

កាលដែលព្រះពុទ្ធជនបរិភោគប្រើប្រាស់ នូវបិណ្ឌបាតប្បច្ច័យ ត្រូវពិចារណាដូច្នេះថា

សព្វោ បនាយំ បិណ្ឌបាតោ
អជិគុច្ឆនីយោ ឥមំ បូតិកាយំ បត្វា
អតិវិយ ជិគុច្ឆនីយោ ជាយតិ

ចង្ហាន់បិណ្ឌបាតទាំងអស់នេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។

កាលដែលព្រះពុទ្ធជនបរិភោគប្រើប្រាស់ នូវសេនាសនប្បច្ច័យ ត្រូវពិចារណាដូច្នេះថា

**សព្វានិ បនិមានិ សេនាសនានិ**
**អជិគុច្ឆនីយានិ ឥមំ បូតិកាយំ បត្វា**
**អតិវិយ ជិគុច្ឆនីយានិ ជាយន្តិ**

ទីសេនាសនៈទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។

កាលដែលប្រាជ្ញនឹងបរិភោគ នូវគិលានប្បច្ច័យ ឲ្យពិចារណាដូច្នេះថា

**សព្វោ បនាយំ គិលានប្បច្ចយភេសជ្ជ-**
**បរិក្ខារោ អជិគុច្ឆនីយោ ឥមំ បូតិកាយំ**
**បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ**

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។

## តង្ខណិកប្បច្ចវេក្ខណៈ

តង្ខណិកប្បច្ចវេក្ខណៈនោះ គឺឲ្យពិចារណាក្នុងខណៈដែលបរិភោគនូវបច្ច័យទាំង ៤ ។

*កាលដែលប្រើប្រាស់នូវ* ចីវរប្បច្ច័យ *ត្រូវពិចារណាដូច្នេះថា*

បដិសង្ខា យោនិសោ ចីវរំ បដិសេវាមិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរឹសប(១) សម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោបិនប្បដិច្ឆាទនត្ថំ

*បព្វជិត គប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេព គឺប្រើប្រាស់នូវសំពត់ចីវរ កំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវក្តៅ ដើម្បីនឹងការពារនូវសម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ កំណត់ទុក ដើម្បីនឹងបិទបាំងនូវអវយវៈ ដែលធ្វើនូវសេចក្តីខ្មាសឲ្យកម្រើក ។*

*កាលដែលបរិភោគ នូវ*បិណ្ឌបាតប្បច្ច័យ *ត្រូវពិចារណាដូច្នេះថា*

បដិសង្ខា យោនិសោ បិណ្ឌបាតំ បដិសេវាមិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសូបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។

---

១ សិរឹសប្ប ឥតិបិ សំយោគោ កតោ ហោតិ ។



www.elibraryofcambodia.org

បព្វជិត គប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេព គឺ បរិភោគចង្ហាន់បិណ្ឌបាត ដើម្បីនឹងលេងដូចកូនអ្នកស្រុកក៏ទេ ដើម្បីនឹងឲ្យកើតបុរិសមានះស្រវឹង ដូចអ្នកប្រដាល់ក៏ទេ ដើម្បីនឹងប្រដាប់កាក់តែងរាងកាយដូចស្រ្តីក្នុងវាំងក៏ទេ ដើម្បីនឹងធ្វើឲ្យផូរផង់សម្បុរដូចអ្នកលេងរបាំក៏ទេ បរិភោគក៏ណាត់ទុក ដើម្បីនឹងឲ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញុំាងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចរិយៈ អញនឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានដែលមានហើយផង នឹងញុំាងវេទនាថ្មី គឺឆ្អែតហួសប្រមាណមិនឲ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តីមិនមានទោស អាងមិនប្រទូសកាយមិនប្រទូសចិត្តជាដើមក្តី កិរិយានៅសប្បាយក្នុងឥរិយាបថទាំង ៤ ក្តី នឹងមានដល់អញ ដោយបានបរិភោគនូវចង្ហាន់បិណ្ឌបាតនេះ ៗ

កាលដែលបរិភោគប្រើប្រាស់ នូវ **សេនាសនប្បច្ច័យ** ឲ្យពិចារណាដូច្នេះថា

**បដិសង្ខា យោនិសោ សេនាសនំ បដិសេ-វាមិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតប-សិរឹសបសម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ** (១)

១ សព្វបោត្ថកេសុ ឦទិសោយេវ បាឋោ ទិស្សតិ ។

បព្វជិត គប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេព គឺបរិភោគប្រើប្រាស់នូវទីសេនាសនៈ កំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវក្តៅ ដើម្បីនឹងការពារនូវសម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូចតាច់ធំទាំងឡាយ កំណត់ទុក ដើម្បីនឹងបន្ទោបង់នូវគ្រលំគ្រាយ ដែលកើតអំពីរដូវ ហើយអភិរម្យសម្ងំនៅក្នុងកម្មដ្ឋាន ។

កាលដែលបរិភោគ នូវគិលានប្បច្ច័យ ឲ្យពិចារណាដូច្នេះថា

បដិសង្ខា យោនិសោ គិលានប្បច្ចយ-
ភេសជ្ជបរិក្ខារំ បដិសេវាមិ យាវទេវ
ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ
បដិឃាតាយ អព្យាបជ្ឈបរមតាយាតិ ។

បព្វជិត គប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេព គឺបរិភោគនូវគ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ កំណត់ទុក ដើម្បីនឹងការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា ។

## អតីតប្បច្ចវេក្ខណៈ

អតីតប្បច្ចវេក្ខណៈនោះ គឺឲ្យពិចារណានូវបច្ច័យ ៤ ក្នុងអតីតកាល គឺកាលដែលបរិភោគរួចហើយ ដែលត្រូវពិចារណាបានតែក្នុង


www.elibraryofcambodia.org

ថ្ងៃនោះ គឺក្នុងវេលាយប់ ១ ថ្ងៃ ១ កុំឲ្យអរុណរះឡើងកាន់ ក្នុងបច្ចវេក្ខណៈមួយ ៗ ពិចារណា ១ចប់ ឬ ២ចប់ ៣ចប់ ក៏បាន ។

កាលដែលនឹងពិចារណា នូវ**ចីវរប្បច្ច័យ** ឲ្យពិចារណាដូច្នេះថា

**អជ្ជ មយា អបច្ចវេក្ខិត្វា យំ ចីវរំ បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរីសបសម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោបិនប្បដិច្ឆាទនត្ថំ**

សំពត់ចីវរឯណា ដែលអញមិនបានពិចារណាហើយ ប្រើប្រាស់ហើយក្នុងថ្ងៃនេះ សំពត់ចីវរនោះ អញប្រើប្រាស់កំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវក្តៅ ដើម្បីនឹងការពារនូវសម្ផស្សរបោម មូស ខ្យល់ កំដៅថ្ងៃ និងពស់គប ពស់ធំទាំងឡាយ កំណត់ទុកដើម្បីនឹងបិទបាំង នូវអវៈយវៈដែលធ្វើឲ្យសេចក្តីអៀនខ្មាសឲ្យកម្រើកៗ

កាលដែលនឹងពិចារណា នូវ**បិណ្ឌបាតប្បច្ច័យ** ឲ្យពិចារណាដូច្នេះថា

**អជ្ជ មយា អបច្ចវេក្ខិត្វា យោ បិណ្ឌបាតោ បរិភុត្តោ សោ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។**

បច្ច័យបិណ្ឌបាតឯណា ដែលអញមិនបានពិចារណាហើយ បរិភោគហើយក្នុងថ្ងៃនេះ បច្ច័យបិណ្ឌបាតនោះ អញបរិភោគ ដើម្បីមិនលេងដូចក្មេងអ្នកស្រុកក៏ទេ ដើម្បីមិនឲ្យកើតបរិសមានមទៈស្រវឹង ដូចអ្នកប្រដាល់ក៏ទេ ដើម្បីមិនប្រដាប់តាក់តែងកាយ ដូចស្រីក្នុងបុរីក៏ទេ ដើម្បីមិនធ្វើឲ្យផូរផង់សម្បុរដូចអ្នកលេងរបាំក៏ទេ បរិភោគកំណត់ទុក ដើម្បីនឹងឲ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចរិយៈ អញនឹងកំចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានដែលមានហើយផង នឹងញ៉ាំងវេទនាថ្មី គឺឆ្អែតហួសប្រមាណ មិនឲ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ នឹងសេចក្តីមិនមានទោស មានមិនប្រទូសកាយ មិនប្រទូសចិត្តជាដើមក្តី កិរិយានៅសប្បាយក្នុងឥរិយាបថទាំង ៤ ក្តី នឹងមានដល់អញ ដោយបានបរិភោគនូវបច្ច័យបិណ្ឌបាតនេះ ។

កាលដែលមិនពិចារណានូវសេនាសនបច្ច័យ ឲ្យពិចារណាដូច្នេះថា

អជ្ជ មយា អបច្ចវេក្ខិត្វា យំ សេនាសនំ បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតប-សិរឹសបសម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ

ទីសេនាសនៈឯណា ដែលអញមិនបានពិចារណាហើយ បរិភោគ

ប្រើប្រាស់ហើយក្នុងថ្ងៃនេះ ចីវរសេនាសនៈនោះ អញបរិភោគកំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវក្ដៅ ដើម្បីនឹងការពារនូវសម្ផស្ស របោម មូស ខ្យល់ កម្ដៅថ្ងៃ និងពស់តូចពស់ធំទាំងឡាយ កំណត់ទុក ដើម្បីនឹងបន្ទោបង់នូវក្រវល់ក្រវាយដែលកើតអំពីរដូវ ហើយអភិរម្យសម្ងំនៅក្នុងកម្មដ្ឋាន ។

កាលដែលនឹងពិចារណានូវ**គិលានប្បច្ច័យ** ត្រូវពិចារណាដូច្នេះថា

**អជ្ជ មយា អបច្ចវេក្ខិត្វា យោ គិលាន-ប្បច្ចយភេសជ្ជបរិក្ខារោ បរិភុត្តោ សោ យាវ-ទេវ ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយាតិ ។**

គ្រឿងបរិក្ខារជាទីគាំទ្រនូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺឯណា ដែលអញមិនបានពិចារណាហើយ បរិភោគហើយក្នុងថ្ងៃនេះ គ្រឿងបរិក្ខារជាទីគាំទ្រនូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនោះ អញបរិភោគកំណត់ទុក ដើម្បីនឹងការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេង ៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខទាំងជាធម្មតា ។

បើកាលដែលទទួល និងកាលដែលប្រារព្ធដើម្បីបរិភោគ និងកាលដែលបរិភោគនោះ បានពិចារណាដោយ**ធាតុប្បច្ចវេក្ខណៈ** ដោយ**បដិកូលប្បច្ចវេក្ខណៈ** ដោយ**តង្ខណិកប្បច្ចវេក្ខណៈ** រួចសព្វគ្រប់ហើយ និងមិនបាច់ពិចារណាក្នុង **អតីតប្បច្ចវេក្ខណៈ** ទៀតក៏បាន ។

**បច្ចវេក្ខណៈ ចប់ ។**

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ |
|---|---|---|---|
| ១ | ១១ | ស្រះ | ស្រៈ |
| ២ | ៥ | សេដ្ឋិ | សេដ្ឋី |
| ៣ | ៤ | សេកំ | សេកុំ |
| ៥ | ១៨ | ព្យញ្ជនះ | ព្យញ្ជនៈ |
| ៨ | ៩ | សអ្កន្ទៈ | សក្កន្ទ |
| ១២ | ៦ | កាសារ.ដុំះ | កាសារៈដុំះ |
| ១៧ | ១៩ | ការញ្ញ | ការុញ្ញ |
| ១៨ | ២ | ខ្យមការន្តៈ | ខ្យជាម-ការន្តៈ |
| ១៨ | ៧ | ធម៌ម | ធម្ម៌ |
| ២០ | ១១ | ប្រាបនូវបាត្រ | ប្រាប់នូវបាត្រ |
| ២១ | ១៩ | ពកម្មបូស | រោគពកម្មប៉ូស |
| ២៨ | ១៤ | បិណ្ឌបាត្រ | បិណ្ឌបាត |
| ៣២ | ១៩ | សមណ | សមណៈ |
| ៣៣ | ២ | ឧភរិ | ឧក្ករិ- |
| ៣៣ | ១៦ | អាចេដីម្បី | អាចដើម្បី |
| ៣៤ | ៥ | ក្នុងបញ្ញា | ក្នុងបញ្ញា- |
| ៣៦ | ៧ | ក្នុងឧបជ្ឈាយ៍ | ក្នុងឧបជ្ឈាយវិធី |
| ៤៤ | ២៣ | អនុនាសិកន្តៈ | នាសិកន្តៈ |
| ៤៥ | ១២ | អនុនាសិកន្តៈ | នាសិកន្តៈ |
| ៤៥ | ១៤ | ខុទ្ទកនិវ្ឋារកណៈ | ខុទ្ទកនិវ្ឋាករណ៍ |
| ៤៦ | ៦ | ចតុរស្សះ | ចតុរស្សៈ |

www.elibraryofcambodia.org

| | | | |
|---|---|---|---|
| ៤៧ | ៩ | សាមណេរត្រូវ | សាមណេរត្រូវ |
| ៤៨ | ១៥ | សង្ឃ | សង្ឃ- |
| ៥១ | ៤ | អនុស្សាវនៈបទ១ | អនុស្សាវនសាម ១ |
| ៥២ | ៦ | ឥត្ថន្នាម្មោ | ឥត្ថន្នាមោ |
| ៥៣ | ៥ | បដ្ឋាយ សព្វ | បដ្ឋាយ សព្វ |
| ៥៣ | ៨ | ព្រះគន្ថ | ព្រះគន្ថ- |
| ៥៦ | ៥ | អជ្ឈាត្តរត្តន | អជ្ឈត្តរត្តន |
| ៥៦ | ២០ | ឧបសម្បទាបេក្ខ | ឧបសម្បទាបេក្ខៈ |
| ៥៨ | ២ | បរិសសម្បទា | បុរិសសម្បទា |
| ៨ | ២ | ដូចជាថា ឧបាយ | ដូចជាបកហើយគេះកែ<br>ក្នុងពាក្យថា សិក្ខាបទ |
| ៦៩ | ៩ | វេន័យ | វិន័យ |
| ៦៩ | ១១ | ផាអក | ផាអ្ក |
| ៧៣ | ៧ | ប្រព្រឹត្តនវ | ប្រព្រឹត្តនូវ |
| ៧៣ | ១១ | សេពនវ | សេពនូវ |
| ៧៣ | ១២ | ចរចេះច្រើន | ចូរចេះច្រើន |
| ៧៦ | ១៣ | ភាសិត | ភាសតិ |
| ៨១ | ១ | និងប្រព្រឹត្ត | នឹងប្រព្រឹត្ត |
| ៨១ | ៧ | សរាបរយៈ | សុរាមេរយៈ |
| ៩៣ | ១២ | សមណេរ | សាមណេរ |
| ៩៥ | ៤ | ចន្លាះ | ចន្លោះ |
| ៩៦ | ១៦ | ភូរគោ | ថូបគោ |
| ៥១ | ៣ | ញត្តិ | ញត្តិ- |
| ៥១ | ៤ | អនុស្សាវនៈបទ | អនុស្សាវនទាយ |
| ៥១ | ៥ | ដូចសូត្យ | ដូចជាសូត្យ |
| ៥៣ | ១០ | ដើមដោយ | ដើមជា |
| ១ | ៤ | ដូចហេតុផល | ដូចហេតុទំនាស់ផល |

www.elibraryofcambodia.org

| | | | |
|---|---|---|---|
| ៩៨ | ១៩ | ន សុរុសុរូការកកុញនៈ | ន សុរុសុរូការកកុញនៈ |
| ១០៦ | ១០ | ដំងនេះ | ដំងឺនេះ |
| ១០៦ | ១២ | គ្រាន់ជាតែ | គ្រាន់តែជា |
| ១០៧ | ៩ | បរិភោគប្រាស់ប្រើ | បរិភោគ |
| ១១០ | ២ | ដូចកេង | ដូចៈក្នុង |
| ១១០ | ៣ | បរិបហានៈ | បុរិសមានៈ |
| ១១១ | ៧ | ព្រហ្មចារិយៈ | ព្រហ្មចារិយ៍ |
| ១១៣ | ៨ | ព្រះហ្មចារិយៈ | ព្រហ្មចារិយ៍ |
| ១១៣ | ១០ | គឺ | ក្តី |
| ១១៣ | ១៨ | ទំ ឋកសវាគាគប- | ទំ សមកសវាគាគប- |
| ៤៤ | ១៧ | ត្រង់ពាក្យថាពុទ្ធំ | ត្រង់ពាក្យថាពុទ្ធ៌ |
| ក | ៤ | របស់ភក្តុ | របស់ភិក្ខុ |
| ៦៩ | ៦ | គឺពន្ធរគនៈ | គឺពុទ្ធរតនៈ |
| ៩៦ | ១៥ | វិបរិក្តិ | វិបរិត |
| ៩០ | ១៦ | វិបរិក្តិ | វិបរិត |
| ក | ៣ | សៈសេរ | សរសេរ |
| ង | ៨ | អកុសលចិត្ត ១១ | អកុសលចិត្ត ១២ |
| ង | ១៤ | ត្រង់រុងរឿង | ត្រង់រុងរឿងក្នុង នូវសព្វ<br>ទាំងអស់ ដូចភ្នំហេមពាន្ត<br>ដែលរុងរឿងក្នុងនូវភ្នំ |
| ឃ | ២០ | នាគោ ងវ | នាគោ ឥវ |
| ង | ២១ | ពុទ្ធោ ឥវ | ពុទ្ធោ ងវ |

យើងខ្ញុំជាកូន ខ្ទៅ យុនសំរ៉ង ខ្ទៅ យ៉ាតណៃ ខ្ទៅសុខផល ខ្ទៅ វិសាល ខ្ទៅ រ៉ាមុន
ខ្ទៅ ភារាជា ខ្ទៅ ចំរើន ខ្ទៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជាeBook
ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ទៅ ពាញ និង ឧបាសិកា ឈរ យឿន

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ ប៉ៅ ភារម្យ

មិថុនា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការប្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្ទៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org